

**ឧបត្ថម្ភដោយ**

Sponsored by

**មិត្តពុទ្ធសាសនិកម៉ាឡេស៊ី**

សម្រាប់ចែកជាធម្មទានប៉ុណ្ណោះ

Malaysian Buddhist Friends

For Free Distribution Only

គាថាធម្មបទ

ភិក្ខុ ស៊ុយ សុវណ្ណ

# គាថាធម្មបទ

# THE DHAMMAPADA



រៀបរៀងដោយ

**ភិក្ខុ បញ្ញាវរោ ស៊ុយ សុវណ្ណ**

**ព.ស ២៥៥៤**

# គាថាធម្មបទ

## ភាសាខ្មែរ_អង់គ្លេស

រៀបរៀងដោយ

ភិក្ខុបញ្ញាវរោ **ស៊ុយ សុវណ្ណ (ធម្មបរិញ្ញាបត្រ)**

**បោះពុម្ពផ្សាយលើកទី១**

**ចំនួន ៤០០០ ក្បាល**

ការផ្សាយរបស់

**សមាគមសមណនិស្សិតខ្មែរ**

សាកលវិទ្យាល័យធម្មទូត ទីក្រុងយ៉ាំងហ្គូន សហភាពមីយ៉ាន់ម៉ា

**ឧបត្ថម្ភបោះពុម្ពដោយ**

**មិត្តពុទ្ធសាសនិកម៉ាឡេស៊ី**

សម្រាប់ចែកចាយជាធម្មទានប៉ុណ្ណោះ

**ព.ស. ២៥៥៤**

# THE
# *DHAMMAPADA*
**(The Word of the Doctrine)**

KHMER – ENGLISH

Prepared by
**Bhikkhu Paññāvaro Suy Sovann (B.A, B.Dh)**

**First Edition**
**4,000 copies**

**A Publication Of**
**Cambodian Buddhist Student Monks**
**I.T.B.M.University, Yangon, Myanmar**

**Sponsored by**
**Malaysian Buddhist Friends**
**For Free Distribution Only**

B. E. 2554

ឈ្មោះសៀវភៅ : **គាថាធម្មបទ** ( ភាសាខ្មែរ-អង់គ្លេស)
The Dhammapada (Khmer-English)

អ្នករៀបរៀង : ភិក្ខុបញ្ញាវរោ **ស៊ុយ សុវណ្ណ** ( ធម្មបរិញ្ញាបត្រ)
Bhikkhu Paññāvaro Suy Sovann (B.A, B.Dh)
E-mail: sovann4u@gmail.com
Website: http://www.info-ksma.ning.com
http://www.info-ksma.wikidot.com
http://www.info-ksma.blogspot.com

បោះពុម្ពលើកទី១ : នៅថ្ងៃសុក្រ ទី......ខែអាសាឍ ឆ្នាំ ខាល ព.ស.
២៥៥៤ ត្រូវនឹងថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០

ចំនួនបោះពុម្ព : ៤០០០ ក្បាល
Amount : 4,000 copies
តម្លៃ (Cost) : $US 1,920 ($ 0.48/book )

អ្នកឧបត្ថម្ភ : **មិត្តពុទ្ធសាសនិកម៉ាឡេស៊ី**
Donors : Malaysian Buddhist Friends

បោះពុម្ពដោយ : **រោងពុម្ព ម៉េង ហាវ**
ផ្ទះលេខ ៨១ ផ្លូវ១៧២ សង្កាត់ជ័យជំនះ
ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ទូរស័ព្ទ ០១២ ៨២៦ ៩២០

ផ្សាយចេញពី : **សមាគមសមណនិស្សិតខ្មែរ**
សាកលវិទ្យាល័យធម្មទូត សហភាពមីយ៉ាន់ម៉ា

# មាតិកា

## Table Contents


| Chapter | Pages |
|---|---|
| អារម្ភកថា | i |
| Forward | |
| សេចក្តីថ្លែងអំណរគុណ | ii |
| Acknowledgement | |
| ជំពូកទី ១: យមកវគ្គ | 1 |
| Chapter I: Yamaka Vagga- the Twin Verses | |
| ជំពូកទី ២: អប្បមាទវគ្គ | 8 |
| Chapter II: Appamāda Vagga- Heedfulness | |
| ជំពូកទី ៣: ចិត្តវគ្គ | 12 |
| Chapter III: Citta Vagga-Mind | |
| ជំពូកទី ៤: បុប្ផវគ្គ | 16 |
| Chapter IV: Puppha Vagga- Flowers | |
| ជំពូកទី ៥: ពាលវគ្គ | 22 |
| Chapter V: Bāla Vagga– The Fool | |
| ជំពូកទី ៦: បណ្ឌិតវគ្គ | 27 |
| Chapter VI: Paṇḍita Vagga– The Wise | |
| ជំពូកទី ៧: អរហន្តវគ្គ | 32 |
| Chapter VII: Arahanta Vagga– The Worthy | |
| ជំពូកទី ៨: សហស្សវគ្គ | 35 |
| Chapter VIII: Sahassa Vagga-Thousands | |
| ជំពូកទី ៩: បាបវគ្គ | 41 |
| Chapter IX: Pāpa Vagga– Evil | |
| ជំពូកទី ១០: ទណ្ឌវគ្គ | 46 |
| Chapter X: Daṇḍa Vagga– The Rod or Punishment | |
| ជំពូកទី ១១: ជរាវគ្គ | 51 |
| Chapter XI: Jarā Vagga– Old Age | |
| ជំពូកទី ១២: អត្តវគ្គ | 56 |
| Chapter XII: Atta Vagga– The Self | |
| ជំពូកទី ១៣: លោកវគ្គ | 59 |
| Chapter XIII: Loka Vagga– The World | |
| ជំពូកទី ១៤: ពុទ្ធវគ្គ | 63 |
| Chapter XIV: Buddha Vagga–The Buddha | |
| ជំពូកទី ១៥: សុខវគ្គ | 69 |
| Chapter XV: Sukha Vagga–Happiness | |
| ជំពូកទី ១៦: បិយវគ្គ | 73 |
| Chapter XVI: Piya Vagga–Affection | |
| ជំពូកទី ១៧: កោធវគ្គ | 78 |
| Chapter XVII: Kodha Vagga–Anger | |
| ជំពូកទី ១៨: មលវគ្គ | 82 |
| Chapter XVIII: Mala Vagga–Impurities or Taints | |

ជំពូកទី ១៩: ធម្មដ្ឋវគ្គ 89
Chapter XIX: Dhammaṭṭha Vagga-The Just or The Righteous
ជំពូកទី ២០: មគ្គវគ្គ 94
Chapter XX: Magga Vagga-The Path or the Way
ជំពូកទី ២១: បកិណ្ណកវគ្គ 99
Chapter XXI: Pakiṇṇaka Vagga-Miscellaneous
ជំពូកទី ២២: និរយវគ្គ 105
Chapter XXII: Niraya Vagga-the Woeful State
ជំពូកទី ២៣:នាគវគ្គ 110
Chapter XXIII: Nāga Vagga-the Elephant
ជំពូកទី ២៤: តណ្ហាវគ្គ 115
Chapter XXIV: Taṇhā Vagga-Craving
ជំពូកទី ២៥: ភិក្ខុវគ្គ 125
Chapter XXV: Bhikkhu Vagga-The Monk
ជំពូកទី ២៦: ព្រាហ្មណវគ្គ 132
Chapter XXVI: Brāhmaṇa Vagga-The Brahman

# អារម្ភកថា

ពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ គឺពិតជាពាក្យដែលប្រកបដោយសច្ចភាព ហើយជាមាគ៌ាជីវិតដ៏ឧត្តមបំផុតសម្រាប់មនុស្សលោកទាំងអស់ប្រតិបត្តិនៅក្នុងជីវិតប្រចាំថ្ងៃ។ ជាពិសេស គាថាធម្មបទទាំងប៉ុន្មានមាននៅក្នុងសៀវភៅដែលលោកអ្នកកំពុងអាននេះ។ សៀវភៅនេះមិនមែនជាសៀវភៅប្រលោមលោក សម្រាប់ឱ្យលោកអ្នកអានកន្ទ្រាកចាប់យកនូវអារម្មណ៍តាមការប្រមើស្រមៃនៃចិត្តឡើយ។ លោកអ្នកត្រូវអានមួយគាថាម្តងៗ ហើយជញ្ជឹងគិតពិចារណាទៅលើអត្ថន័យរបស់វាដោយសន្សឹមៗ។ ក្នុងសៀវភៅនេះចែកជា ២៦ ជំពូក និងចែកជាគាថាមានចំនួន ៤២៣ គាថា។ លោកអ្នកត្រូវអានហើយអានទៀត លុះត្រាអ្នកចូលចិត្ត។ អ្វីដែលរឹងរឹតតែល្អហើយពិសេសទៀតនោះគឺ សៀវភៅនេះមានពីរភាសា (ខ្មែរ និងអង់គ្លេស) ដែលអាចជួយដល់អ្នកសិក្សាស្រាវជ្រាវទាំងឡាយទៀតផង។

ប៉ុន្តែ ទោះបីជាយ៉ាងណាក្តី ខ្ញុំព្រះករុណាអាត្មាភាពមិនបានគិតថាសៀវភៅនេះត្រឹមត្រូវមួយរយភាគរយនោះទេ។ ការខុសភ្លាំងភ្លាត់ណាមួយដោយអចេតនាតែងកើតមាន ហេតុនេះខ្ញុំសូមស្វាគមន៍ដោយក្តីសោមនស្សរីករាយនូវរាល់ពាក្យរិះគន់ស្ថាបនា ដើម្បីទុកជាការកែតម្រូវទៅថ្ងៃខាងមុខ។

សាកលវិទ្យាល័យពុទ្ធសាសនទូតថេរវាទអន្តរជាតិ

ថ្ងៃទី ០៥ ខែសីហា ឆ្នាំ ២០១០



# សេចក្តីថ្លែងអំណរគុណ

ខ្ញុំព្រះករុណាអាត្មាភាព សូមសម្តែងនូវកតញ្ញុតាធម៌ដឹងគុណ និងអរគុណយ៉ាងជ្រាលជ្រៅបំផុតដល់ :

- ព្រះតេជគុណ **ថន វណ្ណុង** ប្រធានសមាគមពុទ្ធសាសនា និងអភិវឌ្ឍន៍សង្គមប្រចាំខេត្តកំពង់ចាម។

- ព្រះតេជគុណ **ស៊ិន គង់** ដែលបានចំណាយពេលវេលាដ៏មមាញឹកក្នុងការជួយចាត់ចែងបោះពុម្ពសៀវភៅគាថាធម្មបទនេះ។

- ព្រះតេជគុណព្រះឧត្តមសត្ថា **ជា ឆោម** ដែលបានឧបត្ថម្ភបច្ច័យបួន និងពាក្យដំបូន្មានល្អៗដល់ខ្ញុំព្រះករុណា។

- ព្រះតេជគុណវិជ្ជាសម្បន្នោ **ឈួម បូ** ញោមឧបាសិកា **ចយ សារឿន** ញោម **សុវណ្ណី** និងញោមញាតិចំណុះជើងវត្តពន្លឺពុទ្ធចក្កទាំងអស់

- ឧបាសក **ម៉ៅ ថាន** ឧបាសិកា **ឆន់ សំបូរ** អតីតទីប្រឹក្សាឯកអគ្គរាជទូតកម្ពុជា ប្រចាំសហភាពមីយ៉ាន់ម៉ា។

- លោក **យូ ឆាន** (Mr. Yu Ban) ពីប្រទេសម៉ាឡេស៊ី (Malaysia) ដែលមានសទ្ធាជ្រះថ្លា ក្នុងការខ្នះខ្នែងស្វែងរកថវិកាជួយបោះពុម្ពសៀវភៅ "ហេតុអ្វីបានជាមានពុទ្ធសាសនា?" "*Why Buddhism?*" និងសៀវភៅ "ខ្លឹមសារជីវិត" "*The Purpose of Life*" និងសៀវភៅ "គាថាធម្មបទ" (The Dhammapada) សម្រាប់ចែកជាធម្មទានដល់សាធារណជន និងសូម

អរគុណដល់ "មិត្តពុទ្ធសាសនិកម៉ាឡេស៊ី" "All Malaysian Buddhist Friends" and មិត្តសប្បុរសជនចំណុះជើងវត្ត មហាវិហារ "Devotees and Friends of Buddhist Mahā Vihāra" ទាំងអស់។

- ញោមឧបាសិកា **គិម ស៊ីមឿន សីលវន្ត សីលវតី** នៅក្នុងពុទ្ធមណ្ឌលវិបស្សនាធុរៈនៃព្រះរាជាណាចក្រកម្ពុជាទាំងអស់ ដែលតែងតែយកចិត្តទុកដួយឧបត្ថម្ភបច្ច័យបួន និងវត្ថុគ្រប់បែបយ៉ាងដល់សមណនិស្សខ្មែរនៅភូមា។

- ញោមមហាឧបាសិកា **កាំង ហ៊ិចណៃ** និងក្រុមគ្រួសារ ដែលតែងតែជួយឧបត្ថម្ភដល់សមណនិស្សិតខ្មែរនៅភូមា។

- ញោមប្រុស នេត ខេលេយ៏ (Mr. Nate Kelley) ដែលបានឧបត្ថម្ភបច្ច័យបួនដល់សមណនិស្សិតខ្មែរ។

- ព្រះតេជគុណ ព្រះករុណាម្ចាស់គ្រប់អង្គនៅក្នុងសាកលវិទ្យាល័យ-ពុទ្ធសាសនទូតថេរវាទអន្តរជាតិ ដែលតែងតែជួយត្រួតពិនិត្យ និងផ្តល់នូវមតិយោបល់ល្អៗដល់ខ្ញុំ។

សូមបុណ្យកុសលជាអំពើល្អតាមជួយថែរក្សាអស់លោកអ្នក សប្បុរសជនគ្រប់ទិនទិវារាត្រីកុំបីខានឡើយ។ សូមឱ្យសាសនាព្រះជិនស្រីស្ថិតនៅគ្រប់ ៥០០០ ព្រះវស្សាដោយបរិបូរណ៍។ សូមឱ្យកម្ពុជរដ្ឋសំបូរទៅដោយអ្នកប្រាជ្ញបណ្ឌិតកវី ដូចអរិយប្រទេសនានានៅក្នុងសាកលលោក។

សូមព្រះគុណ! សូមអរគុណ!

## ជំពូកទី ១: យមកវគ្គ

## Chapter I: Yamaka Vagga – The Twin Verses

គាថាទី ១: ធម៌ទាំងឡាយមានចិត្តជាធំ មានចិត្តប្រសើរបំផុត សម្រេចមកពីចិត្ត បើបុគ្គលមានចិត្តត្រូវទោសៈប្រទូស្តរ៉ាយហើយ ទោះបីនិយាយក្តី ធ្វើក្តី (ក៏អាក្រក់ដែរ) ព្រោះអំពើអាក្រក់នោះឯងហើយ សេចក្តីទុក្ខរមែងដេញជាប់តាមក្រោយបុគ្គលនោះ ដូចជាកង់រទេះវិលតាមស្នាមជើងគោដែលអូសនឹមរទេះយ៉ាងដូច្នោះឯង ។

Verse 1: All mental phenomenas have mind as their forerunner; they have mind as their chief; they are mind-made. If one speaks or acts with an evil mind, suffering follows him just as the wheel follows the hoofprint of the ox that draws the cart.

គាថាទី ២: ធម៌ទាំងឡាយមានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចមកពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ទោះបីនិយាយក្តី ធ្វើក្តី (ក៏ល្អទាំងអស់) ព្រោះចិត្តជ្រះថ្លានោះឯង សេចក្តីសុខរមែងតាមជាប់បុគ្គលនោះ ដូចជាស្រមោលដែលអន្ទោលតាមប្រាណយ៉ាងដូច្នោះឯង ។

Verse 2: All mental phenomenas have mind as their forerunner; they have mind as their chief; they are mind-made. If one speaks or acts with a pure mind, happiness (*sukha*) follows him like a shadow that never leaves him.





គាថាទី ៣: ជនទាំងឡាយណាចងសេចក្តីក្រោធខឹងនោះទុកយ៉ាងនេះថា "អ្នកនោះបានជេរអញ អ្នកនោះបានវាយអញ អ្នកនោះបានឈ្នះអញ អ្នកនោះបានលួចទ្រព្យរបស់អញ" ពៀរវេរារបស់ជនទាំងឡាយនោះ នឹងមិនស្ងប់រម្ងាប់ឡើយ ។

Verse 3. "He abused me, he ill-treated me, he got the better of me, he stole my belongings;"... the enmity of those harbouring such thoughts cannot be appeased.

គាថាទី ៤: ជនទាំងឡាយណាមិនចូលទៅចងសេចក្តីក្រោធខឹងនោះទុកយ៉ាងនេះថា "អ្នកនោះបានជេរអញ អ្នកនោះបានវាយអញ អ្នកនោះបានឈ្នះអញ អ្នកនោះបានលួចទ្រព្យរបស់អញ" ពៀរវេរារបស់ជនទាំងឡាយនោះ នឹងស្ងប់រម្ងាប់បាន ។

Verse 4. "He abused me, he ill-treated me, he got the better of me, he stole my belongings;" ... the enmity of those not harbouring such thoughts can be appeased.

គាថាទី ៥: ក្នុងកាលណាៗក៏ដោយ ធម្មតាពៀរទាំងឡាយក្នុងលោកនេះមិនដែលស្ងប់រម្ងាប់ដោយការចងពៀរឡើយ តាមការពិត ពៀរទាំងឡាយតែងស្ងប់រម្ងាប់ដោយការមិនចងពៀរ នេះជាធម៌ចាស់ មានយូរណាស់មកហើយ ។

Verse 5. Hatred is, indeed, never appeased by hatred in this world. It is appeased only by loving-kindness. This is an ancient law.

គាថាទី ៦: ពួកជនដទៃទៀត មិនដឹងច្បាស់ថា “ពួកយើងទាំងអស់គ្នាកំពុងតែត្រដាបត្រដួសនៅក្នុងទីប្រជុំសង្ឃនេះ” ឯជនទាំងឡាយណា នៅក្នុងទីប្រជុំសង្ឃនោះ ដឹងច្បាស់យ៉ាងនោះ សេចក្តីវិវាទទាស់ទែងគ្នានឹងស្ងប់រម្ងាប់បាន ព្រោះពួកជនទាំងនោះ ។

Verse 6. People, other than the wise, do not realize, "We in this world must all die," (and not realizing it continues their quarrels). The wise realize it and thereby their quarrels cease.

គាថាទី ៧: មាររមែងបៀតបៀនបុគ្គលដែលឃើញតាមអារម្មណ៏ថា ល្អ មិនសង្រួមក្នុងឥន្ទ្រីយ៏ទាំងឡាយ មិនស្គាល់ប្រមាណក្នុងភោជនាហារ ខ្ជិលច្រអូស មានសេចក្តីព្យាយាមអន់ថយនោះ បានដោយងាយស្រួល ដូចវាយោបក់បោករំលើងនូវដើមឈើដែលមានឫសមិនល្អ យ៉ាងនោះឯង ។

Verse 7. He who keeps his mind on pleasant objects, who is uncontrolled in his senses, immoderate in his food, and is lazy and lacking in energy, will certainly be overwhelmed by Māra, just as stormy winds uproot a weak tree.

គាថាទី ៨: មារមិនអាចបៀតបៀនបុគ្គលដែលពិចារណាឃើញតាមអារម្មណ៏ថា មិនល្អ សង្រួមក្នុងឥន្ទ្រីយ៏ទាំងឡាយ ស្គាល់ប្រមាណក្នុងភោជនាហារ មានសទ្ធា មានសេចក្តីព្យាយាមល្អហើយនោះបានឡើយ ដូចព្រះពាយបក់បោកថ្មភ្នំតាន់ឱ្យបែកបាក់មិនបាន យ៉ាងនោះឯង ។

Verse 8. He who keeps his mind on the impurities (of the body), who is well-controlled in his senses and is full of faith





(Saddhā) and energy, will certainly be not overwhelmed by Māra, just as stormy winds cannot shake a mountain of rock.

គាថាទី ៩: បុគ្គលណាមិនមែនជាអ្នកមានកិលេស ដូចជាទឹកអម្ចត់ប្រាសចេញហើយ មិនមានទមៈ និងសច្ចៈ គ្រងនូវសំពត់កាសាវពស្ត្រ បុគ្គលនោះមិនសមគួរនឹងស្លៀកដណ្តប់នូវសំពត់កាសាវពស្ត្រឡើយ ។

Verse 9. He who is not free from taints of moral defilements (kilesas) and yet dons the yellow robe, who lacks restraint in his senses and (speaks not the) truth is unworthy of the yellow robe.

គាថាទី ១០: បុគ្គលណាមានកិលេសដូចជាទឹកអម្ចត់ប្រាសចេញហើយ តម្កល់ខ្លួនបានល្អហើយ នៅក្នុងសីលទាំងឡាយ មានទមៈ និងសច្ចៈ បុគ្គលនោះទើបសមគួរនឹងស្លៀកដណ្តប់នូវសំពត់កាសាវពស្ត្រ ។

Verse 10. He who has discarded all moral defilements (kilesas), who is established in moral precepts, is endowed with restraint and (speaks the) truth is, indeed, worthy of the yellow robe.

គាថាទី ១១: ជនទាំងឡាយណាមានការសម្គាល់ក្នុងរបស់ដែលមិនមានសារៈថា មានសារៈ យល់ឃើញក្នុងរបស់ដែលមានសារៈថា មិនមានសារៈ ជនទាំងឡាយនោះ មានតែការត្រិះរិះខុសជាគោចរ នឹងមិនបានសម្រេចនូវធម្មសារៈឡើយ ។

Verse 11. They take untruth for truth; they take truth for untruth; such persons can never arrive at the truth, for they hold wrong views.

គាថាទី ១២: ជនទាំងឡាយណាដឹងនូវរបស់ដែលមានសារៈ ដោយហេតុដែលមានសារៈ ដឹងនូវរបស់ដែលគ្មានសារៈ ដោយហេតុដែលគ្មានសារៈ ជនទាំងឡាយនោះ ជាអ្នកមានសេចក្តីត្រិះរិះត្រូវជាគោចរ នឹងបានសម្រេចនូវធម្មសារៈ។

Verse 12. They take truth for truth; they take untruth for untruth; such persons arrive at the truth, for they hold right views.

គាថាទី ១៣: តំណក់ទឹកភ្លៀងតែងលេចស្រោចនូវផ្ទះដែលគេប្រក់ដំបូលមិនជិតល្អយ៉ាងណា រាគៈតែងចាក់ទម្លុះនូវចិត្តដែលបុគ្គលមិនបានចម្រើន យ៉ាងនោះដែរ។

Verse 13. Just as rain penetrates a badly-roofed house, so also, passion (rāga) penetrates a mind not cultivated in Tranquillity and Insight Development (Samatha and Vipassanā).

គាថាទី ១៤: តំណក់ទឹកភ្លៀងមិនអាចលេចស្រោចនូវផ្ទះ ដែលគេប្រក់ជិតដោយល្អយ៉ាងណា រាគៈក៏មិនអាចនឹងចាក់ទម្លុះនូវចិត្តដែលបុគ្គលបានចម្រើនដោយល្អហើយ ក៏យ៉ាងនោះដែរ។

Verse 14. Just as rain cannot penetrate a well-roofed house, so also, passion (rāga) cannot penetrate a mind well-cultivated in Tranquillity and Insight Development (Samatha and Vipa–ssanā).





គាថាទី ១៥: អ្នកដែលធ្វើអំពើបាបកម្មរមែងសោកសៅ ក្នុងលោកទាំងពីរ គឺរមែងសោកសៅក្នុងលោកនេះផង សោកសៅក្នុងលោកខាងមុខផង គេរមែងសោកសៅក្តៅក្រហល់ក្រហាយ ព្រោះឃើញកម្មដែលសៅហ្មងរបស់ខ្លួន។

Verse 15. Here he grieves, hereafter he grieves; the evil-doer grieves in both existences. He grieves and he suffers anguish when he sees the depravity of his own deeds.

គាថាទី ១៦: អ្នកដែលបានធ្វើបុណ្យទុកមកហើយ រមែងត្រេកអររីករាយសប្បាយក្នុងលោកទាំងពីរ គឺរីករាយក្នុងលោកនេះផង រីករាយក្នុងលោកខាងមុខផង គេរមែងត្រេកអររីករាយសប្បាយ ព្រោះឃើញនូវកម្មដែលបរិសុទ្ធរបស់ខ្លួន។

Verse 16. Here he rejoices, hereafter he rejoices; one who performed meritorious deeds rejoices in both existences. He rejoices and greatly rejoices when he sees the purity of his own deeds.

គាថាទី ១៧: អ្នកធ្វើបាបតែងក្តៅក្រហាយក្នុងលោកទាំងពីរ គឺក្នុងលោកនេះផង ស្លាប់ទៅហើយក៏ក្តៅក្រហាយក្នុងលោកខាងមុខផង គេតែងក្តៅក្រ-ហាយ ព្រោះដឹងថា "ខ្លួនបានធ្វើបាប" ដល់ទុគ្គតិហើយ ក៏រឹតតែក្តៅក្រហាយលើសដើម។

Verse 17. Here he is tormented, hereafter he is tormented; the evil-doer is tormented in both existences. He is tormented, and he laments: "Evil have I done." He is even more tormented when he is reborn in one of the lower worlds (Apāya).

គាថាទី ១៨: អ្នកដែលបានធ្វើបុណ្យទុកមកហើយ រមែងត្រេកអររីករាយ ក្នុងលោកទាំងពីរ គឺ ត្រេកអររីករាយក្នុងលោកនេះផង ក្នុងលោកខាងមុខផង គេរមែងត្រេកអររីករាយ ក៏ព្រោះដឹងថា ខ្លួនគេបានធ្វើបុណ្យទុកមកហើយ ទៅដល់សុគតិហើយ ក៏រឹតតែត្រេកអរជាភិយ្យោភាព។

Verse 18. Here he is happy, hereafter he is happy; one who performs meritorious deeds is happy in both existences. Happily he exclaims: I have done meritorious deeds. He is happier still when he is reborn in a higher world (sugati).

គាថាទី ១៩: បើបុគ្គលនិយាយធម៌ដែលមានប្រយោជន៍ ទោះបីជាច្រើនយ៉ាងណាក៏ដោយ តែជាអ្នកប្រមាទ មិនប្រព្រឹត្តតាមធម៌ទាំងនោះ ដូចជាអ្នកចិញ្ចឹមគោ រាប់គោឱ្យអ្នកដទៃ ជាអ្នកមិនមានចំណែកនៃសាមញ្ញផលយ៉ាងនោះឯង។

Verse 19. Though he recites much the Sacred Texts (Tipiṭaka), but is negligent and does not practise according to the Dhamma, like a cowherd who counts the cattle of others, he has no share in the benefits of the life of a bhikkhu (i.e., Magga-phala).

គាថាទី ២០: បើបុគ្គលនិយាយធម៌ដែលមានប្រយោជន៍ ទោះបីជាតិចតួចក៏ដោយ តែជាអ្នកប្រព្រឹត្តសមគួរដល់ធម៌នោះ លះបង់ចោលនូវរាគៈ ទោសៈ និងមោហៈអស់ហើយ ជាអ្នកចេះដឹងសព្វគ្រប់ មានចិត្តរួចផុតស្រឡះហើយ





ជាអ្នកមិនប្រកាន់មាំ ក្នុងលោកនេះ ឬលោកខាងមុខ បុគ្គលនោះជាអ្នកមានចំណែកនៃសាមញ្ញផលដោយពិត។

Verse 20. Though he recites only a little of the Sacred Texts (Tipiṭaka), but practises according to the Dhamma, eradicating passion, ill will and ignorance, clearly comprehending the Dhamma, with his mind freed from moral defilements and no longer clinging to this world or to the next, he shares the benefits of the life of a bhikkhu (i.e., Magga-phala).

## ជំពូកទី ២: អប្បមាទវគ្គ

## Chapter II: Appamāda Vagga– Heedfulness

គាថាទី ២១: សេចក្តីមិនប្រមាទជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទជាផ្លូវនៃសេចក្តីស្លាប់ អ្នកដែលមិនប្រមាទហើយ ឈ្មោះថាមិនស្លាប់ អ្នកដែលប្រមាទហើយ ប្រៀបដូចជាបុគ្គលដែលស្លាប់ទៅហើយ។

Verse 21. Mindfulness is the way to the Deathless (Nibbāna); unmindfulness is the way to Death. Those who are mindful do not die; those who are not mindful are as if already dead.

គាថាទី ២២: បណ្ឌិតទាំងឡាយដឹងរឿងនេះ ដោយវិសេសហើយ ទើបតាំងនៅក្នុងសេចក្តីមិនប្រមាទ រីករាយក្នុងសេចក្តីមិនប្រមាទ ត្រេកអរក្នុងធម៌ជាទីគោចររបស់ព្រះអរិយៈទាំងឡាយ។

Verse 22. Fully comprehending this, the wise, who are mindful, rejoice in being mindful and find delight in the domain of the Noble Ones (Ariyas).

គាថាទី ២៣: បណ្ឌិតអ្នកមិនប្រមាទទាំងនោះ ជាអ្នកបានឈាន មានសេចក្តីព្យាយាម មានការប្រឹងប្រែងជាប់ជានិច្ច ជាអ្នកប្រាជ្ញ តែងពាល់ត្រូវនូវព្រះ-និព្វានដែលជាឋានក្សេមចាកយោគៈដ៏ប្រសើរ ។

Verse 23. The wise, constantly cultivating Tranquillity and Insight Development Practice, being ever mindful and steadfastly striving, realize Nibbāna: Nibbāna, which is free from the bonds of yoga; Nibbāna, the Incomparable!

គាថាទី២៤: យសស័ក្តិរមែងចម្រើនកើតមានដល់បុគ្គលដែលមានសេចក្តីព្យា-យាមប្រឹងប្រែង មានសតិស្មារតី មានការងារប្រពៃ ពិចារណាហើយទើបធ្វើ ជាអ្នកសង្រួមហើយ រស់នៅប្រកបដោយធម៌ ជាអ្នកមិនប្រមាទ ។

Verse 24. If a person is energetic, mindful, pure in his thought, word and deed, and if he does every thing with care and consideration, restrains his senses, earns his living according to the Law (Dhamma) and is not unheedful, then, the fame and fortune of that mindful person steadily increase.

គាថាទី ២៥: កិលេសដូចជាទឹកស្ទឹងលិចទីពឹងណាពុំបាន អ្នកប្រាជ្ញគប្បីធ្វើទីពឹងនោះ ដោយការព្យាយាមប្រឹងប្រែង ដោយការមិនប្រមាទ ដោយការសង្រួម និងដោយការអប់រំទូន្មានខ្លួន ។

Verse 25. Through diligence, mindfulness, discipline (with regard to moral precepts), and control of his senses, let the man





of wisdom make (of himself) an island which no flood can overwhelm.

គាថាទី ២៦: ពួកជនពាលឥតមានបញ្ញាល្ងង់ខ្លៅ រមែងតាមប្រកបនូវសេចក្តីប្រមាទ ចំណែកអ្នកប្រាជ្ញវិញ តែងរក្សាទុកនូវសេចក្តីមិនប្រមាទ ដូចជាបុគ្គលរក្សាទ្រព្យដ៏ប្រសើរទុកយ៉ាងនោះឯង ។

Verse 26. The foolish and the ignorant give themselves over to negligence; whereas the wise treasure mindfulness as a precious jewel.

គាថាទី ២៧: អ្នកទាំងឡាយចូរកុំតាមប្រកបសេចក្តីប្រមាទឡើយ ចូរកុំតាមប្រកបសេចក្តីត្រេកអរក្នុងកាមឡើយ ព្រោះថាអ្នកដែលមិនប្រមាទហើយរំពឹងពិចារណាត្រិះរិះនឹងបានសម្រេចនូវសេចក្តីសុខដ៏ប្រសើរ ។

Verse 27. Therefore, one should not be negligent, nor be addicted to sensual pleasures; for he who is established in mindfulness, through cultivation of Tranquillity and Insight Development Practice, experiences supreme happiness (i.e., realizes Nibbāna).

គាថាទី ២៨: ពេលណាបណ្ឌិតកំចាត់បង់នូវសេចក្តីប្រមាទ ដោយសេចក្តីមិនប្រមាទ ពេលនោះបណ្ឌិតនោះនឹងឡើងទៅដល់បញ្ញា ដូចជាប្រាសាទ មិនមានសេចក្តីសោកសៅ តែងមើលឃើញនូវពួកសត្វដែលមានសេចក្តីសោកសៅ អ្នកមានបញ្ញារមែងមើលឃើញនូវបុគ្គលពាលទាំងឡាយ ដូចជាបុគ្គលដែល

ឈរនៅលើកំពូលភ្នំ មើលឃើញនូវបុគ្គលដែលឈរនៅលើផែនដី យ៉ាងនោះឯង ។

Verse 28. The wise one dispels negligence by means of mindfulness; he ascends the tower of wisdom and being free from sorrow looks at the sorrowing beings. Just as one on the mountain top looks at those on the plain below, so also, the wise one (the arahat) looks at the foolish and the ignorant (worldlings).

គាថាទី ២៩: អ្នកមានប្រាជ្ញា កាលបើមនុស្សទាំងឡាយប្រមាទហើយ ជាអ្នកមិនប្រមាទ កាលបើមនុស្សទាំងឡាយដេកលក់ហើយ ជាអ្នកភ្ញាក់ឡើងច្រើន លះបង់ចោលនូវបុគ្គលដែលល្ងង់ខ្លៅទៅបាន ដូចជាសេះដែលមានល្បឿនលឿន បោលឈ្នះសេះដែលមានល្បឿនតិចយ៉ាងដូច្នោះឯង ។

Verse 29. Mindful amongst the negligent, highly vigilant amongst the drowsy, the man of wisdom advances like a race-horse, leaving the jade behind.

គាថាទី ៣០: មឃវទេវរាជបានដល់នូវភាពជាអ្នកប្រសើរខ្ពង់ខ្ពស់ជាងទេវតាទាំងឡាយព្រោះសេចក្ដីមិនប្រមាទ បណ្ឌិតទាំងឡាយសរសើរសេចក្ដីមិនប្រ-មាទ សេចក្ដីប្រមាទ បណ្ឌិតលោកតិះដៀលគ្រប់ពេលវេលា ។

Verse 30. Through mindfulness (in doing meritorious deeds) Maghava became king of the devas. Mindfulness is always praised, but negligence is always blamed.





គាថាទី ៣១: ភិក្ខុជាអ្នកត្រេកអរហើយក្នុងសេចក្ដីមិនប្រមាទ ឬជាអ្នកឃើញភ័យក្នុងសេចក្ដីប្រមាទ រមែងដុតបំផ្លាញនូវសំយោជន៍តូចធំទៅបាន ដូចជាភ្លើងព្រៃឆេះកំទេចនូវសម្រាមតូចធំយ៉ាងដូច្នោះឯង ។

Verse 31. A bhikkhu who takes delight in mindfulness and sees danger in negligence, advances like fire, burning up all fetters, great and small.

គាថាទី ៣២: ភិក្ខុជាអ្នកត្រេកអរហើយក្នុងសេចក្ដីមិនប្រមាទ ឬជាអ្នកឃើញភ័យក្នុងសេចក្ដីប្រមាទ មិនគួរនឹងវិនាសសាបសូន្យ (ពីមគ្គផល) ស្ថិតនៅជិតបង្កើយនៃព្រះនិព្វាន ។

Verse 32: A bhikkhu who takes delight in mindfulness and sees danger in negligence will not fall away, he is, indeed, very close to Nibbāna.

## ជំពូកទី៣: ចិត្តវគ្គ

## Chapter III: Citta Vagga– mind

គាថាទី ៣៣: អ្នកមានប្រាជ្ញាតែងពត់ចិត្តដែលកម្រើកញាប់ញ័រ ឃ្លេងឃ្លោងរក្សាបានដោយកម្រ ហាមឃាត់បានដោយកម្រ ឱ្យជាចិត្តត្រង់បាន ដូចជាជាងធ្វើព្រួញ ពត់ព្រួញឱ្យត្រង់យ៉ាងដូច្នោះឯង ។

Verse 33. The mind is excitable and unsteady; it is difficult to control and to restrain. The wise one trains his mind to be upright as a fletcher straightens an arrow.

គាថាទី ៣៤: ធម្មតាវារិជាត (សត្វដែលកើតក្នុងទឹក មានត្រីជាដើម) ដែលអ្នកនេសាទចាប់ស្រង់ឡើងផុតពីក្នុងទឹក ហើយបានបោះចោលទៅលើគោកតែងតែបម្រះនឡៀល យ៉ាងណាមិញ, ចិត្តនេះ ដែលព្រះយោគាវចរបុគ្គលលើកឱ្យផុតអំពីទឹកដែលធ្លាប់នៅ គឺកាមគុណទាំង៥ ហើយបោះទៅលើគោកពោលគឺ វិបស្សនាកម្មដ្ឋាន ដើម្បីនឹងផ្តាច់ចំណងនៃមារ រមែងញាប់ញ័រអន្ទះ-អន្ទែង ក៏យ៉ាងដូច្នោះដែរ ។

Verse 34. As a fish quivers when taken out of its watery home and thrown on to dry ground, so does the mind quiver when it is taken out of the sensual world to escape from the realm of Māra (i.e., kilesa vaṭṭa, round of moral defilements).

គាថាទី ៣៥: ការទូន្មានចិត្តដែលហាមឃាត់បានដោយកម្រ ជាធម្មជាតិស្រាល មានប្រក្រតីធ្លាក់ចុះទៅក្នុងអារម្មណ៍ដែលជាទីប្រាថ្នា ជាការប្រសើរ ព្រោះថា ចិត្តដែលគេអប់រំបានល្អហើយ តែងនាំសេចក្តីមកឱ្យ ។

Verse 35. The mind is difficult to control; swiftly and lightly, it moves and lands wherever it pleases. It is good to tame the mind, for a well-tamed mind brings happiness.

គាថាទី ៣៦: អ្នកមានប្រាជ្ញា គប្បីរក្សាចិត្តដែលមើលឃើញបានដោយលំបាកល្អិតបំផុត មានប្រក្រតីធ្លាក់ចុះទៅក្នុងអារម្មណ៍ដែលជាទីប្រាថ្នា ចិត្តដែលគេគ្រប់គ្រងបានល្អហើយ តែងនាំសេចក្តីសុខមកឱ្យ ។





Verse 36. The mind is very difficult to see, very delicate and subtle; it moves and lands wherever it pleases. The wise one should guard his mind, for a guarded mind brings happiness.

គាថាទី ៣៧: ជនទាំងឡាយសង្រួមចិត្តដែលទទួលអារម្មណ៍នៅទីឆ្ងាយ ត្រាច់ចរទៅតែមួយដួង គ្មានសរីរៈរាងកាយ គ្មានគុហា (គឺកាយ) ជាទីនៅអាស្រ័យបាន ជនទាំងឡាយនោះ នឹងរួចផុតអំពីចំណងរបស់មារ ។

Verse 37. The mind wanders far and moves about alone: it is non-material; it lies in the cave (chamber) of the heart. Those who control their mind will be free from the bonds of Māra.

គាថាទី ៣៨: បញ្ញាមិនដែលចម្រើនដល់បុគ្គលដែលមានចិត្តមិនគង់វង្ស មិនដឹងច្បាស់នូវព្រះធម៌ មានសេចក្តីជ្រះថ្លារវើរវាយ រសាត់អណ្តែត ។

Verse 38. If a man's mind is unsteady, if he is ignorant of the true Dhamma, and if his faith is wavering, then his knowledge will never be perfect.

គាថាទី ៣៩: ភ័យនឹងមិនមានដល់បុគ្គលដែលមានចិត្តមិនទទឹកសើមដោយរាគៈ មានចិត្តមិនត្រូវទោសៈប្រទូសរ៉ាយហើយ លះបុណ្យនិងបាបបានអស់ហើយ ភ្ញាក់រលឹកឡើង ។

Verse 39. If a manes mind is free from passion, if he is free from ill-will, if he has abandoned both good and evil, and if he is vigilant, for such a man there is no danger.

គាថាទី ៤០: បណ្ឌិតដឹងច្បាស់នូវកាយនេះថា ដូចជាឆ្នាំងដី ហើយរក្សាចិត្តនេះ ដូចជាគេរក្សានគរ យ៉ាងនោះឯង, គប្បីច្បាំងតទល់ជាមួយនឹងមារាធិរាជ ដោយអាវុធ គឺបញ្ញា គប្បីរក្សានូវជ័យជំនះដែលបានឈ្នះហើយ តែមិនគួរជាប់ជំពាក់ (នៅក្នុងជ័យជំនះនោះឡើយ) ។

Verse 40. Knowing that this body is (fragile) like an earthern jar, making one's mind secure like a fortified town, one should fight Māra with the weapon of Knowledge. (After defeating Māra) one should still continue to guard one's mind, and feel no attachment to that which has been gained (i.e., jhāna ecstasy and serenity gained through meditation).

គាថាទី ៤១: កាយនេះមិននៅយូរប៉ុន្មានឡើយ តែមានវិញ្ញាណទៅប្រាស ហើយ ជាកាយគឺគេបោះបង់ចោល ក៏នឹងដេកសង្កត់នៅលើផែនដី ដូចជាអង្កត់ឧសរកប្រយោជន៍គ្មាន ។

Verse 41. Before long, alas, this body, deprived of consciousness, will lie on the earth, discarded like a useless log.

គាថាទី ៤២: ចោរឃើញចោរ ឬមនុស្សមានពៀរឃើញមនុស្សដែលមានពៀរនឹងគ្នាហើយ គប្បីធ្វើនូវសេចក្តីវិនាសអន្តរាយ ហិនហោចណាមួយ ដល់គ្នានឹងគ្នាមិនខានឡើយ, ឯចិត្តដែលបុគ្គលតម្កល់ទុកខុសហើយ គប្បីធ្វើបុគ្គលនោះឱ្យអាក្រក់លើសជាងសេចក្តីវិនាសដែលពួកចោរ និងមនុស្សមានពៀរវេរាធ្វើដល់គ្នាទៅទៀត ។





Verse 42. A thief may harm a thief; an enemy may harm an enemy; but a wrongly directed mind can do oneself far greater harm.

គាថាទី ៤៣: មាតាបិតា ឬពួកញាតិដទៃទៀត មិនអាចធ្វើនូវហេតុនោះ ឱ្យបានឡើយ (មានតែ) ចិត្តដែលបុគ្គលតម្កល់ទុកត្រូវហើយ (ប៉ុណ្ណោះ) អាចធ្វើនូវបុគ្គលនោះ ឱ្យបានប្រសើរជាងហេតុនោះទៅទៀត ។

Verse 43: Not a mother, nor a father, nor any other relative can do more for the well-being of one than a rightly-directed mind can.

## ជំពូកទី ៤: បុប្ផវគ្គ

## Chapter IV: Puppha Vagga– Flowers

គាថាទី ៤៤: អ្នកណានឹងដឹងច្បាស់នូវផែនដីនេះ និងយមលោក និងមនុស្សលោកនេះ ព្រមទាំងទេវលោកបាន អ្នកណានឹងជ្រើសយកនូវបទនៃធម៌ដែលតថាគតសម្តែងល្អហើយ ដូចជានាយមាលាការដែលឆ្លាត ជ្រើសរើសយកផ្កាឈើ យ៉ាងនោះឯង ។

Verse 44. Who shall examine this earth (i.e., this body) the world of Yama (i.e., the four Apāyas) and the world of man together with the world of devas? Who shall examine the well-taught Path of Virtue (Dhammapada) as an expert florist picks and chooses flowers?

គាថាទី ៤៥: ព្រះសេក្ខៈ នឹងដឹងច្បាស់នូវផែនដីនេះ និងយមលោក មនុស្សលោកនេះ ព្រមទាំងទេវលោកបាន ព្រះសេក្ខៈនឹងជ្រើសយកបទនៃធម៌ដែលតថាគតសម្តែងល្អហើយ ដូចជានាយមាលាការដែលឆ្លាត ជ្រើសរើសយកផ្កាឈើ យ៉ាងនោះឯង ។

Verse 45. The Ariya Sekha shall examine this earth (i.e., the body), the world of Yama (i.e., the four Apāyas) and the world of man together with the world of devas. The Ariya Sekha shall examine the well-taught Path of Virtue (Dhammapada) as an expert florist picks and chooses flowers.

គាថាទី ៤៦: ភិក្ខុដឹងច្បាស់នូវរាងកាយនេះថា ដូចជាពពុះទឹក ដឹងច្បាស់នូវរាងកាយនេះថា ដូចជាថ្ងៃបណ្តើរកូន ជាធម៌គប្បីកាត់ចោលនូវកម្រងផ្ការបស់មារាធិរាជ គឺវដ្តៈទាំងបី ហើយដល់ស្ថានទីដែលមច្ចុរាជមើលមិនឃើញ គឺព្រះនិព្វាន ។

Verse 46. One who knows that this body is impermanent like froth, and comprehends that it is insubstantial like a mirage, will cut the flowers of Māra (i.e., the three kinds of *vaṭṭa* or rounds), and pass out of sight of the King of Death.

គាថាទី ៤៧: មច្ចុរាជ គឺសេចក្តីស្លាប់ រមែងអូសទាញយកនូវនរជនដែលមានចិត្តជាប់ជំពាក់ ក្នុងអារម្មណ៍ផ្សេងៗ ជាអ្នកកំពុងតែជ្រើសរើសយកកម្រងផ្កា គឺបញ្ចកាមគុណទៅ ដូចជាមហាសាគរដ៏ធំធេងជន់លិចកួចយកអ្នកស្រុក ដែលដេកលក់ទៅ យ៉ាងនោះឯង ។





Verse 47. Like one who picks and chooses flowers, a man who has his mind attached to sensual pleasures is carried away by Death, just as a great flood sweeps away a sleeping village.

គាថាទី ៤៨: មច្ចុរាជ រមែងធ្វើនូវនរជនដែលមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ ជាអ្នកកំពុងតែជ្រើសយកផ្កាឈើទាំងឡាយ គឺបញ្ចកាមគុណ ជាអ្នកមិនចេះឆ្អែតឆ្អន់ក្នុងកាមទាំងឡាយ ឱ្យចូលកាន់អំណាចរបស់ខ្លួន ។

Verse 48. Like one who picks and chooses flowers, a man who has his mind attached to sensual pleasures and is insatiate in them is over powered by Death.

គាថាទី ៤៩: មុនីគប្បីចូលទៅផ្ទះ ដូចជាភមរជាតិមិនធ្វើឱ្យរស និងក្លិនរុក្ខជាតិមានការខូចខាត ក្រេបជញ្ជក់យកតែរស គឺកេសរផ្កា ហើយហោះហើរទៅ យ៉ាងដូច្នោះឯង ។

Verse 49: As the bee collects nectar and flies away without damaging the flower or its colour or its scent, so also, let the sage dwell and act in the village (without affecting the faith and generosity or the wealth of the villagers).

គាថាទី ៥០: បុគ្គលមិនគួរយកពាក្យសម្តីដែលលាមកអាក្រក់របស់ជនដទៃមកទុកនៅក្នុងចិត្តឡើយ មិនគួរជញ្ជឹងចាំមើលកិច្ចការដែលគេធ្វើហើយ និងមិនបានធ្វើហើយរបស់ជនដទៃ គួរតែពិចារណាកិច្ចការរបស់ខ្លួនដែលបានធ្វើរួចហើយ និងមិនទាន់បានធ្វើរួចហើយ ប៉ុណ្ណោះ ។

Verse 50: One should not consider the faults of others, nor their doing or not doing good or bad deeds. One should consider only whether one has done or not done good or bad deeds.

គាថាទី ៥១: បុប្ផជាតិដែលមានពណ៌ស្រស់ល្អ តែមិនមានក្លិនក្រអូប យ៉ាងណាមិញ, វាចាសុភាសិត ជាវាចាដែលមិនមានផលដល់បុគ្គលដែលមិនធ្វើតាម ក៏យ៉ាងនោះដែរ ។

Verse 51. Just as a beautiful flower, lacking in scent, cannot give the wearer the benefit of its scent, so also, the well-preached words of the Buddha cannot benefit one who does not practise the Dhamma.

គាថាទី ៥២: បុប្ផជាតិ ដែលមានពណ៌ស្រស់ល្អ ព្រមទាំងមានក្លិនក្រអូបសាយដល់អ្នកប្រដាប់ យ៉ាងណាមិញ, វាចាដែលជាសុភាសិត ជាវាចាដែលមានប្រយោជន៏ដល់អ្នកដែលបានធ្វើតាមដោយល្អ ក៏យ៉ាងនោះដែរ ។

Verse 52. Just as a flower, beautiful as well as fragrant, will give the wearer the benefit of its scent, so also, the well-preached words of the Buddha will benefit one who practises the Dhamma.

គាថាទី ៥៣: នាយមាលាការ គប្បីធ្វើកម្រងផ្កាឱ្យបានច្រើនអំពីគំនរផ្កា យ៉ាងណាមិញ, បុគ្គលដែលមានសេចក្តីស្លាប់ធម្មតា គប្បីធ្វើកុសលឱ្យបានច្រើន ក៏យ៉ាងនោះដែរ ។

Verse 53. As from a collection of flowers many a garland can be made by an expert florist, so also, much good can be done





(with wealth, out of faith and generosity) by one subject to birth and death.

គាថាទី ៥៤: ក្លិនបុប្ផជាតិក្រអូបរសាត់ទៅច្រាសខ្យល់មិនបានឡើយ ក្លិនខ្លឹមច័ន្ទន៏ ឬក្រស្នា និងក្លិនម្លិះរួត ក៏ក្រអូបទៅច្រាសខ្យល់មិនបានដែរ ក្លិននៃពួកសប្បុរសទាំងឡាយក្រអូបច្រាសខ្យល់បាន ព្រោះសប្បុរសរមែងល្បីខ្ចាវខ្ចរគ្រប់ទិសទីកន្លែងបាន ។

Verse 54. The scent of flowers cannot go against the wind; nor the scent of sandalwood, nor of rhododendron (*tagara*), nor of jasmin (*mallika*); only the reputation of good people can go against the wind. The reputation of the virtuous ones (sappurisa) is wafted abroad in all directions.

គាថាទី ៥៥: ក្លិនគឺសីល ជាធម្មជាតិប្រសើរជាងគន្ធជាតទាំងអស់នេះ គឺ ក្លិន-ខ្លឹមច័ន្ទន៏ ក្លិនក្រស្នា ក្លិនផ្កាឧប្បល ហើយនិងក្លិនម្លិះរួត ។

Verse 55. There are the scents of sandalwood, rhodo- dendron, lotus and jasmin (*mallika*); but the scent of virtue surpasses all scents.

គាថាទី ៥៦: ក្លិនក្រស្នា ក្លិនច័ន្ទន៏ឯណាមួយ ក្លិននេះមានតិចពេកណាស់ ចំណែកក្លិនរបស់អ្នកមានសីលទាំងឡាយ ជាក្លិនដ៏ប្រសើរបំផុតក្រអូបសុស-សាយទៅក្នុងពួកទេវតា និងមនុស្សទាំងឡាយ ។

Verse 56. The scents of rhododendron and of sandal wood are very faint; but the scent (reputation) of the virtuous is the strongest; it spreads even to the abodes of the deva.

គាថាទី ៥៧: មារាធិរាជ មិនអាចរកឃើញនូវគតិរបស់លោកអ្នកដែលដល់ព្រមដោយសីល ជាអ្នករស់នៅដោយសេចក្តីមិនប្រមាទ រួចផុតស្រឡះហើយពីលោភៈទោសៈ និងមោហៈ ព្រោះដឹងដោយប្រពៃទាំងនោះបានឡើយ ។

Verse 57. Māra cannot find the path taken by those who are endowed with virtue, who live mindfully and have been freed from moral defilements by Right Knowledge.

គាថាទី ៥៨-៥៩: ផ្កាឈូកមានក្លិនក្រអូបឈ្ងុយឈ្ងប់ ដុះឡើងក្នុងគំនរសម្រាមដែលគេចាក់ចោលក្បែរផ្លូវធំ ជាផ្កាដែលជាទីពេញចិត្តដល់អ្នកដំណើរយ៉ាងណាមិញ, សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ ទោះបីកើតនៅក្នុងសមាគមនៃពួកជនដែលដូចជាកងសម្រាមក៏ដោយ ក៏នៅតែរុងរឿងលើសបុថុជ្ជនទាំង-ឡាយដែលងងឹតសូន្យឈឹងដោយបញ្ញា ក៏យ៉ាងដូច្នោះឯង ។

Verses 58-59: As a sweet-smelling and beautiful lotus flower may grow upon a heap of rubbish thrown on the highway, so also, out of the rubbish heap of beings may appear a disciple of the Buddha, who with his wisdom shines forth far above the blind (ignorant) worldlings.



# ជំពូកទី ៥: ពាលវគ្គ

## Chapter V: Bāla Vagga–The Fool

គាថាទី ៦០: យប់យូរសម្រាប់អ្នកដែលដេកមិនលក់ យោជន៍ឆ្ងាយដាច់ស្រយាលសម្រាប់អ្នកដែលស្ទើយកម្លាំងហើយ វដ្តសង្សារវែងឆ្ងាយសម្រាប់បុគ្គលពាលទាំងឡាយដែលមិនដឹងច្បាស់នូវព្រះធមិ ។

Verse 60: Long is the night to one who is wakeful; long is (the journey of) one yojana to the traveller who is tired; long is saṁsāra (round of rebirths) to the fool, who is ignorant of the true Dhamma (the Teaching of the Buddha).

គាថាទី ៦១: បើបុគ្គលធ្វើដំណើរទៅ (ទីណា) មិនបានសំឡាញ់ដែលមានគុណធមិប្រសើរជាងខ្លួន ឬស្មើនឹងខ្លួនទេ គប្បីធ្វើដំណើរទៅតែម្នាក់ឯង ឱ្យបានរឹងប៉ឹងល្អ ព្រោះថា ភាពជាមិត្រសំឡាញ់ក្នុងបុគ្គលពាលមិនមានឡើយ ។

Verse 61: If a person seeking a companion cannot find one who is better than or equal to him, let him resolutely go on alone; there can be no companionship with the foolish.

គាថាទី ៦២: ជនពាលតែងក្តៅក្រហល់ក្រហាយថា "បុត្រទាំងឡាយរបស់អញមាន ទ្រព្យសម្បត្តិរបស់អញមាន" តាមការពិត ខ្លួនមិនមែនជារបស់ខ្លួន បុត្រទាំងឡាយនឹងមានមកពីណា ទ្រព្យនឹងមានមកពីណា?

Verse 62. "I have sons, I have wealth"; with this (feeling of attachment) the fool is afflicted. Indeed, he himself is not his own, how can sons and wealth be his?

គាថាទី ៦៣: បុគ្គលណាដឹងខ្លួនឯងថា ជាអ្នកល្ងង់ខ្លៅ បុគ្គលនោះនឹងក្លាយទៅជាបណ្ឌិតបាន ព្រោះការដឹងខ្លួននោះ ឯបុគ្គលណាជាអ្នកល្ងង់ខ្លៅ សម្គាល់ខ្លួនឯងថា ជាបណ្ឌិត បុគ្គលនោះ តថាគតហៅថា ជាអ្នកល្ងង់ខ្លៅ ។

Verse 63. The fool who knows that he is a fool can, for that reason, be a wise man; but the fool who thinks that he is wise is, indeed, called a fool.

គាថាទី ៦៤: ជនពាល ទោះបីចូលទៅអង្គុយជិតជាមួយនឹងបណ្ឌិតអស់មួយជីវិតក៏ដោយ គេក៏មិនដឹងច្បាស់នូវព្រះធម៌ដែរ ប្រៀបដូចជាវែកមិនស្គាល់រសជាតិសម្ល យ៉ាងនោះឯង ។

Verse 64. A fool, even though he is associated with a wise man all his life, does not understand the Dhamma, just as a ladle does not know the taste of soup.

គាថាទី ៦៥: វិញ្ញូជន សូម្បីចូលទៅអង្គុយជិតជាមួយនឹងបណ្ឌិតអស់ពេលខ្លីក៏ដោយ គេនឹងយល់ច្បាស់នូវព្រះធម៌បានយ៉ាងឆាប់រហ័ស ប្រៀបបីដូចជាអណ្តាតស្គាល់រសជាតិនៃសម្ល យ៉ាងដូច្នោះឯង ។

Verse 65. An intelligent man, even though he is associated with a wise man only for a moment, quickly understands the Dhamma, just as the tongue knows the taste of soup.





គាថាទី ៦៦: ជនពាលទាំងឡាយ អាប់ប្រាជ្ញា មានខ្លួនបីដូចជាសត្រូវ ដើរសាងបាបកម្មដែលមានផលក្តៅក្រហាយ ។

Verse 66. With themselves as their own enemies, fools lacking in intelligence, move about doing evil deeds, which bear bitter fruits.

គាថាទី ៦៧: បុគ្គលធ្វើកម្មណាហើយ ក្តៅក្រហាយជាខាងក្រោយ មានមុខពេញដោយទឹកភ្នែក ស្រែកទួញយំ ទទួលនូវផលនៃកម្មណា កម្មដែលធ្វើនោះ មិនល្អសោះឡើយ ។

Verse 67. That deed is not well done, if one has to repent for having done it, and if, with a tearful face, one has to weep as a result of that deed.

គាថាទី ៦៨: បុគ្គលធ្វើកម្មណាហើយ មិនក្តៅក្រហាយជាខាងក្រោយ មានការរំភើតចិត្ត មានចិត្តសប្បាយ សោយនូវផលនៃកម្មណា កម្មដែលធ្វើនោះជាកម្មល្អ ។

Verse 68. That deed is well done if one has not to repent for having done it, and if one is delightful and happy with the result of that deed.

គាថាទី ៦៩: ដរាបណា បាបមិនទាន់ហុចផលឱ្យ ដរាបនោះ បុគ្គលពាលសម្គាល់ថា បាបមានរសជាតិផ្អែមដូចជាទឹកឃ្មុំ ពេលណាបាបឱ្យផល ពេលនោះ ជនពាលនឹងបានជួបប្រទះនូវសេចក្តីទុក្ខ (ដោយពិតប្រាកដ) ។

Verse 69. As long as the evil deed does not bear fruit, the fool thinks it is sweet like honey; but when his evil deed does bear fruit, the fool suffers for it.

គាថាទី ៧០: ជនពាលគប្បីបរិភោគភោជនាហារ ដោយចុងស្បូវភ្លាំងរាល់ៗខែ គេមិនបានដល់នូវចំណែកទី១៦ នៃព្រះអរិយបុគ្គល ដែលលោកមានធម៌កំណត់រាប់បានហើយទាំងឡាយ (តាំងពីសោតាបន្នឡើងទៅ)។

Verse 70. Even though, month after month, the fool (living in austerity) takes his food sparingly with the tip of a grass blade, he is not worth even one-sixteenth part of those who have comprehended the Truth (i.e., the ariyas).

គាថាទី ៧១: ក៏បាបកម្មដែលបុគ្គលបានធ្វើហើយ មិនទាន់ហុចផលឱ្យ ដូចជាទឹកដោះដែលគេរីតក្នុងខណៈនោះ មិនទាន់ប្រែប្រួលទៅ យ៉ាងនោះឯង បាប-កម្មរមែងតាមដុតនូវបុគ្គលពាល ដូចភ្លើងដែលក្តៅងំ យ៉ាងនោះឯង។

Verse 71. An evil deed does not immediately bear fruit, just as the newly-drawn milk does not curdle at once; but it follows the fool burning him like live coal covered with ashes.

គាថាទី ៧២: ចំណេះវិជ្ជាកើតឡើងដល់បុគ្គលពាល ដើម្បីសេចក្តីវិនាស ឥតប្រយោជន៍តែម្យ៉ាងប៉ុណ្ណោះ ចំណេះវិជ្ជានោះ ញ៉ាំងបញ្ញារបស់គេឱ្យធ្លាក់ចុះរមែងកំចាត់បង់នូវចំណែកនៃធម៌ល្អ របស់បុគ្គលពាលនោះចោល។

Verse 72. The skill of a fool can only harm him; it destroys his merit and his wisdom (lit., it severs his head).





គាថាទី ៧៣: ភិក្ខុពាល គប្បីប្រាថ្នាសេចក្តីសរសើរដែលមិនមាន ចង់បានធំលើពួកភិក្ខុទាំងឡាយ ចង់បានឥស្សរភាព នៅក្នុងអាវាសទាំងមូល និងចង់បានការបូជាក្នុងត្រកូលដទៃទៀត។

Verse 73. The foolish bhikkhu desires praise for qualities he does not have, precedence among bhikkhus, authority in the monasteries, and veneration from those unrelated to him.

គាថាទី ៧៤: សេចក្តីត្រិះរិះរមែងកើតមានដល់ភិក្ខុពាលយ៉ាងនេះ គឺ "គ្រហស្ថនិងបព្វជិតទាំងពីរពួក ចូរសម្គាល់នូវកិច្ចការដែលគេធ្វើហើយ ព្រោះអាស្រ័យអាត្មាតែម្នាក់ឯង ចូរនៅក្នុងអំណាចរបស់អាត្មាអញ តែម្យ៉ាងប៉ុណ្ណោះ ក្នុងកិច្ចការណាមួយ ទោះតូចក្តី ធំក្តី" សេចក្តីច្រណែន និងមានះ ការប្រកាន់ខ្លួនរមែងចម្រើនឡើងដល់ (ភិក្ខុពាលនោះ)។

Verse 74. "Let both laymen and bhikkhus think that things are done because of me; let them obey me in all matters, great and small." Such being the thoughts of the fool, his greed and his pride grow.

គាថាទី ៧៥: ក៏បដិបទាដែលអាស្រ័យលាភផ្សេង បដិបទាដែលញ៉ាំងសត្វឱ្យដល់ព្រះនិព្វានផ្សេង (ម្នាក់ម្យ៉ាង) ភិក្ខុជាសាវ័កនៃព្រះពុទ្ធជាម្ចាស់ដឹងនូវហេតុនេះហើយ មិនគួរត្រេកអរនឹងលាភសក្ការៈ គួរតាមចម្រើនវិវេក។

Verse 75. Indeed, the path that leads to worldly gain is one and the Path that leads to Nibbāna is another. Fully comprehending this, the bhikkhu, the disciple of the Buddha, should not take

delight in worldly gain and honour, but devote himself to solitude, detachment and the realization of Nibbāna.

## ជំពូកទី ៦: បណ្ឌិតវគ្គ

## Chapter VI: Paṇḍita Vagga–The Wise

គាថាទី ៧៦: បុគ្គលគប្បីសម្លឹងមើលអ្នកណាម្នាក់ ដែលជាអ្នកមានប្រាជ្ញា និយាយចង្អុលបង្ហាញទោសឱ្យបានឃើញជាក់ច្បាស់ ដូចជាអ្នកបង្ហាញកំណប់ទ្រព្យឱ្យ យ៉ាងនោះឯង គប្បីសេពគប់នឹងអ្នកប្រាជ្ញ ដែលលោកជាបណ្ឌិតនោះ (ព្រោះថា) កាលបើសេពគប់នឹងអ្នកប្រាជ្ញនោះមានតែសេចក្តីល្អ មិនមានសេចក្តីអាក្រក់ឡើយ ។

Verse 76. One should follow a man of wisdom who rebukes one for one's faults, as one would follow a guide to some buried treasure. To one who follows such a wise man, it will be an advantage and not a disadvantage.

គាថាទី ៧៧: អ្នកណាគប្បីឱ្យឱវាទ ទូន្មានប្រៀនប្រដៅ និងហាមប្រាមចាកធម៌របស់អសប្បុរស អ្នកនោះឯងរមែងជាទីស្រឡាញ់របស់ពួកសប្បុរស មិនជាទីស្រឡាញ់របស់ពួកអសប្បុរសទាំងឡាយ ។

Verse 77. The man of wisdom should admonish others; he should give advice and should prevent others from doing





wrong; such a man is held dear by the good; be is disliked only by the bad.

គាថាទី ៧៨: បុគ្គលមិនគួរសេពគប់នឹងបាបមិត្រ មិនគួរសេពគប់នឹងបុរសថោកទាប គួរសេពគប់តែកល្យាណមិត្រ គួរសេពគប់តែនឹងបុរសខ្ពង់ខ្ពស់ ។

Verse 78. One should not associate with bad friends, nor with the vile. One should associate with good friends, and with those who are noble.

គាថាទី ៧៩: បណ្ឌិតជាអ្នកមានធម្មបីតិ (ឆ្អែតក្នុងធម៌) មានចិត្តត្រេកអរហើយ រមែងនៅជាសុខ បណ្ឌិតរមែងត្រេកអរក្នុងធម៌ដែលព្រះអរិយៈបានប្រកាសហើយសព្វៗកាល ។

Verse 79. He who drinks in the Dhamma lives happily with a serene mind; the wise man always takes delight in the Dhamma (*Bodhipakkhiya Dhamma*) expounded by the Noble Ones (*ariyas*).

គាថាទី ៨០: ធម្មតាអ្នកស្រែតែងបាចទឹកបញ្ចូលទៅក្នុងស្រែ ជាងធ្វើព្រួញតែងពត់ព្រួញឱ្យត្រង់ ជាងឈើតែងថាំងឈើឱ្យស្មើ ឯជនជាបណ្ឌិតតែងអប់រំខ្លួន (ឱ្យបានល្អ) ។

Verse 80. Farmers (lit., makers of irrigation canals) channel the water; fletchers straighten the arrow; carpenters work the timber; the Wise tame themselves.

គាថាទី ៨១: ភ្នំថ្មតាន់សុទ្ធរមែងមិនកម្រើកញាប់ញ័រ ព្រោះខ្យល់ យ៉ាងណាមិញ បណ្ឌិតទាំងឡាយ ក៏មិនញាប់ញ័រ ព្រោះការតិះដៀល និងការសរសើរ យ៉ាងដូច្នោះដែរ ។

Verse 81. As a mountain of rock is unshaken by wind, so also, the wise are unperturbed by blame or by praise.

គាថាទី ៨២: អន្លង់ទឹកជ្រៅដែលថ្លាល្អ មិនមានកករល្អក់ យ៉ាងណាមិញ បណ្ឌិតទាំងឡាយបានស្តាប់ព្រះធម៌ហើយ រមែងរីករាយសប្បាយចិត្ត ក៏យ៉ាងដូច្នោះដែរ ។

Verse 82. Like a lake which is deep, clear and calm, the wise after listening to the Teaching (Dhamma) become serene.

គាថាទី ៨៣: សប្បុរសទាំងឡាយមិនជាប់ជំពាក់ក្នុងធម៌ទាំងពួង លោកអ្នកដែលស្ងប់រម្ងាប់ មិនអន្ទះអន្ទែងព្រោះសេចក្តីប្រាថ្នាក្នុងកាម បណ្ឌិតទាំងឡាយ ដែលសេចក្តីសុខ ឬទុក្ខពាល់ត្រូវហើយ ក៏មិនសម្តែងអាការៈឡើងចុះដែរ ។

Verse 83. Indeed, the virtuous give up all (i.e., attachment to the five khandhas, etc.); the virtuous (lit., the tranquil) do not talk with sensual desire; when faced with joy or sorrow, the wise do not show elation or depression.

គាថាទី ៨៤: បណ្ឌិត នឹងមិនធ្វើបាប ព្រោះហេតុនៃខ្លួន នឹងមិនធ្វើបាបព្រោះហេតុនៃអ្នកដទៃ មិនគួរប្រាថ្នាបុត្រ មិនគួរប្រាថ្នាទ្រព្យសម្បត្តិ មិនគួរ





ប្រាថ្នារាជធានី មិនគួរប្រាថ្នាសេចក្តីសម្រេចដើម្បីខ្លួន ព្រោះហេតុដែលមិនប្រកបត្រូវតាមធម៌ បណ្ឌិតនោះគប្បីជាអ្នកមានសីល មានបញ្ញា តាំងនៅក្នុងព្រះធម៌ ។

Verse 84. For his own sake or for the sake of others, he does no evil; nor does he wish for sons and daughters or for wealth or for a kingdom by doing evil; nor does he wish for success by unfair means; such a one is indeed virtuous, wise and just.

គាថាទី ៨៥: បណ្តាមនុស្សទាំងឡាយ មនុស្សដែលបានដល់ត្រើយ គឺ ព្រះនិព្វាននោះមានចំនួនតិចតួចណាស់ ចំណែកឯមនុស្សក្រៅពីនេះ រមែងទៅដល់ត្រើយ គឺសក្កាយទិដ្ឋិតែម្យ៉ាង ។

Verse 85. Few among men reach the other shore (Nibbāna); all the others only run up and down on this shore.

គាថាទី ៨៦: អ្នកណាប្រព្រឹត្តសមគួរដល់ធម៌ ដែលតថាគតបានសម្តែងហើយដោយប្រពៃ អ្នកទាំងនោះនឹងបានដល់នូវត្រើយ គឺព្រះនិព្វាន ឆ្លងផុតពីវាលវដ្តសង្សារ ដែលជាទីតាំងនៃមច្ចុរាជ គឺកិលេសមារ ដែលបុគ្គលឆ្លងបានដោយកម្រ ។

Verse 86. But those who practise according to the well-expounded Dhamma will reach the other shore (Nibbāna), having passed the realm of Death (i.e., saṁsāra), very difficult as it is to cross.

គាថាទី ៨៧-៨៨: បណ្ឌិតលះបង់នូវធម៌ខ្មៅ (ធម៌អាក្រក់) ចោលហើយ ចេញពីអាល័យ អាស្រ័យព្រះនិព្វានដែលគ្មានអាល័យ ហើយគប្បីញ៉ាំងធម៌ស (ធម៌ល្អ) ឱ្យបានចម្រើនឡើង គប្បីលះកាមទាំងឡាយចោលហើយ ជាអ្នកមិនមានគ្រឿងកង្វល់ ប្រាថ្នានូវសេចក្តីត្រេកអរដ៏ក្រៃលែង ក្នុងវិវេកដែលគេត្រេកអរបានដោយកម្រ បណ្ឌិតគប្បីធ្វើខ្លួនឱ្យស្អាតបរិសុទ្ធចាកគ្រឿងសៅហ្មងចិត្តទាំងឡាយ ។

Verse 87 & 88. The man of wisdom, leaving the home of craving and having Nibbāna as his goal, should give up the dark states, evil ways and cultivate pure, good ones. He should seek great delight in solitude, detachment and Nibbāna, which an ordinary man finds so difficult to enjoy. He should also give up sensual pleasures, and clinging to nothing, should cleanse himself of all impurities of the mind.

គាថាទី ៨៩: ជនទាំងឡាយបានអប់រំចិត្តល្អត្រឹមត្រូវហើយ ក្នុងអង្គធម៌ដែលជាគ្រឿងត្រាស់ដឹងទាំងឡាយ (និង) ជនទាំងឡាយមិនប្រកាន់មាំ ត្រេកអរក្នុងការលះចោលនូវការប្រកាន់មាំ ជនទាំងឡាយនោះៗជាអ្នកមិនមានអាសវៈជាអ្នករុងរឿង បរិនិព្វានក្នុងលោក ។

Verse 89. Those, with mind well-developed in the seven Factors of Enlightenment (bojjhaṅga), having rid themselves of all grasping, rejoice in their abandonment of attachment. Such men, with all moral intoxicants eradicated, and powerful (with the light of Arahatta Maggaññāṇa), have realized Nibbāna in this world (i.e., with Khandha aggregates remaining).



# ជំពូកទី ៧: អរហន្តវគ្គ

## Chapter VII: Arahanta Vagga– The Worthy

គាថាទី ៩០: សេចក្តីក្តៅក្រហាយមិនមានដល់អ្នកដែលមានផ្លូវឆ្ងាយបានទៅដល់ហើយ អស់សេចក្តីសោកសៅ រួចផុតអស់ហើយក្នុងធម៌ទាំងពួង លះកិលេសគ្រឿងរួបរឹតបានហើយ ។

Verse 90. For him (an arahat) whose journey is ended, who is free from sorrow and from all (e.g. khandha aggregates), who has destroyed all Ties, there is no more distress.

គាថាទី ៩១: ព្រះខីណាស្រពទាំងឡាយ ជាអ្នកមានសតិតែងចៀសចេញឆ្ងាយ លោកមិនត្រេកអរក្នុងទីនៅអាស្រ័យ លះបង់ចោលនូវអាល័យ គឺការជាប់ជំពាក់បានអស់ហើយ បីដូចជាសត្វហង្សលះបង់ភក់ចោលហើយ ហើរទៅយ៉ាងនោះឯង ។

Verse 91. The mindful strive diligently (in the Tranquillity and Insight Development Practice); they take no delight in the home (i.e., in the life of sensual pleasures); like swans (haṁsa) that forsake the muddy pool, they abandon all home life (i.e., all cravings).

គាថាទី ៩២: ជនទាំងឡាយណា មិនមានការសន្សំទុក ជនទាំងឡាយណាមានភោជនៈបានកំណត់ដឹងហើយ សុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ ជាគោចរ

របស់ជនទាំងឡាយណា គតិគឺដំណើរនៃជនទាំងឡាយនោះៗ កម្រណាស់នឹងដឹងច្បាស់បាន ដូចជាគន្លងនៃពួកសត្វព្ទដ៏អាកាស យ៉ាងនោះឯង ។

Verse 92. Arahats do not hoard (anything); when taking food they reflect well over it (i.e., in accordance with the three parinnas). They have as their object liberation from existence, that is, Nibbāna which is Void and Signless. Their destination, like the course of birds in the air, cannot be traced.

គាថាទី ៩៣: អាសវៈគឺគ្រឿងត្រាំទាំងឡាយរបស់បុគ្គលណាអស់ហើយ បុគ្គលណាមិនអាស្រ័យហើយក្នុងអាហារ និងសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ ជាគោចររបស់បុគ្គលណា គន្លងជើងនៃបុគ្គលនោះៗ កម្រណាស់នឹងដឹងច្បាស់បាន ដូចជាគន្លងពួកសត្វព្ទដ៏អាកាស យ៉ាងនោះឯង ។

Verse 93. The arahat is free from moral intoxicants (āsavas); he is not attached to food. He has as his object liberation from existence, i.e., Nibbāna which is Void and Signless. His path, like that of birds in the air, cannot be traced.

គាថាទី ៩៤: ឥន្ទ្រិយ៍ទាំងឡាយរបស់ភិក្ខុណា ដល់ការស្ងប់រម្ងាប់ហើយ ដូចជាសេះដែលនាយសារថីបានហ្វឹកហាត់ល្អហើយ យ៉ាងនោះឯង សូម្បីពួកទេវតាក៏ញញឹមរាក់ទាក់ចំពោះភិក្ខុអង្គនោះ ដែលជាអ្នកលះមានះចោលហើយ មិនមានអាសវៈ ជាអ្នកមានគោលជំហររឹងប៉ឹង ។

Verse 94. The arahat whose sense-faculties are calm like horses well-tamed by the charioteer, who is free from pride and moral intoxicants - such an arahat is held dear even by the devas.





គាថាទី ៩៥: ភិក្ខុណាមានចិត្តស្មើដោយផែនដី ប្រៀបដូចជាសសរខឿន មានគោលជំហររឹងប៉ឹង មានវត្តប្រតិបត្តិល្អ មានកិលេសដូចជាភក់ទៅប្រាសហើយ ដូចជាទន្លេដែលមិនកករល្អក់ យ៉ាងនោះឯង នឹងមិនសោមនស្ស មិនទោមនស្ស សង្សារវដ្តទាំងឡាយនឹងមិនមានដល់ភិក្ខុដែលមានគោលជំហររឹងប៉ឹង យ៉ាងនោះឡើយ ។

Verse 95. Like the earth, the arahat is patient and is not provoked to respond in anger; like the door-post he is firm; he is unperturbed by the ups and downs of life; he is serene and pure like a lake free from mud. For such an arahat there will be no more rebirth.

គាថាទី ៩៦: ចិត្តស្ងប់ វាចាស្ងប់ និងកាយកម្មក៏ស្ងប់ រមែងមានដល់លោកអ្នកដែលរួចផុតហើយ ព្រោះដឹងដោយប្រពៃ ជាអ្នកស្ងប់រម្ងាប់ មានគោលជំហររឹងប៉ឹង យ៉ាងនោះ ។

Verse 96. An arahat is calm in his mind, calm in his speech, and also in his deed; truly knowing the Dhamma, such an arahat is free from moral defilements and is unpurturbed by the ups and downs of life.

គាថាទី ៩៧: នរជនណាមិនជឿគេដោយងាយ ដឹងនូវព្រះនិព្វានដែលបច្ច័យធ្វើមិនបាន កាត់ទីតចោល មានឱកាសបានកម្ចាត់ចោលហើយ មានសេចក្តីត្រូវការខ្ជាក់ចោលបានហើយ នរជននោះឯង ជាបុរសខ្ពង់ខ្ពស់បំផុត ។

Verse 97. He who is not credulous, who has realized the Unconditioned (Nibbāna), who has cut off the links of the

round of rebirths, who has destroyed all consequences of good and bad deeds, who has discarded all craving, is indeed the noblest of all men (i.e., an arahat).

គាថាទី ៩៨: ព្រះអរហន្តទាំងឡាយ លោកនៅក្នុងទីណាៗ ទោះបីជាផ្ទះក្តី ព្រៃក្តី ទីទាប ឬទីខ្ពស់ក្តី ទីនោះៗសុទ្ធតែជាទីគួរត្រេកអរទាំងអស់ ។

Verse 98. In a village or in a forest, in a valley or on a hill, wherever arahats dwell, that place is delightful.

គាថាទី ៩៩: ព្រៃឈើទាំងឡាយជាព្រៃដែលជាទីសប្បាយ បុគ្គលទាំងឡាយដែលមានរាគៈទៅប្រាសហើយ រមែងត្រេកអរនៅក្នុងព្រៃ ដែលមិនជាទីសប្បាយនៃមហាជន (ព្រោះ) បុគ្គលដែលមានរាគៈទៅប្រាសហើយទាំង-ឡាយនោះជាអ្នកមិនស្វែងរកកាម ជាប្រក្រតី ។

Verse 99. Forests are delightful, but the worldlings find no delight in them; only those who are free from passion will find delight in them, for they do not seek sensual pleasures.

## ជំពូកទី ៨: សហស្សវគ្គ

## Chapter VIII: Sahassa Vagga– Thousands

គាថាទី ១០០: វាចាសូម្បីមានដល់ទៅមួយពាន់ម៉ាត់ក៏ដោយ តែជាវាចាមិនប្រកបដោយបទ ដែលមានប្រយោជន៍ វាចានោះគឺជាវាចាមិនប្រសើរសោះ





ឡើយ បទដែលប្រកបដោយប្រយោជន៍មួយបទដែលបុគ្គលបានស្តាប់ហើយស្ងប់រម្ងាប់បាន បទនោះជាបទប្រសើរជាង ។

Verse 100. Better than a thousand words that are senseless and unconnected with the realization of Nibbāna, is a single word of sense, if on hearing it one is calmed.

គាថាទី ១០១: គាថាសូម្បីមានដល់ទៅមួយពាន់ តែជាគាថាមិនប្រកបដោយបទ ដែលមានប្រយោជន៍ គាថានោះមិនប្រសើរឡើយ គាថាមួយបទដែលបុគ្គលបានស្តាប់ហើយ អាចស្ងប់រម្ងាប់បាន គាថានោះប្រសើរជាង ។

Verse 101. Better than a thousand verses that are senseless and unconnected with the realization of Nibbāna, is a single verse, if on hearing it one is calmed.

គាថាទី ១០២: បុគ្គលណាគប្បីសម្តែងនូវព្រះគាថាដល់ទៅមួយរយ តែមិនប្រកបដោយបទ ដែលមានប្រយោជន៍ បទនៃធម៌មួយបទដែលបុគ្គលស្តាប់ហើយស្ងប់រម្ងាប់បាន បទនៃធម៌នោះប្រសើរជាងគាថាមួយរយរបស់បុគ្គលនោះ ។

Verse 102. Better than the recitation of a hundred verses that are senseless and unconnected with the realization of Nibbāna, is the recitation of a single verse of the Teaching (Dhamma), if on hearing it one is calmed.

គាថាទី ១០៣: បុគ្គលណាគប្បីឈ្នះមនុស្សមួយពាន់គុណនឹងមួយពាន់ (គឺមួយលាន) ក្នុងសមរភូមិ បុគ្គលនោះមិនឈ្មោះថា អ្នកឈ្នះដ៏ប្រសើរក្នុង

សង្គ្រាមបានទេ ចំណែកឯបុគ្គលណាឈ្នះខ្លួនឯងម្នាក់បានហើយ បុគ្គលនោះជាអ្នកដែលឈ្នះដ៏ប្រសើរបំផុត នៅក្នុងសមរភូមិ ។

Verse 103. A man may conquer a million men in battle, but one who conquers himself is, indeed, the greatest of conquerors.

គាថាទី ១០៤-១០៥: ការឈ្នះខ្លួនឯងជាការប្រសើរ ចំណែកឯពួកសត្វក្រៅពីនេះដែលគេបានឈ្នះហើយ មិនប្រសើរឡើយ (ព្រោះថា) កាលបើបុគ្គលអប់រំខ្លួនល្អហើយ មានប្រក្រតីសង្រួមជាប់ជានិច្ច ទេវតា គន្ធព្វ មារ ព្រមទាំងព្រហ្ម គប្បីធ្វើនូវជ័យជំនះរបស់បុគ្គលនោះ ឱ្យបរាជ័យវិញពុំបានឡើយ ។

Verses 104 & 105. It is better indeed, to conquer oneself than to conquer others. Neither a deva, nor a gandhabba, nor Māra together with Brahma can turn into defeat the victory of the man who controls himself.

គាថាទី ១០៦: បុគ្គលណាគប្បីបូជាដោយទ្រព្យមួយពាន់រៀងរាល់ខែ អស់រយៈពេលមួយរយឆ្នាំស្មើៗ ចំណែកឯបុគ្គលបូជាចំពោះអ្នកដែលមានខ្លួនបានអប់រំហើយ សូម្បីម្នាក់ឯងគត់ អស់រយៈពេលមួយភ្លែតក៏ដោយ ការបូជាមួយភ្លែតនោះ ប្រសើរជាងការបូជាអស់រយៈពេលជាងរយឆ្នាំ ការបូជាអស់រយៈពេលមួយរយឆ្នាំនោះនឹងប្រសើរអ្វី ។

Verse 106. Month after month for a hundred years, one may make offerings (to ordinary people) to the value of a thousand *Kahāpanas*; yet if, only for a moment one pays homage to a bhikkhu who has practised Insight Development, this homage





is, indeed, better than a hundred years of making offerings (to ordinary people).

គាថាទី ១០៧: បុគ្គលណាគប្បីបម្រើភ្លើងក្នុងព្រៃអស់ពេលមួយរយឆ្នាំ ចំណែកបុគ្គលបូជាអ្នកដែលមានខ្លួនបានអប់រំហើយ តែម្នាក់គត់ សូម្បីមួយរំពេចក៏ដោយ ការបូជានេះប្រសើរជាងការបូជាមួយរយឆ្នាំនោះទៅទៀត ការបូជាមួយរយឆ្នាំនឹងប្រសើរអ្វី ។

Verse 107. For a hundred years, a man may tend the sacred fire in the forest: yet if, only for a moment, one pays homage to a bhikkhu who has practised Insight Development, this homage is, indeed, better than a hundred years of making sacrifices (in fire-worship).

គាថាទី ១០៨: បុគ្គលអ្នកប្រាថ្នាបុណ្យគប្បីបូជាយញ្ញ និងការបួងសួងណាមួយក្នុងលោកអស់ពេលមួយរយឆ្នាំ ការបូជាទាំងអស់នោះមិនបានស្មើនឹងចំណែកទី៤នៃការអភិវាទឡើយ ព្រោះការអភិវាទ ក្រាបថ្វាយបង្គំក្នុងលោកអ្នកមានដំណើរត្រង់ ជាការបូជាដ៏ប្រសើរបំផុត ។

Verse 108. In this world, one may make sacrificial offerings, great and small, all the year round, in order to gain merit; all these offerings are not worth a quarter of the merit gained by worshipping the Noble Ones (Ariyas) who walk the right path.

គាថាទី ១០៩: ធម៌គឺពរទាំងឡាយ៤ប្រការ គឺអាយុ១ ពណ៌សម្បុរកាយ១ សេចក្ដីសុខ១ កម្លាំងមួយ១ រមែងចម្រើនអស់កាលជានិច្ចដល់អ្នកដែលមាន

សេចក្តីឱនកាយថ្វាយបង្គំដល់ព្រះរតនត្រៃជាប្រក្រតី និងអ្នកដែលមានសេចក្តីគោរពកោតក្រែង ដល់អ្នកដែលមានសេចក្តីចម្រើនដោយគុណ មានសីលគុណជាដើម ឬដែលចម្រើនដោយវ័យគឺចាស់ព្រឹទ្ធាចារ្យ ។

Verse 109. For one who always respects and honours those who are older and more virtuous, four benefits, viz., longevity, beauty, happiness and strength, will increase.

គាថាទី ១១០: បុគ្គលណាជាអ្នកមិនមានសីល មានចិត្តមិនតង់វង្ស ទោះបី-ជារស់នៅបានមួយរយឆ្នាំក៏ដោយ ការរស់នៅមួយថ្ងៃរបស់បុគ្គលអ្នកមានសីល មានឈាន ប្រសើរជាងការរស់នៅរបស់បុគ្គលអ្នករស់នៅមួយរយឆ្នាំទៅទៀត ។

Verse 110. Better than a hundred years in the life of an immoral person who has no control over his senses, is a day in the life of a virtuous person who cultivates Tranquillity and Insight Development Practice.

គាថាទី ១១១: បុគ្គលណាជាអ្នកអាប់ប្រាជ្ញា មានចិត្តមិនតង់វង្ស គប្បីរស់-នៅមួយរយឆ្នាំ ការរស់នៅរបស់បុគ្គលអ្នកមានបញ្ញា មានឈាន ត្រឹមតែមួយថ្ងៃគត់ ប្រសើរជាងការរស់នៅរបស់បុគ្គល អ្នករស់នៅមួយរយឆ្នាំនោះទៅទៀត ។

Verse 111. Better than a hundred years in the life of an ignorant person, who has no control over his senses, is a day in the life of a wise man who cultivates Tranquillity and Insight Development Practice.





គាថាទី ១១២: បុគ្គលណាជាអ្នកខ្ជិលច្រអូស មានសេចក្តីព្យាយាមមិនល្អ គប្បីរស់នៅដល់ទៅមួយរយឆ្នាំ ការរស់នៅមួយថ្ងៃរបស់បុគ្គលអ្នកមានសេចក្តីព្យាយាមខ្ជាប់ខ្ជួន ប្រសើរជាងការរស់នៅរបស់បុគ្គលដែលរស់នៅមួយរយឆ្នាំនោះ ។

Verse 112. Better than a hundred years in the life of a person who is idle and inactive, is a day in the life of one who makes a zealous and strenuous effort (in Tranquillity and Insight Development Practice).

គាថាទី ១១៣: បុគ្គលណាមិនឃើញនូវការកើតឡើង និងការរលត់ គប្បីរស់នៅដល់ទៅមួយរយឆ្នាំ ការរស់មួយថ្ងៃរបស់បុគ្គល ដែលឃើញការកើតឡើង និងការរលត់ទៅ ប្រសើរជាងការរស់នៅរបស់បុគ្គលដែលរស់នៅមួយរយឆ្នាំនោះ ។

Verse 113. Better than a hundred years in the life of a person who does not perceive the arising and the dissolving of the five aggregates (khandhas), is a day in the life of one who perceives the arising and dissolving of the five aggregates.

គាថាទី ១១៤: អ្នកណាមិនឃើញផ្លូវដែលមិនស្លាប់ គប្បីរស់នៅដល់ទៅ១០០ ឆ្នាំ ការរស់នៅមួយថ្ងៃនៃបុគ្គលដែលឃើញផ្លូវដែលមិនស្លាប់ ប្រសើរជាងការរស់នៅមួយរយឆ្នាំរបស់បុគ្គលដែលមិនឃើញផ្លូវដែលមិនស្លាប់នោះ ។

Verse 114. Better than a hundred years in the life of a person who does not perceive the Deathless (Nibbāna), is a day in the life of one who perceives the Deathless (Nibbāna).

គាថាទី ១១៥: បុគ្គលណាមិនឃើញធម៌ដ៏ឧត្តម គប្បីរស់នៅដល់មួយរយឆ្នាំ ការរស់នៅមួយថ្ងៃរបស់បុគ្គលដែលឃើញធម៌ដ៏ឧត្តម ប្រសើរជាងការរស់នៅរបស់បុគ្គលដែលមិនឃើញធម៌ដ៏ឧត្តមនោះ ។

Verse 115. Better than a hundred years in the life of a person who does not comprehend the Noble Dhamma (*Dhamma-muttamaṁ*), is a day in the life of one who comprehends the Noble Dhamma.

## ជំពូកទី ៩: បាបវគ្គ

## Chapter IX: Pāpa Vagga– Evil

គាថាទី ១១៦: បុគ្គលគប្បីរួសរាន់ប្រញាប់ប្រញាល់ក្នុងសេចក្តីល្អ គប្បីហាមប្រាមចិត្តឱ្យផុតពីអំពើអាក្រក់ ព្រោះថា បើបុគ្គលធ្វើសេចក្តីល្អយឺតពេក ចិត្តនឹងត្រេកអរក្នុងសេចក្តីអាក្រក់ ។

Verse 116. One should make haste in doing good deeds; one should restrain one's mind from evil; for the mind of one who is slow in doing good tends to take delight in doing evil.

គាថាទី ១១៧: បើបុគ្គលធ្វើអាក្រក់ មិនគួរធ្វើអំពើអាក្រក់នោះញឹកញាប់ទេ (និង) មិនគួរត្រេកអរក្នុងអំពើអាក្រក់នោះផងដែរ ព្រោះថា ការសន្សំបាបនាំសេចក្តីទុក្ខមកឱ្យ ។





Verse 117. If a man does evil, he should not do it again and again; he should not take delight in it; the accumulation of evil leads to dukkha.

គាថាទី ១១៨: បើបុគ្គលធ្វើបុណ្យ គប្បីធ្វើបុណ្យនោះឱ្យបានញឹកញាប់ (និង) គប្បីធ្វើសេចក្តីត្រេកអរក្នុងបុណ្យនោះផងដែរ ព្រោះថា ការសន្សំនូវបុណ្យតែងបានសេចក្តីសុខ ។

Verse 118. If a man does what is good, he should do it again and again; he should take delight in it; the accumulation of merit leads to happiness.

គាថាទី ១១៩: ដរាបណាអំពើអាក្រក់មិនទាន់ហុចផលឱ្យ ដរាបនោះមនុស្សអាក្រក់ឃើញអំពើអាក្រក់ ថា ល្អ តែពេលណាអំពើអាក្រក់ហុចផលឱ្យ ពេលនោះ មនុស្សអាក្រក់នឹងឃើញអំពើអាក្រក់ ថា អាក្រក់ពិតមែន ។

Verse 119. Even an evil person may still find happiness so long as his evil deed does not bear fruit; but when his evil deed does bear fruit he will meet with evil consequences.

គាថាទី ១២០: ដរាបណាអំពើល្អមិនទាន់ហុចផលឱ្យ ដរាបនោះមនុស្សល្អឃើញអំពើល្អ ថា មិនល្អ តែពេលណាអំពើល្អហុចផលឱ្យ ពេលនោះមនុស្សល្អឃើញអំពើល្អ ថា ល្អពិតមែន ។

Verse 120. Even a good person may still meet with suffering so long as his good deed does not bear fruit: but when it does bear fruit he will enjoy the benefits of his good deed.

គាថាទី ១២១: បុគ្គលមិនគួរមើលងាយបាបថា "បាបមានប្រមាណតិចតួច នឹងមិនឱ្យផល" សូម្បីតែក្អមទឹក (ដែលគេបើកគ្របចំហ) រមែងពេញដោយ ដំណក់ទឹកភ្លៀងដែលស្រក់ធ្លាក់ចុះមក ម្ដងមួយដំណក់ៗបាន យ៉ាងណាមិញ បុគ្គលពាលធ្វើអំពើបាប ទោះបីជាម្ដងបន្តិចៗ ក៏រមែងពេញដោយបាបបាន យ៉ាងដូច្នោះឯង ។

Verse 121. One should not think lightly of doing evil, imagining "A little will not affect me"; just as a water-jar is filled up by falling drops of rain, so also, the fool is filled up with evil, by accumulating it little by little.

គាថាទី ១២២: បុគ្គលមិនគួរមើលងាយបុណ្យថា "បុណ្យមានប្រមាណតិចតួច នឹងមិនឱ្យផល" សូម្បីក្អមទឹក (ដែលគេបើកគ្របចំហ) រមែងពេញដោយ ដំណក់ទឹកភ្លៀងដែលស្រក់ធ្លាក់ចុះមក ម្ដងមួយដំណក់ៗបាន យ៉ាងណាមិញ ធីរជនសន្សំបុណ្យម្ដងបន្តិចៗ ក៏រមែងពេញដោយបុណ្យបាន ក៏យ៉ាងដូច្នោះ ដែរ ។

Verse 122. One should not think lightly of doing good, imagining "A little will not affect me'; just as a water-jar is filled up by falling drops of rain, so also, the wise one is filled up with merit, by accumulating it little by little.

គាថាទី ១២៣: បុគ្គលគប្បីលះបង់នូវអំពើអាក្រក់ទាំងឡាយចោលឱ្យបាន ដូចជាពាណិជដែលមានទ្រព្យច្រើន មានគ្នាតិច គេចចេញឆ្ងាយពីផ្លូវដែលមាន ភ័យ និងដូចជាបុគ្គលដែលចង់បានជីវិត ចៀសវាងនូវថ្នាំពិស យ៉ាងនោះឯង ។





Verse 123. Just as a wealthy merchant with few attendants avoids a dangerous road, just as one who desires to go on living avoids poison, so also, one should avoid evil.

គាថាទី ១២៤: បើដំបៅមិនមានលើបាទដៃទេ បុគ្គលគប្បីកាន់យកថ្នាំពិសនឹង បាទដៃបាន ថ្នាំពិសមិនអាចជ្រាបចូលទៅដល់បាទដៃ ដែលមិនមានដំបៅបាន យ៉ាងណាមិញ បាបក៏មិនមានដល់អ្នកដែលមិនធ្វើ (បាប) ក៏យ៉ាងដូច្នោះដែរ ។

Verse 124. If there is no wound on the hand, one may handle poison; poison does not affect one who has no wound; there can be no evil for one who has no evil intention.

គាថាទី ១២៥: បុគ្គលណាប្រទូសរ៉ាយបៀតបៀន ដល់អ្នកដែលមិនប្រទូសរ៉ាយ ជាអ្នកបរិសុទ្ធល្អ មិនមានកិលេសគ្រឿងកង្វល់ បាបរមែងត្រឡប់មករកបុគ្គល ពាលនោះវិញ ដូចជាធូលីល្អិតៗដែលគេបាចច្រាសខ្យល់ (រមែងរសាត់មករក ខ្លួនវិញ) យ៉ាងដូច្នោះឯង ។

Verse 125. If one wrongs a person who should not be wronged, one who is pure and is free from moral defilements, viz., an arahat, the evil falls back upon that fool, like fine dust thrown against the wind.

គាថាទី ១២៦: ពួកជនខ្លះតែងចូលទៅកាន់គភ៌ ពួកជនដែលមានបាបកម្ម រមែងទៅកាន់នរក ពួកជនដែលមានកម្មជាហេតុនៃសុគតិ រមែងទៅកាន់ សុគតិសួគ៌ ពួកជនដែលមិនមានអាសវក្កិលេសរមែងបរិនិព្វាន ។

Verse 126. Some are reborn as human beings, the wicked are reborn in a place of continuous torment (niraya), the righteous

go to the deva world, and those who are free from moral intoxicants (viz., the arahats) realize Nibbāna.

គាថាទី ១២៧: អ្នកធ្វើបាបកម្ម ទោះបីរត់គេចទៅពួននៅលើអាកាសក្តី នៅនាកណ្តាលមហាសមុទ្រក្តី ចូលទៅពួននៅក្នុងរូងភ្នំក្តី ក៏នៅតែគេចមិនរួចពីបាបកម្មនោះបានឡើយ ព្រោះថា ភូមិប្រទេសដែលបុគ្គលរត់គេចទៅពួនសម្ងំនៅ ដើម្បីឱ្យរួចផុតពីបាបកម្មនោះ ប្រាកដជាមិនមានសោះឡើយ ។

Verse 127. Not in the sky, nor in the middle of the ocean, nor in the cave of a mountain, nor anywhere else, is there a place, where one may escape from the consequences of an evil deed.

គាថាទី ១២៨: បុគ្គលបាប ទោះបីរត់គេចទៅនៅលើអាកាសក្តី នៅនាកណ្តាលមហាសមុទ្រក្តី រត់ចូលទៅនៅក្នុងរូងភ្នំក្តី ក៏មិនអាចនឹងរត់គេចផុតពីមច្ចុរាជគឺសេចក្តីស្លាប់បានដែរ ព្រោះថា ភូមិប្រទេសដែលបុគ្គលស្ថិតនៅហើយ មច្ចុរាជមិនអាចសង្គ្រុបបាននោះ ប្រាកដជាពុំមានសោះឡើយ ។

Verse 128. Not in the sky, nor in the middle of the ocean, nor in the cave of a mountain, nor anywhere else, is there a place where one cannot be oppressed by Death.



# ជំពូកទី ១០: ទណ្ឌវគ្គ

## Chapter X: Daṇḍa Vagga–The Rod or Punishment

គាថាទី ១២៩: សត្វទាំងឡាយ សុទ្ធតែតក់ស្លុតចំពោះអាជ្ញា សុទ្ធតែភ័យខ្លាចចំពោះសេចក្តីស្លាប់គ្រប់ៗគ្នា បុគ្គលធ្វើខ្លួនឱ្យជាឧបមាហើយ មិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើអ្នកដទៃឱ្យប្រហារ (នូវសត្វដទៃ) ឡើយ ។

Verse 129. All are afraid of the stick, all fear death. Putting oneself in another's place, one should not beat or kill others.

គាថាទី ១៣០: សត្វទាំងឡាយសុទ្ធតែតក់ស្លុតចំពោះអាជ្ញាគ្រប់ៗគ្នាទាំងអស់ សត្វទាំងឡាយសុទ្ធតែស្រឡាញ់ជីវិតគ្រប់ៗគ្នាទាំងអស់ បុគ្គលធ្វើខ្លួនឱ្យជាឧបមាហើយ មិនគួរវាយប្រហារដោយខ្លួនឯង មិនគួរប្រើអ្នកដទៃឱ្យវាយប្រហារ (សត្វដទៃ) ឡើយ ។

Verse 130. All are afraid of the stick, all hold their lives dear. Putting oneself in another's place, one should not beat or kill others.

គាថាទី ១៣១: សត្វទាំងឡាយដែលកើតមកហើយ សុទ្ធតែប្រាថ្នាចង់បាននូវសេចក្តីសុខ អ្នកណាស្វែងរកសេចក្តីសុខដើម្បីខ្លួន តែទៅបៀតបៀនដល់អ្នកដទៃដោយអាជ្ញា អ្នកនោះលះលោកនេះទៅហើយ នឹងមិនបាននូវសេចក្តីសុខឡើយ ។

Verse 131. He who seeks his own happiness by oppressing others, who also desire to have happiness, will not find happiness in his next existence.

គាថាទី ១៣២: សត្វទាំងឡាយដែលកើតមកហើយ សុទ្ធតែប្រាថ្នាចង់បាននូវសេចក្តីសុខ អ្នកណាស្វែងរកសេចក្តីសុខដើម្បីខ្លួន មិនបៀតបៀនអ្នកដទៃដោយអាជ្ញា អ្នកនោះលះលោកនេះទៅហើយ រមែងបាននូវសេចក្តីសុខ។

Verse 132. He who seeks his own happiness by not oppressing others, who also desire to have happiness, will find happiness in his next existence.

គាថាទី ១៣៣: អ្នកមិនត្រូវនិយាយពាក្យអាក្រក់នឹងអ្នកណាមួយឡើយ ជនទាំងឡាយត្រូវអ្នកនិយាយស្តីថាឱ្យហើយ គប្បីនិយាយស្តីថាត្រឡប់មករកអ្នកវិញ ព្រោះថា ការនិយាយប្រជែងវាសនាគ្នានាំឱ្យកើតទុក្ខ អាជ្ញាតបត្រូវបានធ្លាក់មករកខ្លួនអ្នកវិញ។

Verse 133. Do not speak harshly to anyone; those who are thus spoken to will retort. Malicious talk is indeed the cause of trouble (dukkha) and retribution will come to you.

គាថាទី ១៣៤: បើសិនជាអ្នកធ្វើខ្លួនមិនឱ្យកម្រើកញាប់ញ័រ ដូចជារគាំងកំបែកដែលគេបោះចោល អ្នកនុ៎ះនឹងជាអ្នកបានដល់នូវព្រះនិព្វាន ការនិយាយប្រ-ជែងវាសនានឹងមិនមានដល់អ្នកឡើយ។

Verse 134. If you can keep yourself calm and quiet like a broken gong which is no longer resonant, you are sure to realize Nibbāna, there will be no harshness in you.





គាថាទី ១៣៥: គង្វាលគោក្បៀងគោទាំងឡាយ ទៅកាន់ទីគោចរដោយអាជ្ញាគឺដំបង ឬរំពាត់ យ៉ាងណាមិញ ជរាគឺសេចក្តីទ្រុឌទ្រោមគ្រាំគ្រា និងមច្ចុរាជគឺសេចក្តីស្លាប់ ក៏ក្បៀងទៅនូវអាយុរបស់សត្វទាំងឡាយ ក៏យ៉ាងនោះឯង។

Verse 135. As with a stick the cowherd drives his cattle to the pasture, so also, Ageing and Death drive the life of beings.

គាថាទី ១៣៦: បុគ្គលពាលគ្មានបញ្ញាកំពុងធ្វើនូវបាបកម្មទាំងឡាយ ក៏នៅតែមិនដឹងខ្លួន គេនឹងក្តៅក្រហាយដូចជាភ្លើងឆេះរោលរាល ព្រោះបាបកម្មទាំងឡាយរបស់ខ្លួន។

Verse 136. A fool while doing evil deeds does not know them as being evil; but that fool suffers for his evil deeds like one who is burnt by fire.

គាថាទី ១៣៧: អ្នកណាប្រទូសរ៉ាយក្នុងជនទាំងឡាយ ដែលមិនប្រទូសរ៉ាយជាអ្នកមិនមានអាជ្ញា ដោយអាជ្ញា រមែងដល់នូវឋានៈ១០យ៉ាងណាមួយ យ៉ាងឆាប់រហ័ស។

Verse 137 He who does harm with weapons to those who are harmless and should not be harmed will soon come to any of these ten evil consequences.

គាថាទី ១៣៨, ១៣៩, ១៤០: បុគ្គលគប្បីដល់នូវវេទនាយ៉ាងធ្ងន់១ សេចក្តីវិនាសទ្រព្យ១ ការបែកធ្លាយនៃរាងកាយ១ អាពាធជាទម្ងន់១ សេចក្តីរាយមាយនៃចិត្ត១ ឧបសគ្គគឺព្រះរាជា១ ការនិយាយមួលបង្កាច់យ៉ាងធ្ងន់១

ការអស់ទៅនៃពួកញាតិ១ ការវិនាសបាត់បង់នូវភោគៈទាំងឡាយ១ម្យ៉ាងទៀត ភ្លើងព្រៃនឹងឆេះផ្ទះរបស់គេ អ្នកនោះជាអ្នកមានបញ្ញាអន់ថយ ព្រោះទម្លាយរាងកាយ រមែងចូលទៅកាន់ឋាននរក។

Verses 138, 139 & 140. He will be subject to severe pain, or impoverishment, or injury to the body (i.e., loss of limbs), or serious illness (e.g., leprosy), or lunacy, or misfortunes following the wrath of the king, or wrongful and serious accusations, or loss of relatives, or destruction of wealth, or the burning down of his houses by fire or by lightning. After the dissolution of his body, the fool will be reborn in the plane of continuous suffering (niraya).

គាថាទី ១៤១: កិរិយាប្រព្រឹត្តភាពជាអ្នកអាក្រាតរាងកាយ១ ជដាគឺផ្នួងសក់តាបស១ ភក់១ ការមិនបរិភោគ១ កិរិយាដេកនៅលើផែនដី១ ការប្រឡាក់ប្រឡូសលាបដោយធូលី១ សេចក្តីព្យាយាមដោយភាពជាអ្នកអង្គុយចោងហោង១ (ទាំងអស់នេះ) ធ្វើសត្វដែលមានសេចក្តីសង្ស័យមិនទាន់បានកន្លងផុតហើយ ឱ្យបរិសុទ្ធពុំបានឡើយ។

Verse 141. Not going naked, nor having matted hair, nor smearing oneself with mud, nor fasting, nor sleeping on bare ground, nor covering oneself with dust, nor striving by squatting can purify a being, who has not yet overcome doubt.

គាថាទី ១៤២: បើបុគ្គលស្អិតស្អាងរាងកាយហើយ តែជាអ្នកដែលស្ងប់រម្ងាប់អប់រំខ្លួនបានល្អហើយ ទៀងទាត់មគ្គផល ជាអ្នកប្រព្រឹត្តប្រសើរ លះចោល





អាជ្ញាក្នុងពួកសត្វដែលមានជីវិតទាំងឡាយបានហើយ បុគ្គលនោះឈ្មោះថាព្រាហ្មណ៍ បុគ្គលនោះឈ្មោះថា សមណៈ បុគ្គលនោះ ឈ្មោះថា ភិក្ខុ។

Verse 142. Though he is gaily decked, if he is calm, free from moral defilements, and has his senses controlled, if he is established in Magga Insight, if he is pure and has laid aside enmity (lit., weapons) towards all beings, he indeed is a brāhmaṇa, a samaṇa, and a bhikkhu.

គាថាទី ១៤៣: បុរសដែលហាមនូវអកុសលវិតក្កៈបានដោយហិរិ មានតិចនាក់ណាស់ក្នុងលោក បុគ្គលណាកំចាត់នូវការដេកលក់ (ប្រញាប់) ក្រោកឡើងដូចជាសេះដែលល្អ ខ្លាចរំពាត់មិនឱ្យប៉ះខ្លួនយ៉ាងនេះឯង។

Verse 143. Rare in this world is the kind of person who out of a sense of shame restrains from doing evil and keeps himself awake like a good horse that gives no cause to be whipped.

គាថាទី ១៤៤: អ្នកទាំងឡាយចូរមានសេចក្តីព្យាយាម មានសេចក្តីតក់ស្លុតដូចជាសេះដែលល្អត្រូវម្ចាស់វាយដោយខ្សែតីហើយ (មានការខ្នះខ្នែងប្រឹងប្រែង) ដូច្នោះឯង អ្នកទាំងឡាយចូរប្រកបព្រមដោយសទ្ធា សីល វិរិយៈសមាធិ និងគុណគ្រឿងវិនិច្ឆ័យធម៌ ជាអ្នកមានវិជ្ជា និងចរណៈបរិបូណ៌ មានសតិគង់វង្ស នឹងលះនូវសេចក្តីទុក្ខ ដែលមានប្រមាណមិនតិចនេះបាន។

Verse 144. Like a good horse stirred at a touch of the whip, be diligent and get alarmed by endless round of rebirths (i.e., saṁsāra). By faith, morality, effort, concentration, discernment of the Dhamma, be endowed with knowledge and practice of

morality, and with mindfulness, leave this immeasurable dukkha (of saṁsāra) behind.

គាថាទី ១៤៥: ធម្មតាអ្នកស្រែតែងបាចទឹកបញ្ចូលទៅក្នុងស្រែ ជាងព្រួញតែងពត់ព្រួញឱ្យត្រង់ ជាងឈើតែងចាំងឈើឱ្យត្រង់ អ្នកមានវត្តប្រតិបត្តិល្អតែងអប់រំខ្លួន។

Verse 145. Farmers channel the water; fletchers straighten the arrows; carpenters work the timber; the wise tame themselves.

## ជំពូកទី ១១: ជរាវគ្គ

## Chapter XI: Jarā Vagga– Old Age

គាថាទី ១៤៦: កាលបើលោកសន្និវាសត្រូវភ្លើងឆេះជាប់ជានិច្ច តើហេតុអ្វីហ្ន៎បានជាពួកនាងទាំងអស់គ្នាមកសប្បាយរីករាយក្អាកក្អាយយ៉ាងនេះ? ពួកនាងទាំងអស់គ្នាត្រូវសេចក្តីងងឹតគ្របសង្កត់ហើយ ចុះហេតុអ្វីបានជាមិនខំស្វែងរកពន្លឺ (សម្រាប់កម្ចាត់នូវសេចក្តីងងឹតនោះចេញ)?។

Verse 146. Why is there laughter? Why is there joy although (the world) is always burning? Shrouded in darkness why not seek the light?





គាថាទី ១៤៧: អត្តភាពរាងកាយ (មនុស្សយើង) មិនមានការតាំងនៅយឺនយូរជាស្ថាពរឡើយ អ្នកចូរពិចារណាមើលនូវអត្តភាពនោះ ដែលកម្មធ្វើឱ្យវិចិត្រហើយ ជាកាយដែលប្រកបដោយផ្លែដំបៅរលួយ ដែលឆ្អឹង៣០០កំណាត់សាងឡើងហើយ ជារបស់ក្តៅក្រហាយកើតទុក្ខច្រើន ដែលពួកមហាជននាំគ្នាគិតដល់ខ្លាំងណាស់។

Verse 147. Look at this dressed up body, a mass of sores, supported (by bones), sickly, a subject of many thoughts (of sensual desire). Indeed, that body is neither permanent nor enduring.

គាថាទី ១៤៨: រូបនេះគ្រាំគ្រាទ្រុឌទ្រោមហើយ ជាទីអាស្រ័យនៅនៃរោគជារបស់ដែលផុយរលួយ កាយរបស់ខ្លួនជារបស់ដែលស្អុយគួរខ្ពើមរអើម នឹងបែកធ្លាយ ព្រោះថាជីវិតមានសេចក្តីស្លាប់នៅទីបំផុត។

Verse 148: This body is worn out-with age, it is the seat of sickness, it is subject to decay. This putrid body disintegrates; life, indeed, ends in death.

គាថាទី ១៤៩: ឆ្អឹងទាំងឡាយឯណាដែលគេចោលដេរដាសហើយ ដូចជាផ្លែឃ្លោកក្នុងសារទះរដូវ មានពណ៌ដូចពណ៌នៃសត្វព្រាប សេចក្តីត្រេកអរអ្វីហ្ន៎ (នឹងកើតមាន) ព្រោះឃើញឆ្អឹងទាំងអស់នោះ?

Verse 149: Like gourds thrown away in autumn are these dove-grey bones; what pleasure is there in seeing them?

គាថាទី ១៥០: សរីរៈនេះដែលកម្មធ្វើឱ្យជានគរនៃឆ្អឹងទាំងឡាយមានសាច់ និងឈាមជាគ្រឿងបូកលាប ជាទីធ្លាក់ចុះនៃជរា មរណៈ ការប្រកាន់ខ្លួន និងការរមិលគុណ ។

Verse 150: This body (lit., the city) is built up with bones which are covered with flesh and blood; within this dwell (lit., are deposited) decay and death, pride and detraction (of others' virtues and reputation).

គាថាទី ១៥១: រាជរថទាំងឡាយដែលវិចិត្រល្អ តែងតែគ្រាំគ្រាទ្រុឌទ្រោមទៅ សូម្បីសរីរៈរាងកាយក៏ដល់នូវការចាស់ជរាគ្រាំគ្រាដូចគ្នាដែរ ចំណែកធម៌របស់សប្បុរសទាំងឡាយមិនដល់នូវការចាស់ជរាគ្រាំគ្រាបានឡើយ ពួកសប្បុរសទាំងឡាយតែងប្រឹក្សានឹងពួកសប្បុរសទាំងឡាយ ។

Verse 151: The much ornamented royal carriages do wear out, the body also grows old, but the Dhamma of the Virtuous does not decay. Thus, indeed, say the Virtuous among themselves.

គាថាទី ១៥២: បុរសអ្នកមានសុតៈតិច គឺបានស្តាប់មកតិចនេះ រមែងទៅដូចជាគោចាស់ដែលគេឈប់ប្រើប្រាស់យ៉ាងនោះឯង សាច់ទាំងឡាយរបស់អប្បសុត្តបុគ្គលនោះនឹងរីកចម្រើន តែបញ្ញារបស់គេគ្មានបានរីកចម្រើនឡើយ ។

Verse 152: This man of little learning grows old like an ox; only his flesh grows but not his wisdom.





គាថាទី ១៥៣: តថាគតកាលកំពុងតែស្វះស្វែងរកជាងធ្វើផ្ទះ ពោលគឺតណ្ហាមិនទាន់បានជួបប្រទះនៅឡើយ បានវិលវល់អន្ទោលទៅកាន់សង្សារវដ្តមានជាតិជាអនេក ការកើតរឿយៗជាទុក្ខ ។

Verse 153: I, who have been seeking the builder of this house (body), failing to attain Enlightenment (*Bodhi nana* or *Sabbannuta nana*) which would enable me to find him, have wandered through innumerable births in *saṁsāra*. To be born again and again is, indeed, *dukkha*!

គាថាទី ១៥៤: នៃជាងធ្វើផ្ទះ! គឺតណ្ហា យើងរកអ្នកឃើញហើយ អ្នកនឹងធ្វើផ្ទះ គឺអត្តភាពរបស់យើងមិនបានទៀតឡើយ បង្កង់គឺកិលេសសេសសល់ទាំងឡាយរបស់អ្នក យើងបានកាច់បាក់អស់ហើយ ដំបូលផ្ទះគឺអវិជ្ជា យើងបានរើចោលអស់ហើយ ចិត្តរបស់យើងបានដល់នូវព្រះនិព្វាន ដែលមានសង្ខារទៅប្រាសហើយ បានដល់ហើយនូវការអស់ទៅនៃតណ្ហាទាំងឡាយ ។

Verse 154: Oh house-builder! You are seen, you shall build no house (for me) again. All your rafters are broken, your roof-tree is destroyed. My mind has reached the unconditioned (i.e., *Nibbāna*); the end of craving (*Arahatta Phala*) has been attained.

គាថាទី ១៥៥: បុគ្គលពាលទាំងឡាយមិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យសម្បត្តិក្នុងពេលដែលខ្លួននៅជាកម្លោះក្រមុំ ហើយនឹងក្តៅក្រហាយសោក

ស្គាយ ដូចជាសត្វក្រៀលចាស់ក្រហល់ក្រហាយក្នុងភក់ដែលគ្មានត្រី យ៉ាងនោះឯង ។

Verse 155: They, who in youth have neither led the life of Purity nor have acquired wealth, waste away in dejection like decrepit herons on a drying pond deplete of fish.

គាថាទី ១៥៦: បុគ្គលពាលទាំងឡាយមិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យសម្បត្តិក្នុងពេលដែលខ្លួននៅជាកម្លោះក្រមុំ ហើយនឹងដេកជញ្ជឹងនឹកគិតដល់ទ្រព្យចាស់ទាំងឡាយ ដូចជាកូនសរដែលគេបាញ់ចេញពីធ្នូ យ៉ាងនោះឯង ។

Verse 156: They, who in youth have neither led the Life of Purity nor have acquired wealth, lie helplessly like arrows that have lost momentum, moaning and sighing after the past.



# ជំពូកទី ១២: អត្តវគ្គ

## Chapter XII: Atta Vagga– The Self

គាថាទី ១៥៧: បើបណ្ឌិតដឹងថាខ្លួនជាទីស្រលាញ់ហើយ ត្រូវតែខំថែរក្សាខ្លួននោះឱ្យបានល្អ ត្រូវតម្កល់ទុកខ្លួនក្នុងវ័យទាំងបីណាមួយ ។

Verse 157: If one knows that one is dear to oneself, one should protect oneself well. During any of the three watches (of life) the wise man should be on guard (against evil).

គាថាទី ១៥៨: បណ្ឌិតគួរតម្កល់ខ្លួនឯងឱ្យតាំងនៅក្នុងគុណដ៏សមគួរជាមុនសិនចាំប្រដៅអ្នកដទៃជាខាងក្រោយ នឹងមិនលំបាក ។

Verse 158: One should first establish oneself in what is proper; then only one should teach others. A wise man should not incur reproach.

គាថាទី ១៥៩: បើបុគ្គលប្រៀនប្រដៅអ្នកដទៃយ៉ាងណា ក៏ត្រូវធ្វើខ្លួនយ៉ាងនោះដែរ បុគ្គលអប់រំខ្លួនឯងបានល្អហើយទើបប្រដៅអ្នកដទៃ លោកថាខ្លួនហ្នឹងហើយដែលបុគ្គលទូន្មានបានដោយកម្រ ។

Verse 159: One should act as one teaches others; only with oneself thoroughly tamed should one tame others. To tame oneself is, indeed, difficult.

គាថាទី ១៦០: ខ្លួនជាទីពឹងរបស់ខ្លួនឯង បុគ្គលដទៃតើអ្នកណាហ្ន៎នឹងជាទីពឹងបាន? បុគ្គលដែលអប់រំខ្លួនបានល្អហើយ នឹងបាននូវទីពឹងដែលគេបានដោយកម្រ ។

Verse 160: One indeed is ones own refuge; how can others be a refuge to one? With oneself thoroughly tamed, one can attain a refuge (i.e., Arahatta Phala), which is so difficult to attain.

គាថាទី ១៦១: បាបដែលខ្លួនបានធ្វើហើយកើតក្នុងខ្លួន មានខ្លួនជាដែនកើត រមែងញាំញីគ្របសង្កត់នូវបុគ្គលអ្នកមានបញ្ញាទន់ខ្សោយ ដូចពេជ្រកាត់កែវ-មុណីដែលកើតពីថ្ម យ៉ាងនោះឯង ។

Verse 161: The evil done by oneself, arising in oneself, and caused by oneself, destroys the foolish one, just as a diamond grinds the rock from which it is formed.

គាថាទី ១៦២: ភាពជាអ្នកទ្រុស្តសីលហួសកម្រិត គ្របសង្កត់ (អត្តភាព) របស់បុគ្គលណា ដូចជាវល្លិជ្រៃរួបរឹតព័ន្ធដើមសាលៈយ៉ាងនោះឯង បុគ្គលនោះឈ្មោះថាធ្វើខ្លួនឱ្យដូចជាចោរដែលប្រាថ្នានឹងធ្វើសេចក្តីវិនាសដល់គេយ៉ាងនោះឯង ។

Verse 162: As the creeper (maluva) strangle the sal tree, so also, a really immoral person (overwhelmed by Craving) does to himself just what his enemy wishes him to do.

គាថាទី ១៦៣: កម្មអាក្រក់និងកម្មឥតប្រយោជន៏ដល់ខ្លួន មនុស្សអាក្រក់ធ្វើបានដោយងាយ កម្មណាជាប្រយោជន៏ផង ល្អផង កម្មនោះឯងគេធ្វើបានដោយកម្រណាស់ ។





Verse 163: It is easy to do things that are bad and unbeneficial to oneself, but it is, indeed, most difficult to do things that are beneficial and good.

គាថាទី ១៦៤: បុគ្គលណាមានបញ្ញាទន់ខ្សោយ អាស្រ័យទិដ្ឋិដ៏អាក្រក់ បដិសេធចោលនូវពាក្យប្រៀនប្រដៅរបស់ព្រះអរិយបុគ្គលទាំងឡាយ ដែលជាព្រះអរ-ហន្តឆ្ងាយចាកពីសឹកសត្រូវ រស់នៅប្រកបដោយធម៌ បុគ្គលនោះកើតមកដើម្បីសម្លាប់ខ្លួនឯង ដូចជាផ្លែឫស្សីកើតមកដើម្បីសម្លាប់ដើមឫស្សីយ៉ាងដូច្នោះឯង ។

Verse 164: The foolish man who, on account of his wrong views, scorns the teaching of homage-worthy Noble Ones (Ariyas) who live according to the Dhamma is like the bamboo which bears fruit for its own destruction.

គាថាទី ១៦៥: បុគ្គលណាធ្វើបាបដោយខ្លួនឯង បុគ្គលនោះរមែងសៅហ្មងដោយខ្លួនឯង បុគ្គលណាមិនធ្វើបាបដោយខ្លួនឯង បុគ្គលនោះនឹងបរិសុទ្ធដោយខ្លួនឯង សេចក្តីបរិសុទ្ធនិងសេចក្តីមិនបរិសុទ្ធជារឿងផ្ទាល់ខ្លួន អ្នកដទៃគប្បីញ៉ាំងអ្នកដទៃឱ្យបរិសុទ្ធពុំបានឡើយ ។

Verse 165: By oneself indeed is evil done and by oneself is one defiled; by oneself is evil not done and by oneself is one purified. Purity and impurity depend entirely on oneself; no one can purify another.

គាថាទី ១៦៦: បុគ្គលមិនគួរញ៉ាំងប្រយោជន៍ខ្លួនឱ្យខូចខាត ព្រោះប្រយោជន៍របស់អ្នកដទៃជាច្រើនឡើយ បានដឹងច្បាស់នូវប្រយោជន៍ខ្លួនហើយ គប្បីខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួន ។

Verse 166: For the sake of another's benefit, however great it may be, do not neglect one's own (moral) benefit. Clearly perceiving one's own benefit one should make every effort to attain it.

## ជំពូកទី ១៣: លោកវគ្គ
## Chapter XIII: Loka Vagga– The World

គាថាទី ១៦៧: បុគ្គលមិនគួរសេពនូវធម៌ដ៏ថោកទាប មិនគួររស់នៅដោយសេចក្ដីប្រមាទ មិនគួរសេពនូវការយល់ខុស មិនគួរជានៅឱ្យចង្អៀតលោកឡើយ ។

Verse 167: Do not follow ignoble ways, do not live in negligence, do not embrace wrong views, do not be the one to prolong saṁsāra (lit., the world).



គាថាធម្មបទ

គាថាទី ១៦៨: បព្វជិតមិនគួរប្រមាទក្នុងបិណ្ឌបាត្រដែលខ្លួនក្រោកឡើងឈរចាំទទួល បុគ្គលគួរប្រព្រឹត្តឱ្យសុចរិត អ្នកប្រព្រឹត្តធម៌ជាប្រក្រតីរមែងនៅជាសុខក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

Verse 168: Do not neglect the duty of going on alms-round; observe proper practice (in going on alms-round). One who observes proper practice lives happily both in this world and in the next.

គាថាទី ១៦៩: បុគ្គលគួរប្រព្រឹត្តធម៌ឱ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះឱ្យទុច្ចរិត អ្នកប្រព្រឹត្តធម៌ជាប្រក្រតីរមែងនៅជាសុខក្នុងលោកនេះ និងលោកខាងមុខ ។

Verse 169: Observe proper practice (in going on alms-round); do not observe improper practice. One who observes proper practice lives happily both in this world and in the next.

គាថាទី ១៧០: ស្ដេចមច្ចុរាជនឹងមិនឃើញនូវបុគ្គលដែលពិចារណាឃើញច្បាស់នូវលោកគឺសង្ខារ ដូចជាបុគ្គលគប្បីឃើញពពុះទឹក (និង) ដូចជាបុគ្គលគប្បីឃើញនូវថ្ងៃបណ្ដើរកូនយ៉ាងនោះឯង ។

Verse 170: If a man looks at the world (i.e., the five khandhas) in the same way as one looks at a bubble or a mirage, the King of Death will not find him.

គាថាទី ១៧១: អ្នកទាំងឡាយចូរមកមើលនូវលោកគឺអត្តភាពនេះ ដែលត្រកាលដូចជារាជ ដែលជាទីជាប់ជំពាក់នៃពួកជនពាលទាំងឡាយ តែមិនជាទីជាប់ជំពាក់នៃជនអ្នកដឹងពិត ។

Verse 171: Come, look at this world (i.e., the five khandhas), which is like an ornamented royal carriage. Fools flounder in this world of the khandhas, but the wise are not attached to it.

គាថាទី ១៧២: អ្នកណាប្រមាទហើយកាលពីពេលមុន តែពេលខាងក្រោយគេមិនប្រមាទ អ្នកនោះនឹងធ្វើលោកនេះឱ្យភ្លឺស្វាងបាន ដូចជាព្រះច័ន្ទរះផុតស្រឡះពីពពក បំភ្លឺលោកឱ្យភ្លឺស្វាងត្រចះត្រចង់យ៉ាងនោះឯង ។

Verse 172: He, who has been formerly unmindful, but is mindful later on, lights up the world with the light of Magga Insight a; does the moon freed from clouds.

គាថាទី ១៧៣: អ្នកណាលះចោលនូវបាបកម្មដែលខ្លួនបានធ្វើរួចហើយដោយកុសល (គឺអរហត្តមគ្គ) បុគ្គលនោះនឹងញុំាងលោកនេះឱ្យភ្លឺស្វាងបាន ដូចជាព្រះច័ន្ទរះផុតស្រឡះពីពពក បំភ្លឺលោកនេះឱ្យភ្លឺស្វាងត្រចះត្រចង់យ៉ាងនោះឯង ។

Verse 173: He who overwhelms with good, the evil that he has done lights up this world (with the light of Magga Insight), as does the moon freed from clouds.





គាថាទី ១៧៤: សត្វលោកនេះដូចជាមនុស្សខ្វាក់ នៅក្នុងលោកនេះមនុស្សតិចនាក់ណាស់នឹងយល់ច្បាស់បាន តិចនាក់ណាស់នឹងបានទៅដល់ឋានសួគ៌ ដូចជាសត្វដែលជាប់លប់របស់នាយព្រាន តិចណាស់នឹងរួចផុតពីលប់បានយ៉ាងនោះឯង ។

Verse 174: Blind are the people of this world: only a few in this world see clearly (with Insight). Just as only a few birds escape from the net, so also, only a few get to the world of the devas, (and Nibbāna).

គាថាទី ១៧៥: ហង្សទាំងឡាយរមែងហើរតាមផ្លូវនៃព្រះអាទិត្យ ឯអ្នកមានឫទ្ធិទាំងឡាយតែងហោះទៅតាមអាកាសដោយឫទ្ធិ អ្នកមានបញ្ញាទាំងឡាយឈ្នះមារព្រមទាំងវាហនៈបានហើយ នឹងចេញចាកលោកបាន ។

Verse 175: Swans travel in the sky; those with supernormal powers travel through space; the wise having conquered Māra together with his army, go out of this world (i.e. realize Nibbāna).

គាថាទី ១៧៦: បាបដែលបុគ្គលអ្នកកន្លងធមិយ៉ាងឯក (គឺលះសច្ចៈ) ចោលជាអ្នកនិយាយកុហក មានបរលោកលះចោលហើយមិនគប្បីធ្វើ មិនមានសោះឡើយ ។

Verse 176: For one who transgresses the Truth, and is given to lying, and who is unconcerned with the life hereafter, there is no evil that he dare not do.

គាថាទី ១៧៧: ពួកមនុស្សអ្នកកំណាញ់នឹងមិនបានទៅកាន់ទេវលោកឡើយ ពួកមនុស្សពាលមិនសរសើរទានឡើយ ឯអ្នកប្រាជ្ញអនុមោទនានូវទាន លោកជាអ្នកមានសេចក្ដីសុខ ព្រោះហេតុដែលបានអនុមោទនាទាននោះឯង។

Verse 177: Indeed, misers do not go to the abode of the devas; fools do not praise charity; but the wise rejoice in charity and so gain happiness in the life hereafter.

គាថាទី ១៧៨: សោតាបត្តិផលប្រសើរជាងឯករាជ្យលើផែនដី ជាងការទៅកាន់ឋានសួគ៌ និងប្រសើរជាងអធិបតីភាពនៅក្នុងលោកទាំងមូល។

Verse 178: Far better than sovereignty over the earth, or far better than going to the abodes of the devas, or far better than ruling supreme over the entire universe, is (the attainment of) Sotāpatti Fruition.

## ជំពូកទី ១៤: ពុទ្ធវគ្គ

## Chapter XIV: Buddha Vagga – The Buddha

គាថាទី ១៧៩: កិលេសជាតមានរាគៈជាដើម ដែលព្រះសម្មាសម្ពុទ្ធអង្គឯណាបានឈ្នះហើយ ព្រះអង្គមិនត្រឡប់ចាញ់វិញ កិលេសតិចតួចក្នុងលោកនឹងទៅរកកិលេសជាត ដែលព្រះសម្មាសម្ពុទ្ធអង្គនោះឈ្នះហើយពុំបានឡើយ ពួក





នាងនឹងនាំព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជាបុគ្គលមានគោចររកទីបំផុតគ្មានមិនមានស្លាកស្នាមដោយស្លាកស្នាមអ្វីបាន?

Verse 179: The Buddha, whose conquest (of moral defilements) is complete, in whom there cannot arise any further defilements in this world, that Buddha of infinite range of wisdom, who is trackless, by what track will you lead him'?

គាថាទី ១៨០: តណ្ហាមានបណ្ដាញជ្រួតជ្រាបចូលទៅក្នុងអារម្មណ៏ផ្សេងៗ មិនមានដល់ព្រះពុទ្ធជាម្ចាស់អង្គឯណា ដើម្បីនាំទៅក្នុងភពណាៗ ពួកនាងនឹងនាំព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជាបុគ្គលមានគោចរ (អារម្មណ៏) រកទីបំផុតគ្មាន មិនមានស្លាកស្នាម ដោយស្លាកស្នាមអ្វីបាន?

Verse 180: The Buddha, in whom there is no craving, which like a net would bring him back to any existence (in saṁsāra), that Buddha of infinite range of wisdom, who is trackless, by what track will you lead him?

គាថាទី ១៨១: ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ជាអ្នកប្រាជ្ញខ្វល់ខ្វាយក្នុងឈាន ត្រេកអរក្នុងធម៌ដែលចូលទៅស្ងប់រម្ងាប់ដោយអំណាចនេក្ខម្មៈ ពួកទេវតានិងមនុស្សទាំងឡាយ តែងតែស្រឡាញ់រាប់អានចំពោះព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គនោះ ជាអ្នកមានសតិ។

Verse 181: The wise who practise jhāna concentration and Insight Meditation take delight in the peace of liberation from sensual pleasures and moral defilements. Such wise and mindful ones, who truly comprehend the Four Noble Truths (i.e., Arahats and Buddhas) are held dear also by the devas.

គាថាទី ១៨២: កិរិយាត្រឡប់បានអត្តភាពជាមនុស្សជាការក្រ ការរស់នៅរបស់សត្វទាំងឡាយជាការលំបាក កិរិយាបានស្តាប់នូវព្រះសទ្ធម្មជាការក្រ ការឧបត្តិឡើងនៃព្រះពុទ្ធទាំងឡាយជាការលំបាក ។

Verse 182: Hard to gain is birth as man; hard is the life of mortals; hard to get is the opportunity of hearing the Ariya Dhamma (Teaching of the Buddhas); hard it is for a Buddha to appear.

គាថាទី ១៨៣: កិរិយាមិនធ្វើនូវបាបទាំងពួង កិរិយាបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ ទាំងនេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

Verse 183: Not to do evil, to cultivate merit, to purify one's mind - this is the Teaching of the Buddhas.

គាថាទី ១៨៤: អំណត់គឺសេចក្តីអត់ធន់ជាតបៈធម៌ដ៏ឧត្តម ព្រះពុទ្ធទ្រង់ត្រាស់ថា "ព្រះនិព្វានជាគុណជាតិដ៏ឧត្តម" អ្នកបួសដែលបៀតបៀនសត្វដទៃ សម្លាប់សត្វដទៃមិនមែនជាបព្វជិត មិនមែនជាសមណៈឡើយ ។

Verse 184: The best moral practice is patience and forbearance; "Nibbāna is Supreme", said the Buddhas. A bhikkhu does not harm others; one who harms others is not a bhikkhu.

គាថាទី ១៨៥: កិរិយាមិនតិះដៀល (អ្នកដទៃ)១ កិរិយាសង្រួមក្នុងបាតិ-មោក្ខ១ ភាវៈដឹងប្រមាណក្នុងភត្តាហារ១ ទីដេកនិងទីអង្គុយដ៏ស្ងាត់១ កិរិយា





បំពេញសេចក្តីព្យាយាមក្នុងអធិចិត្ត១ ទាំងអស់នេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

Verse 185: Not to revile, not to do any harm, to practise restraint according to the Fundamental Instructions for the bhikkhus, to be moderate in taking food, to dwell in a secluded place, to devote oneself to higher concentration - this is the Teaching of the Buddhas.

គាថាទី ១៨៦-១៨៧: សេចក្តីឆ្អែតឆ្អន់ក្នុងកាមទាំងឡាយមិនមាន ព្រោះកហាបណៈធ្លាក់មកបីដូចជាទឹកភ្លៀង កាមទាំងឡាយមានរសជាតិតិចណាស់ តែមានទុក្ខច្រើន បណ្ឌិតបានដឹងច្បាស់យ៉ាងនេះហើយ លោកមិនដល់នូវការត្រេកអរក្នុងកាមទាំងឡាយ សូម្បីជារបស់ដែលជាទិព្វក៏ដោយ ព្រះសាវ័ករបស់ព្រះសម្មាសម្ពុទ្ធជាអ្នកត្រេកអរហើយក្នុងការអស់ទៅនៃតណ្ហា ។

Verses 186 & 187: Not by a shower of coins can sensual desires be satiated; sensual desires give little pleasure and are fraught with evil consequences (dukkha). Knowing this, the wise man, who is the disciple of the Buddha, does not find delight even in the pleasures of the devas, but rejoices in the cessation of craving (i.e. Nibbāna).

គាថាទី ១៨៨: មនុស្សទាំងឡាយមានចំនួនច្រើនត្រូវភ័យគ្របសង្កត់ហើយ តែងយកភ្នំទាំងឡាយខ្លះ ព្រៃឈើទាំងឡាយខ្លះ អារាមដើមឈើដែលជាចេតិយទាំងឡាយខ្លះ ធ្វើជាទីពឹងទីរឮក ។

Verse 188: When threatened with danger, men go to many a refuge, to mountains and forests, to parks and gardens, and to sacred trees.

គាថាទី ១៨៩: ទីពឹងបែបនេះមិនមែនជាទីពឹងដ៏ក្សេម នេះមិនមែនជាទីពឹងដ៏ឧត្តម ព្រោះបុគ្គលអាស្រ័យនូវទីពឹងនុ៎ះហើយ ក៏មិនអាចរួចផុតអំពីសេចក្តីទុក្ខបានឡើយ ។

Verse 189: But such a refuge is not a safe refuge, not the best refuge. One is not liberated from all evil consequences of existence (dukkha) for having come to such a refuge.

គាថាទី ១៩០-១៩១: បុគ្គលណាមួយដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃធ្វើជាទីពឹងជាទីរឭក នឹងឃើញនូវអរិយសច្ចៈទាំង ៤ គឺ: ទុក្ខ ហេតុនាំឱ្យកើតទុក្ខ សេចក្តីរលត់ទុក្ខ និងមគ្គមានអង្គ៨ ដ៏ប្រសើរ ដែលញ៉ាំងសត្វឱ្យដល់នូវសេចក្តីស្ងប់នៃទុក្ខ គឺព្រះនិព្វានដោយបញ្ញាដ៏ប្រពៃ ។

Verses 190 & 191: One, who takes refuge in the Buddha, the Dhamma and the Saṅgha, sees with Magga Insight the Four Noble Truths, viz., Dukkha, the Cause of Dukkha, the Cessation of Dukkha, and the Noble Path of Eight Constituents which leads to the Cessation of Dukkha.

គាថាទី ១៩២: នេះហើយជាទីពឹងដ៏ក្សេម នេះហើយជាទីពឹងដ៏ឧត្តមរបស់បុគ្គលនោះ ព្រោះបុគ្គលអាស្រ័យត្រៃសរណៈទាំងបីនេះជាទីពឹងហើយ នឹងបានរួចផុតអំពីសេចក្តីទុក្ខទាំងពួងបាន ។





Verses 192: This, indeed, is the safe refuge; this is the best refuge. Having come to this refuge, one is liberated from all dukkha.

គាថាទី ១៩៣: បុគ្គលអាជានេយ្យរកបានដោយកម្រ បុរសអាជានេយ្យនោះមិនកើតនៅក្នុងទីទាំងពួងឡើយ បុគ្គលអ្នកមានបញ្ញាកើតនៅក្នុងត្រកូលណាមួយ ត្រកូលនោះនឹងបានដល់នូវសេចក្តីសុខ ។

Verse 193: It is hard to find the noblest of men; he is not born everywhere nor in every clan. To whatever clan such a wise man is born, that clan prospers.

គាថាទី ១៩៤: កិរិយាបានត្រាស់ដឹងនៃព្រះពុទ្ធទាំងឡាយនាំមកនូវសេចក្តីសុខ កិរិយាសម្តែងនូវធម៌របស់សប្បុរសនាំមកនូវសេចក្តីសុខ សេចក្តីព្រម-ព្រៀងគ្នារបស់សង្ឃ ឬពួកក្រុមនាំមកនូវសេចក្តីសុខ សេចក្តីព្យាយាមរបស់អ្នកដែលមានសេចក្តីព្រមព្រៀងគ្នានាំមកនូវសេចក្តីសុខ ។

Verse 194: Happy is the arising of a Buddha; happy is the exposition of the Ariya Dhamma; happy is the harmony amongst the Samgha; happy is the practice of those in harmony.

គាថាទី ១៩៥: អ្នកណាក៏មិនអាចរាប់នូវបុណ្យរបស់អ្នកដែលបូជាដល់បុគ្គលដែលគួរបូជា គឺព្រះពុទ្ធនិងសាវ័ករបស់ព្រះពុទ្ធទាំងឡាយផង ជាអ្នកកន្លងនូវបបញ្ចធម៌គ្រឿងយឺតយូរបានហើយ ជាអ្នកមានសេចក្តីសោកសៅ និងសេចក្តីខ្សឹកខ្សួលអស់ហើយ ។

Verse 195: He pays homage to those who are worthy of veneration, whether they are the Buddhas or their disciples who have overcome obstacles (to Insight Development) and have rid themselves of sorrow and lamentation.

គាថាទី ១៩៦: បុគ្គលដែលបូជានូវបុគ្គលដែលគួរបូជាទាំងនោះ ដែលបាន បរិនិព្វានទៅហើយ ជាអ្នកមិនមានភ័យអំពីទីណា១ ដោយការរាប់វិធីណា មួយក៏ដោយ ថាបុណ្យនេះមានប្រមាណប៉ុណ្ណេះ ។

Verse 196: The merit gained by such a person who pays homage to those who have been freed from moral defilements and have nothing to fear, cannot be measured by anyone, as this much or that much.

## ជំពូកទី ១៥: សុខវគ្គ

## Chapter XV: Sukha Vagga– Happiness

គាថាទី ១៩៧: បណ្តាពួកមនុស្សដែលមានពៀរវេរានឹងគ្នា ពួកយើងឥតមាន ពៀរវេរារស់នៅជាសុខសប្បាយស្រួលហ្ន៎ បណ្តាមនុស្សដែលមានពៀរវេរា នឹងគ្នា ពួកយើងរស់នៅឥតមានពៀរវេរានឹងគ្នា ។

Verse 197: Indeed we live very happily, not hating anyone among those who hate; among men who hate we live without hating anyone.





គាថាទី ១៩៨: បណ្តាពួកមនុស្សដែលមានសេចក្តីក្តៅក្រហាយ ពួកយើងរស់ នៅឥតមានសេចក្តីក្តៅក្រហាយ រស់នៅជាសុខសប្បាយស្រួលហ្ន៎ បណ្តាពួក មនុស្សដែលមានសេចក្តីក្តៅក្រហាយ ពួកយើងរស់នៅឥតមានសេចក្តីក្តៅ-ក្រហាយ ។

Verse 198: Indeed we live very happily, in good health among the ailing; among men who are ailing we live in good health.

គាថាទី ១៩៩: បណ្តាពួកមនុស្សដែលមានសេចក្តីខ្វល់ខ្វាយ ពួកយើងឥតមាន សេចក្តីខ្វល់ខ្វាយ រស់នៅជាសុខសប្បាយស្រួលហ្ន៎ បណ្តាពួកមនុស្សដែលមាន សេចក្តីខ្វល់ខ្វាយ ពួកយើងរស់នៅឥតមានសេចក្តីខ្វល់ខ្វាយ ។

Verse 199: Indeed we live very happily, not striving (for sensual pleasures) among these who strive (for them); among those who strive (for them) we live without striving.

គាថាទី ២០០: កិលេសគ្រឿងកង្វល់ មិនមានដល់យើងទាំងឡាយណា យើង ទាំងឡាយនោះ រស់នៅជាសុខសប្បាយស្រួលហ្ន៎ យើងទាំងឡាយជាអ្នកមាន បីតិជាអាហារ បីដូចទេវតាជាន់អាភស្សរៈយ៉ាងនោះឯង ។

Verse 200: Indeed we live very happily, without any anxiety (i.e., without greed, ill will and ignorance); like the Abhassara brahmas we shall live on delightful satisfaction (pīti) as our food.

គាថាទី ២០១: អ្នកឈ្នះរមែងជួបប្រទះនូវពៀរ អ្នកចាញ់តែងនៅជាទុក្ខ អ្នកលះការឈ្នះចាញ់បានហើយស្ងប់នៅជាសុខ ។

Verse 201: Conquest begets enmity; the conquered live in misery; the peaceful live happily having renounced conquest and defeat.

គាថាទី ២០២: ភ្លើងស្មើដោយរាគៈមិនមានឡើយ កំហុសស្មើដោយទោសៈមិនមានឡើយ សេចក្តីទុក្ខស្មើដោយខន្ធមិនមានឡើយ សុខដទៃក្រៅពីសេចក្តីស្ងប់មិនមានឡើយ ។

Verse 202: There is no fire like passion; there is no evil like hatred; there is no ill like (the burden of) khandhas; there is no bliss that surpasses the Perfect Peace (i.e., Nibbāna).

គាថាទី ២០៣: សេចក្តីស្រេកឃ្លានជាទុក្ខយ៉ាងក្រៃលែង សង្ខារទាំងឡាយមានសភាពជាទុក្ខក្រៃលែង បណ្ឌិតដឹងរឿងនោះច្បាស់លាស់ហើយ (ធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន) ព្រោះព្រះនិព្វានជាបរមសុខ ។

Verse 203: Hunger is the greatest ailment, khandhas are the greatest ill. The wise, knowing them as they really are, realize Nibbāna, the greatest bliss.

គាថាទី ២០៤: ការមិនមានរោគជាលាភយ៉ាងប្រសើរ សេចក្តីសន្តោសតាមមានតាមបានជាទ្រព្យដ៏ប្រសើរ សេចក្តីស្និទ្ធស្នាលនឹងគ្នាជាញាតិដ៏ប្រសើរ ព្រះនិព្វានជាបរមសុខ ។





Verse 204: Health is the greatest gift, contentment is the greatest wealth, a trusted friend is the best relative, Nibbāna is the greatest bliss.

គាថាទី ២០៥: បុគ្គលក្រេបជញ្ជក់នូវរសដែលកើតពីវិវេក និងរសព្រះនិព្វានដែលចូលទៅស្ងប់រម្ងាប់ ក្រេបជញ្ជក់នូវរសបីតិដែលកើតពីធម៌ ជាអ្នកមិនមានសេចក្តីក្រហល់ក្រហាយ មិនមានបាប ។

Verse 205: Having had the taste of solitude and the taste of Perfect Peace of Nibbāna, one who drinks in the joy of the essence of the Dhamma is free from fear and evil.

គាថាទី ២០៦: ការបានឃើញនូវព្រះអរិយបុគ្គលទាំងឡាយជាការប្រពៃ ការរស់នៅជាមួយ (ព្រះអរិយបុគ្គលទាំងនោះ) នាំសេចក្តីសុខមកឱ្យគ្រប់ពេលគ្រប់វេលា បុគ្គលនឹងមានសេចក្តីសុខសប្បាយជានិច្ចនិរន្តរ៍បាន ព្រោះមិនបានជួបប្រទះនូវបុគ្គលពាលទាំងឡាយ ។

Verse 206: It is good to see the Noble Ones (ariyas); to live with them is always a pleasure; not seeing fools is also always a pleasure.

គាថាទី ២០៧: បុគ្គលដែលដើរសមាគមជាមួយនឹងពួកបុគ្គលពាល រមែងសោកសៅអស់កាលជាយូរអង្វែង ការនៅរួមជាមួយនឹងបុគ្គលពាលទាំង-ឡាយជាហេតុនាំឱ្យកើតទុក្ខគ្រប់ពេលគ្រប់វេលា ដូចជាការនៅរួមជាមួយនឹង

ពួកសត្រូវយ៉ាងនោះឯង អ្នកប្រាជ្ញមានការនៅរួមគ្នាជាសុខ បីដូចជាសមាគម នៃពួកញាតិទាំងឡាយយ៉ាងនោះដែរ ។

Verse 207: He who walks in the company of fools has to grieve for a long time. Association with fools is ever painful, as living with an enemy; association with the wise is a pleasure, as living with relatives.

គាថាទី ២០៨: ព្រោះហេតុនោះហើយ អ្នកទាំងឡាយចូរសេពគប់នឹងអ្នកប្រាជ្ញ មានបញ្ញា ជាពហូសូតបុគ្គល ហើយមានប្រក្រតីធ្វើការងារ មានចរិយាវត្ត ប្រសើរ ជាអរិយបុគ្គលមានបញ្ញា ឈ្លាសវាងវៃយ៉ាងនោះឱ្យបានជាប់ បីដូច ជាព្រះច័ន្ទគប់ផ្លូវនៃនក្ខត្តឫក្សយ៉ាងដូច្នោះឯង ។

Verse 208: Therefore one should follow a resolute, intelligent, learned, persevering and dutiful ariya; follow such a virtuous and wise man, as the moon follows the path of the stars.

## ជំពូកទី ១៦ : បិយវគ្គ

## Chapter XVI: Piya Vagga–Affection

គាថាទី ២០៩: បុគ្គលប្រកបខ្លួនក្នុងរឿងដែលមិនគួរប្រកប ហើយមិនប្រកប ខ្លួនក្នុងរឿងដែលគួរប្រកប បោះចោលនូវរបស់ដែលមានប្រយោជន៍ កាន់យក





នូវអារម្មណ៍ដែលជាទីស្រឡាញ់ ប្រាថ្នាចំពោះបុគ្គលដែលតាមប្រកបខ្លួនក្នុង រឿងដែលមិនគួរប្រកប ។

Verse 209: He who does what should not be done and fails to do what should be done, who forsakes the noble aim of life (i. e., Morality, Concentration and Insight) and grasps at sensual pleasure, covets the benefits gained by those who exert themselves (in meditation).

គាថាទី ២១០: បុគ្គលមិនគួរសមាគមជាមួយសត្វនិងសង្ខារទាំងឡាយ ដែល ជាទីស្រឡាញ់ (និង) មិនជាទីស្រឡាញ់ក្នុងពេលណាៗក៏ដោយ ព្រោះថាការ មិនឃើញសត្វនិងសង្ខារដែលជាទីស្រឡាញ់ និងការឃើញសត្វនិងសង្ខារដែល មិនជាទីស្រឡាញ់ ជាហេតុនាំឱ្យកើតទុក្ខ ។

Verse 210: Do not associate with those who are dear, and never with those who are not dear to you; not seeing the dear ones is painful, and seeing those who are not dear to you is also painful.

គាថាទី ២១១: ព្រោះហេតុនោះ បុគ្គលមិនគួរធ្វើសត្វនិងសង្ខារឱ្យជាទីស្រ-ឡាញ់ឡើយ ព្រោះការព្រាត់ប្រាសអំពីសត្វនិងសង្ខារដែលជាទីស្រឡាញ់ ជា ការថោកទាប អារម្មណ៍ដែលជាទីពេញចិត្តនិងមិនជាទីពេញចិត្ត មិនមានដល់ បុគ្គលទាំងឡាយណា បុគ្គលទាំងឡាយនោះក៏មិនមានកិលេសជាគ្រឿងចង រឹតដែរ ។

Verse 211: Therefore, one should hold nothing dear; separation from the loved ones is painful; there are no fetters for those who do not love or hate.

គាថាទី ២១២: សេចក្តីសោកសៅកើតមកពីរបស់ដែលជាទីស្រឡាញ់ ភ័យកើតអំពីរបស់ដែលជាទីស្រឡាញ់ សេចក្តីសោកសៅមិនមានដល់បុគ្គលដែលរួចផុតពីរបស់ដែលជាទីស្រឡាញ់ ភ័យនឹងមានមកពីណាបាន?

Verse 212: Affection begets sorrow, affection begets fear. For him who is free from affection there is no sorrow; how can there be fear for him?

គាថាទី ២១៣: សេចក្តីសោកសៅកើតមកអំពីសេចក្តីស្រឡាញ់ ភ័យកើតមកអំពីស្រឡាញ់ សេចក្តីសោកសៅមិនមានដល់បុគ្គលដែលរួចផុតហើយពីសេចក្តីស្រឡាញ់ ភ័យនឹងមានមកពីណាបាន?

Verse 213: Endearment begets sorrow, endearment begets fear. For him who is free from endearment there is no sorrow; how can there be fear for him?

គាថាទី ២១៤: សេចក្តីសោកសៅកើតមកអំពីសេចក្តីត្រេកត្រអាល ភ័យកើតមកអំពីសេចក្តីត្រេកត្រអាល សេចក្តីសោកសៅមិនមានដល់បុគ្គលដែលរួចផុតហើយពីសេចក្តីត្រេកត្រអាល ភ័យនឹងមានមកពីណាបាន?

Verse 214: Attachment (to sensual pleasures) begets sorrow, attachment begets fear. For him who is free from attachment there is no sorrow; how can there be fear for him?





គាថាទី ២១៥: សេចក្តីសោកសៅកើតមកអំពីកាម ភ័យកើតមកអំពីកាម សេចក្តីសោកសៅមិនមានដល់បុគ្គលដែលរួចផុតហើយអំពីកាម ភ័យនឹងមានមកពីណាបាន?

Verse 215: Lust begets sorrow, lust begets fear. For him who is free from lust there is no sorrow; how can there be fear for him?

គាថាទី ២១៦: សេចក្តីសោកសៅកើតមកអំពីតណ្ហា ភ័យកើតមកអំពីតណ្ហា សេចក្តីសោកសៅមិនមានដល់បុគ្គលដែលបានរួចផុតហើយអំពីតណ្ហា ភ័យនឹងមានមកពីណាបាន?

Verse 216: Craving begets sorrow, craving begets fear. For him who is free from craving there is no sorrow; how can there be fear for him?

គាថាទី ២១៧: នរជនរមែងធ្វើបុគ្គលដែលដល់ព្រមហើយដោយសីល និងទស្សនៈ ជាអ្នកតាំងនៅក្នុងធម៌ មានប្រក្រតីនិយាយពាក្យពិតត្រង់ ធ្វើការងាររបស់ខ្លួនឱ្យជាទីស្រឡាញ់ពេញចិត្ត។

Verse 217: He who is endowed with Virtue, and Insight, who is established in the Dhamma, who has realized the Truth, and performs his own duties, is loved by all men.

គាថាទី ២១៨: បុគ្គលណាមានឆន្ទៈកើតហើយក្នុងព្រះនិព្វានដែលគេនិយាយប្រាប់ពុំបាន គប្បីជាអ្នកមានចិត្ត (មគ្គចិត្ត ផលចិត្ត) ពាល់ត្រូវហើយក្តី ជាអ្នក

មានចិត្តមិនជាប់ជំពាក់ក្នុងកាមទាំងឡាយក្តី តថាគតហៅបុគ្គលនោះថា ជាអ្នកមានក្រសែទៅខាងលើ ។

Verse 218: He who has developed a desire for the Ineffable (i.e., Nibbāna), whose mind reaches the same, and is no longer attached to the sensual world (kāmaloka), is called one who is bound upstream (uddhaṁsoto).

គាថាទី ២១៩: ពួកជនជាញាតិមិត្ត ឬក្លើម្រាក់ជាអ្នកមានចិត្តល្អជាដល់គ្នានឹងគ្នា រមែងមានចិត្តត្រេកអរចំពោះបុរសជាញាតិមិត្តដែលព្រាត់ប្រាសគ្នាអស់កាលជាយូរអង្វែងមកហើយ ដែលបានដល់ហើយនូវសិរីសួស្តី មកពីចម្ងាយ ចាំទទួលគ្នារាក់ទាក់យ៉ាងណាមិញ ។

Verse 219: A man who has long been absent and has returned home safely from a distance is welcomed with joy by relatives, friends and well-wishers on his return.

គាថាទី ២២០: បុណ្យទាំងឡាយក៏រមែងរង់ចាំទទួលជនអ្នកបានធ្វើបុណ្យទុកហើយ លះលោកនេះទៅកាន់លោកខាងនាយ ដូចជាគេរង់ចាំទទួលញាតិមិត្រដែលស្រឡាញ់គ្នា បានមកដល់ហើយយ៉ាងនោះឯង ។

Verse 220: In the same way, his good deeds will receive him who has done good when he goes from this world to the other, as relatives receive a dear one on his return.



# ជំពូកទី ១៧: កោធវគ្គ

## Chapter XVII: Kodha Vagga– Anger

គាថាទី ២២១: បុគ្គលគប្បីលះនូវសេចក្តីក្រោធ គប្បីលះនូវការប្រកាន់ខ្លួន គប្បីកន្លងនូវសំយោជនៈទាំងពួងចោលចេញ សេចក្តីទុក្ខទាំងឡាយនឹងមិនមកតាមបុគ្គលទាំងនោះ ដែលជាអ្នកមិនជាប់ជំពាក់ក្នុងនាមនិងរូប ជាអ្នកមិនមានកិលេសគ្រឿងកង្វល់ ។

Verse 221: Give up anger, abandon conceit, overcome all fetters. Ills of life (dukkha) do not befall one who does not cling to mind and body and is free from moral defilements.

គាថាទី ២២២: នរជនណាហាមនូវសេចក្តីក្រោធ ដែលកើតឡើងហើយបាន ដូចជានាយសារថីបញ្ឈប់រថដែលកំពុងតែឆ្ពោះទៅមុខយ៉ាងនោះឯង តថាគតហៅនរជននោះថា ជាសារថី ជនក្រៅពីនេះគ្រាន់តែជាអ្នកកាន់នូវខ្សែបង្ហៀរប៉ុណ្ណោះឯង ។

Verse 222: He who restrains his rising anger as a skilful charioteer checks a speeding chariot - him I call a true charioteer; other charioteers only hold the reins.

គាថាទី ២២៣: បុគ្គលគប្បីឈ្នះមនុស្សក្រោធខឹងដោយការមិនក្រោធខឹងតប គប្បីឈ្នះមនុស្សមិនល្អដោយសេចក្តីល្អ គប្បីឈ្នះមនុស្សកំណាញ់ស្វិតដោយការឱ្យទាន គប្បីឈ្នះមនុស្សនិយាយពាក្យមិនពិតដោយនិយាយពាក្យពិត ។

Verse 223: Conquer the angry one by not getting angry (i.e., by loving-kindness); conquer the wicked by goodness; conquer the stingy by generosity, and the liar by speaking the truth.

គាថាទី ២២៤: បុគ្គលគប្បីពោលពាក្យពិតត្រង់ កុំគប្បីក្រោធខឹងឡើយ ទោះគេសុំនូវវត្ថុតិចតួចក៏ត្រូវឱ្យវត្ថុតិចតួចទៅគេដែរ បុគ្គលនឹងទៅក្នុងសំណាក់នៃទេវតាទាំងឡាយបាន ក៏ដោយសារឋានៈ៣ យ៉ាងនោះឯង ។

Verse 224. One should speak the truth, one should not yield to anger, one should give when asked even if it is only a little. By means of these three one may go to the world of the devas.

គាថាទី ២២៥: ជនទាំងឡាយណាជាមុនី មិនបៀតបៀនអ្នកដទៃ សង្រួមហើយដោយកាយជាដើមជានិច្ច ជនទាំងឡាយនោះនឹងទៅកាន់ទីស្ថានដែលមិនចេះប្រែប្រួល ដែលជាទីស្ថានមនុស្សទាំងឡាយទៅហើយមិនចេះសោកសៅ ។

Verse 225: The arahats, who do not harm others and are always restrained in their actions, go to the deathless Nibbāna, where there is no sorrow.

គាថាទី ២២៦: អាសវៈទាំងឡាយរបស់បុគ្គលដែលភ្ញាក់ឡើងគ្រប់ពេលវេលាជាអ្នកសិក្សាទាំងយប់ទាំងថ្ងៃ មានចិត្តបង្អោនចូលទៅរកព្រះនិព្វាន នឹងដល់នូវការតាំងនៅពុំបានឡើយ ។

Verse 226: In those who are ever vigilant, who by day and by night train themselves in the three sikkhas (i.e., sīla, samādhi



គាថាធម្មបទ

and paññā), and who have their mind directed towards Nibbāna, moral intoxicants become extinct.

គាថាទី ២២៧: អតុលៈ និន្ទា និងសរសើរនេះជារឿងចាស់មានយូរណាស់មកហើយ រឿងនុ៎ះមិនមែនដូចជាមាននៅក្នុងថ្ងៃនេះក៏ទេ បុគ្គលទាំងឡាយខ្លះនិន្ទាដល់បុគ្គលដែលអង្គុយនៅស្ងៀមក៏មាន ពួកខ្លះនិន្ទាដល់បុគ្គលនិយាយច្រើនក៏មាន ពួកខ្លះនិន្ទាដល់បុគ្គលដែលនិយាយល្មមសមគួរក៏មាន បុគ្គលដែលមិនត្រូវគេនិន្ទាមិនមានក្នុងលោក ។

Verse 227: It is not new, O Atula! It has always been done from ancient times. They blame one who is silent, they blame one who speaks much, they blame one who speaks little. There is no one in this world who is not blamed.

គាថាទី ២២៨: បុគ្គលដែលត្រូវគេនិន្ទាហើយតែម្ខាង ឬគេសរសើរហើយតែម្ខាងមិនដែលមានឡើយក្នុងអតីតកាល នឹងមិនមានក្នុងអនាគតកាលផងមិនមានក្នុងបច្ចុប្បន្នកាលនេះផង ។

Verse 228: There never has been, there never will be, nor is there now, anyone who is always blamed or always praised.

គាថាទី ២២៩-២៣០: បើវិញ្ញូជនពិចារណាជារៀងរាល់ថ្ងៃ ពោលសរសើរនូវបុគ្គលណាដែលជាអ្នកប្រព្រឹត្តមិនឱ្យខាតខ្សែរយៈ ជាអ្នកមានបញ្ញា ជាអ្នកតាំងភ្ជាប់ដោយបញ្ញានិងសីល អ្នកណាហ៊ានសមគួរនឹងនិន្ទាបុគ្គលនោះ ជាអ្នកប្រៀប

ដូចជាដុំមាសជម្ពូនុទ សូម្បីពួកទេវតាក៏សរសើរបុគ្គលនោះដែរ ព្រហ្មក៏សរសើរ
អ្នកនោះដែរ ។

Verses 229 & 230: If the wise praise him day after day, knowing him to be truly faultless, wise and endowed with knowledgc and virtue, who would blame him, who is like a nikkha of pure gold? The devas praise him; he is praised even by the great Brahmas.

គាថាទី ២៣១: បុគ្គលគប្បីរក្សាការកម្រើកនៃកាយ គប្បីជាអ្នកសង្រួមហើយ
ដោយកាយ គប្បីលះកាយទុច្ចរិតចេញ ហើយប្រព្រឹត្តសុចរិតដោយកាយ ។

Verse 231: Guard against evil deeds, control your body. Giving up evil deeds, cultivate good deeds.

គាថាទី ២៣២: បុគ្គលគប្បីរក្សាការកម្រើកនៃវាចា គប្បីជាអ្នកសង្រួមហើយ
ដោយវាចា គប្បីលះវចីទុច្ចរិតចេញ ហើយប្រព្រឹត្តអំពើល្អដោយវាចា ។

Verse 232: Guard against evil speech, control your speech. Giving up evil speech, cultivate good speech.

គាថាទី ២៣៣: បុគ្គលគប្បីរក្សាការកម្រើកនៃចិត្ត គប្បីជាអ្នកសង្រួមហើយ
ដោយចិត្ត គប្បីលះមនោទុច្ចរិត ហើយប្រព្រឹត្តសុចរិតដោយចិត្ត ។

Verse 233: Guard against evil thoughts, control your mind. Giving up evil thoughts, cultivate good thoughts.





គាថាទី ២៣៤: អ្នកមានបញ្ញាទាំងឡាយសង្រួមហើយដោយកាយ មួយ-
ទៀត សង្រួមហើយដោយវាចា អ្នកមានបញ្ញាទាំងឡាយសង្រួមហើយដោយ
ចិត្ត អ្នកមានបញ្ញាទាំងអស់នោះ ឈ្មោះថាជាអ្នកសង្រួមល្អប្រពៃហើយ ។

Verse 234: The wise are controlled in deed, they are controlled in speech, they are controlled in thought. Indeed, they are perfectly self-controlled.

## ជំពូកទី ១៨: មលវគ្គ
## Chapter XVIII: Mala Vagga– Impurities or Taints

គាថាទី ២៣៥: ខ្លួនអ្នកក្នុងកាលឥឡូវនេះជាបុគ្គលប្រៀបដូចស្លឹកឈើទុំមាន
ពណ៌លឿង បុរសជាបម្រើនៃយមរាជគឺមរណៈ ក៏ប្រាកដដល់អ្នកហើយ អ្នក
ជាបុគ្គលស្ថិតនៅក្នុងប្រធាននៃសេចក្តីសាបសូន្យ ស្បៀងគឺកុសលរបស់អ្នក
សោតក៏គ្មាន ។

Verse 235: You are now like a withered leaf; the messengers of death are near you; you are about to set out on a long journey; (yet), you have no provisions (for the journey).

គាថាទី ២៣៦: អ្នកចូរធ្វើនូវទីពឹងនៃខ្លួនចុះ ចូរតាំងព្យាយាមរួតរះ ចូរជា
អ្នកឈ្លាស (កុំជាមនុស្សល្ងង់ខ្លៅឡើយ) អ្នកកាលធ្វើយ៉ាងនេះនឹងជាបុគ្គល

មានមន្ទិល (មានរាគៈជាដើម) ខ្ជាត់ចេញមិនមានគ្រឿងពួនគឺកិលេសហើយ នឹងដល់នូវអរិយភូមិដ៏ជាទិព្វ។

Verse 236: Make a firm support for yourself; hasten to strive hard, and be wise. Having removed impurities and being free from moral defilements you shall enter the abodes of the Ariyas (i.e., Suddhavasa brahma realm).

គាថាទី ២៣៧: ខ្លួនអ្នកក្នុងកាលឥឡូវនេះជាបុគ្គលមានវ័យចូលដល់ជរាហើយ ជាអ្នកជិតនឹងទៅកាន់សំណាក់នៃយមរាជហើយ ទីអាស្រ័យរបស់អ្នកក៏មិនមានទៀត ស្បៀងគឺកុសលរបស់អ្នកសោតក៏គ្មានដែរ។

Verse 237: Now you are of advanced age; you are going to the presence of the King of Death and you cannot stop on the way; (yet) you have no provisions (for the journey).

គាថាទី ២៣៨: អ្នកចូរធ្វើនូវទីពឹងនៃខ្លួនចុះ ចូរតាំងព្យាយាមរួតរះ ចូរជាអ្នកឈ្លាស (កុំជាមនុស្សល្ងង់ខ្លៅឡើយ) អ្នកកាលធ្វើយ៉ាងនេះហើយ នឹងជាមនុស្សមានមន្ទិល (មានរាគៈជាដើម) ខ្ជាត់ចេញមិនមានគ្រឿងពួន គឺកិលេស ហើយនឹងមិនចូលទៅដល់ជាតិនិងជរា តទៅទៀតឡើយ។

Verse 238: Make a firm support for yourself; hasten to strive hard, and be wise. Having removed impurities and being free from moral defilements you will no longer be subject to rebirth and decay.





គាថាទី ២៣៩: អ្នកមានប្រាជ្ញាគួរកម្ចាត់មន្ទិលរបស់ខ្លួនក្នុងខណៈៗ បន្តិចម្តង ៗដោយលំដាប់ទៅ ដូចជាងមាសដែលជម្រះស្នឹមនៃមាសប្រាក់ដូច្នោះឯង។

Verse 239: By degrees, little by little, from moment to moment a wise man removes his own impurities (moral defilements), as a smith removes the dross of silver or gold.

គាថាទី ២៤០: មន្ទិលដែលតាំងឡើងអំពីដែក ចេញមកអំពីដែក ត្រឡប់ស៊ីដែកដដែលនោះវិញយ៉ាងណាមិញ អំពើទាំងឡាយដែលតាំងឡើងខាងក្នុងខ្លួន រមែងដឹកនាំនូវបុគ្គលអ្នកប្រព្រឹត្តកន្លងនូវប្រាជ្ញា ជាគ្រឿងពិចារណានូវបច្ច័យ ហើយបរិភោគប្រើប្រាស់នោះ ឱ្យទៅកាន់ទុគ្គតិភពក៏យ៉ាងនោះឯង។

Verse 240: Just as rust is formed from iron, and corrodes the iron from which it is formed, so also, his own deeds lead the transgressor to a lower plane of existence (duggati).

គាថាទី ២៤១: មន្តទាំងឡាយមានការមិនស្វាធ្យាយជាមន្ទិល ផ្ទះសម្បែងទាំងឡាយមានការមិនតាំងនៅជាស្ថាពរជាមន្ទិល ការខ្ជិលច្រអូសជាមន្ទិលនៃវណ្ណៈគឺពណ៌សម្បុរ សេចក្តីប្រមាទជាមន្ទិលរបស់អ្នករក្សា។

Verse 241: Non-recitation is the taint of learning; nonmaintenance is the taint of houses; indolence is the taint of beauty; unmindfulness is the taint of one who keeps watch.

គាថាទី ២៤២: ការប្រព្រឹត្តទុច្ចរិតជាមន្ទិលរបស់ស្ត្រី សេចក្តីកំណាញ់ជាមន្ទិលរបស់អ្នកឱ្យ បាបធម៌ទាំងឡាយជាមន្ទិលក្នុងលោកនេះ និងលោកខាងមុខ។

Verse 242: Sexual misconduct is the taint of a woman; stinginess is the taint of a giver; evil ways are indeed taints in this world as well as in the next.

គាថាទី ២៤៣: តថាគតនឹងប្រាប់នូវមន្ទិលដែលក្រៃលែងជាងមន្ទិលនោះ អវិជ្ជាគឺជាមន្ទិលដ៏ក្រៃលែង ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយចូរលះនូវមន្ទិលនោះចេញហើយ នឹងជាអ្នកគ្មានមន្ទិល ។

Verse 243: A taint worse than these is ignorance (of the Truth), which is the greatest of taints. O bhikkhus, abandon this taint and be taintless.

គាថាទី ២៤៤: ធម្មតាបុគ្គលដែលមិនមានហិរិ ក្លាហានដូចជាក្អែក មានប្រក្រតីកម្ចាត់គុណអ្នកដទៃ ប្រព្រឹត្តទៅដើម្បីយកមុខមាត់ អួតវាយឫកពារ សៅហ្មងហើយរស់នៅយ៉ាងស្រួល ។

Verse 244: Life is easy for one who is shameless and bold as a crow, who slanders others and is pretentious, aggressive and corrupt.

គាថាទី ២៤៥: អ្នកដែលមានហិរិមានប្រក្រតីស្វែងរកតែកម្មល្អបរិសុទ្ធជានិច្ច មិនរួញរា មិនមែនជាអ្នកក្រអឺតក្រទមវាយឫក មានជីវិតរស់នៅបរិសុទ្ធ យល់ឃើញរស់នៅយ៉ាងលំបាក ។

Verse 245: Life is hard for one with a sense of shame, who always seeks purity, who is free from attachment, who is modest and who sees clearly what is proper livelihood.





គាថាទី ២៤៦-២៤៧: នរជនណាមួយធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះ១ និយាយកុហក១ កាន់យករបស់ដែលគេមិនបានឱ្យក្នុងលោក១ ដល់នូវភរិយាអ្នកដទៃ១ មួយទៀត នរជនណាមួយប្រព្រឹត្តរឿយ ៗនូវការផឹកសុរានិងមេរ័យ អ្នកនោះឈ្មោះថា ជីករំលើងមូលគឺឫសគល់របស់ខ្លួននៅក្នុងលោកនេះតែម្តង ។

Verses 246 & 247: He who destroys life, tells lies, takes what is not given him, commits adultery and takes intoxicating drinks, digs up his own roots even in this very life.

គាថាទី ២៤៨: នែបុរសដ៏ចម្រើន! អ្នកចូរយល់យ៉ាងនេះថា បាបធម៌ទាំង-ឡាយ គឺ: លោភៈ និងទោសៈមិនមែនជាធម៌ដែលអ្នកមិនបានសង្រួមហើយ កុំបៀតបៀនញាំញីរូបអ្នកដើម្បីសេចក្តីទុក្ខអស់កាលជាយូរអង្វែងឡើយ ។

Verse 248: Know this, O man! Not restraining oneself is evil; do not let greed and ill will subject you to prolonged misery.

គាថាទី ២៤៩: ជនតែងឱ្យទានតាមសទ្ធា តាមសេចក្តីជ្រះថ្លា អ្នកណាជាអ្នកខ្ញួរមុខអឹមអៀន ព្រោះទឹកនិងបាយរបស់អ្នកដទៃនោះ ជននោះនឹងមិនបានសម្រេចនូវសមាធិទាំងពេលថ្ងៃទាំងពេលយប់ឡើយ ។

Verse 249: People give according to their faith and their devotion; one who is displeased with others receiving food and drink cannot attain concentration (samādhi) by day or by night.

គាថាទី ២៥០: មង្កុភាពគឺភាពជាអ្នកអៀនខ្មាសនោះ ជនណាមួយបានជីករំលើងឱ្យអស់ឫសគល់ហើយ ដកចេញអស់ហើយ អ្នកនោះឯងនឹងបានសម្រេចនូវសមាធិទាំងពេលថ្ងៃទាំងពេលយប់ ។

Verse 250: He who has this feeling of displeasure cut off, uprooted and removed, will surely attain concentration (samādhi) by day or by night.

គាថាទី ២៥១: ភ្លើងស្មើដោយរាគៈមិនមានឡើយ អ្នកចាប់ភ្ជាប់ឱ្យស្មើនឹងទោសៈមិនមានឡើយ បណ្តាញស្មើដោយមោហៈមិនមាន ស្ទឹងស្មើដោយតណ្ហាមិនមានឡើយ ។

Verse 251: There is no fire like passion, there is no grip like ill will, there is no net like ignorance, there is no river like craving.

គាថាទី ២៥២: ទោសអ្នកដទៃមើលឃើញបានដោយងាយ ឯទោសរបស់ខ្លួនឯងវិញមើលឃើញដោយលំបាក ព្រោះថាបុគ្គលនោះរមែងទម្លាក់ទោសដល់ជនដទៃ ដូចជាគេបាចអង្កាមច្រាសខ្យល់យ៉ាងនោះឯង តែបុគ្គលនោះបិទបាំងទោសរបស់ខ្លួន ( មិនឱ្យអ្នកដទៃឃើញ) ដូចព្រានព្រៃបិទបាំងរាងកាយដោយគ្រឿងបិទបាំងយ៉ាងនោះឯង ។

Verse 252: It is easy to see the faults of others, but difficult to see one's own. A man broadcasts the fault; of others like winnowing chaff in the wind, but hides his own faults as a crafty fowler covers himself.





គាថាទី ២៥៣: អាសវៈទាំងឡាយនឹងចម្រើនឡើងដល់បុគ្គលនោះ ដែលជាអ្នកចាំមើលតែទោសរបស់អ្នកដទៃ ចាំចាប់កំហុសរបស់អ្នកដទៃជានិច្ច បុគ្គលនោះជាអ្នកឃ្លាតចាកឆ្ងាយពីការអស់ទៅនៃអាសវៈ ។

Verse 253: In one who constantly sees the faults of others and is always disparaging them, moral intoxicants (āsavas) increase; he is far from extinction of moral intoxicants (i.e., he is far from attainment of arahatship).

គាថាទី ២៥៤: ស្នាមគំនូសលើអាកាសមិនមាន សមណៈខាងក្រៅមិនមាន ពួកសត្វជាអ្នកត្រេកអរយ៉ាងក្រៃលែងក្នុងធម៌គ្រឿងយឺតយូរ តថាគតទាំងឡាយមិនមានធម៌ដែលជាគ្រឿងយឺតយូរឡើយ ។

Verse 254: In the sky there is no track; outside the Buddha's Teaching there is no ariya bhikkhu (samaṇa). All beings take delight in fetters (i.e., craving, pride and wrong view) that prolong saṁsāra; all the Buddhas are free from these fetters.

គាថាទី ២៥៥: ស្នាមគំនូសលើអាកាសមិនមាន សមណៈខាងក្រៅមិនមាន សង្ខារទាំងឡាយឈ្មោះថាជារបស់ទៀងមិនមាន កិលេសដែលជាគ្រឿងច្របូកច្របល់មិនមានដល់ព្រះពុទ្ធទាំងឡាយឡើយ ។

Verse 255: In the sky there is no track; outside the Buddha's Teaching there is no ariya bhikkhu (samaṇa). There is no conditioned thing that is permanent; all the Buddhas are unperturbed (by craving, pride and wrong view).

# ជំពូកទី ១៩: ធម្មដ្ឋវគ្គ

## Chapter XIX: Dhammaṭṭtha Vagga– The Righteous

គាថាទី ២៥៦: បុគ្គលមិនឈ្មោះថាជាអ្នកតាំងនៅក្នុងធម៌បាន ព្រោះហេតុដែលកាត់សេចក្ដីដោយការមិនត្រូវត្រឹម ចំណែកឯបុគ្គលណាជាបណ្ឌិតវិនិច្ឆ័យរឿងទាំងពីរយ៉ាងគឺៈ រឿងដែលពិតនិងរឿងដែលមិនពិត។

Verse 256: He is not just if he decides a case arbitrarily; the wise man should decide after considering both what is right and what is wrong.

គាថាទី ២៥៧: ជនជាបណ្ឌិតជាអ្នកតាំងនៅក្នុងធម៌បាន ព្រោះហេតុដែលកាត់សេចក្ដីដោយការត្រូវត្រឹម ដោយសេចក្ដីទៀងត្រង់ប្រកបដោយធម៌ តាមសមគួរដល់ (ទោស) បុគ្គលនោះជាអ្នកមានបញ្ញា រក្សាធម៌ តថាគតឱ្យឈ្មោះថាជាអ្នកតាំងនៅក្នុងធម៌។

Verse 257: The wise man who decides not arbitrarily but in accordance with the law is one who safeguards the law; he is to be called one who abides by the law (dhammattho).

គាថាទី ២៥៨: បុគ្គលមិនឈ្មោះថាជាបណ្ឌិត ព្រោះហេតុតែនិយាយស្ដីច្រើន (ចំណែក) អ្នកដែលមានសេចក្ដីក្សេមក្សាន្ត ពុំមានពៀរវេរា ឥតមានភ័យ តថាគតហៅថា "បណ្ឌិត"។





Verse 258: He is not a wise man just because he talks much; only he who is peaceful, free from enmity, and does no harm to others, is to be called 'a wise man'.

គាថាទី ២៥៩: បុគ្គលមិនឈ្មោះថា "ជាអ្នកទ្រទ្រង់ព្រះធម៌" ព្រោះហេតុដែលនិយាយច្រើន ចំណែកឯបុគ្គលណាស្ដាប់ធម៌តិចតួចទេ ហើយឃើញធម៌ដោយនាមកាយ បុគ្គលណាមិនមើលងាយព្រះធម៌ បុគ្គលនោះឯង "ជាអ្នកទ្រទ្រង់ព្រះធម៌"។

Verse 259. He is not "one versed in the Dhamma (Dhamma-dhara)" just because he talks much. He who hears only a little but comprehends the Dhamma, and is not unmindful is, indeed, "one versed in the Dhamma."

គាថាទី ២៦០: បុគ្គលមិនឈ្មោះថាព្រះថេរៈ ព្រោះមានសក់ស្កូវដុះនៅលើសិរសា អ្នកដែលមានវ័យចាស់ហួសទៅហើយ តថាគតឱ្យឈ្មោះថា "ចាស់ទទេៗ"។

Verse 260. He is not a thera just because his head is grey; he who is ripe only in years is called "one grown old in vain."

គាថាទី ២៦១: អ្នកណាមានសច្ចៈធម៌ ការមិនបៀតបៀន ការសង្រួមនិងការអប់រំ បុគ្គលនោះឯងជាអ្នកមានមន្ទិលខ្ជាត់ចេញហើយ ជាអ្នកមានបញ្ញា តថាគតឱ្យឈ្មោះថាព្រះថេរៈ។

Verse 261. Only a wise man who comprehends the Four Noble Truths and the Dhamma, who is harmless and virtuous, who

restrains his senses and has rid himself of moral defilements is indeed called a thera.

គាថាទី ២៦២: បុគ្គលដែលមានចិត្តច្រណែន មានសេចក្តីកំណាញ់ អួតអាង នឹងឈ្មោះថាជាមនុស្សល្អ ព្រោះនិយាយពាក្យពិរោះ ឬ ព្រោះភាពជាអ្នកមានសម្បុរកាយល្អមិនបានឡើយ ។

Verse 262. Not by fine talk, nor by good looks could one be a good-hearted man, if he were envious, miserly and crafty.

គាថាទី ២៦៣: ទោសទាំង ៣ យ៉ាង មានសេចក្តីច្រណែនជាដើម បុគ្គលណាមួយបានដកហើងកាត់ផ្តាច់ ធ្វើឱ្យមានឫសដាច់អស់ហើយ បុគ្គលនោះជាអ្នកមានទោសៈបានខ្ជាត់ចេញហើយ មានបញ្ញាតថាគតឱ្យឈ្មោះថា ជាអ្នកមានរូបល្អ ។

Verse 263. A wise man who has cut off, uprooted and removed these and has rid himself of moral defilements is indeed called a good-hearted man.

គាថាទី ២៦៤: បុគ្គលដែលមិនមានវត្តប្រតិបត្តិ និយាយមិនទៀងត្រង់ មិនឈ្មោះថាសមណៈព្រោះកោរសក់ទេ អ្នកដែលប្រកបដោយសេចក្តីប្រាថ្នា និងការចង់បានមិនចេះអស់ តើនឹងឈ្មោះថា សមណៈយ៉ាងណាបាន?

Verse 264. Not by a shaven head does a man become a samaṇa, if he lacks morality and austere practices and tells lies. How could he who is full of covetousness and greed be a samaṇa?





គាថាទី ២៦៥: អ្នកណាមួយញុំាងបាបតូច ឬធំឱ្យស្ងប់ចុះ ដោយប្រការទាំង-ពួងបាន បុគ្គលនោះ តថាគតឱ្យឈ្មោះថាសមណៈព្រោះញុំាងបាបទាំងពួងឱ្យស្ងប់រម្ងាប់បានហើយ ។

Verse 265. He who has totally subdued all evil, great and small, is called a samana because he has overcome all evil.

គាថាទី ២៦៦: បុគ្គលឈ្មោះថា ជាភិក្ខុព្រោះហេតុតែសុំអ្នកដទៃក៏មិនមែនដែរ បុគ្គលសមាទានធម៌ជាពិសនឹងឈ្មោះថា ជាភិក្ខុព្រោះហេតុប៉ុណ្ណោះក៏មិនមែនដែរ ។

Verse 266. He does not become a bhikkhu merely because he stands at the door for alms. He cannot become a bhikkhu because he acts according to a faith which is not in conformity with the Dhamma.

គាថាទី ២៦៧: ឯបុគ្គលណាក្នុងសាសនានេះលះបុណ្យនិងបាបបានហើយ ជាអ្នកប្រព្រឹត្តប្រសើរ ដើរពិចារណាក្នុងលោក អ្នកនុ៎ះឈ្មោះថាភិក្ខុ ។

Verse 267. In this world, he who lays aside both good and evil, who leads the life of purity, and lives meditating on the khandha aggregates is indeed called a bhikkhu.

គាថាទី ២៦៨-២៦៩: បុគ្គលល្ងង់ខ្លៅមិនដឹងច្បាស់ មិនឈ្មោះថាមុនីព្រោះគ្រាន់តែនៅស្ងៀម ឯបុគ្គលណាជាបណ្ឌិតកាន់យកធម៌ដ៏ប្រសើរ ដូចគេកាន់ជញ្ជីងថ្លឹង លះបាបចោលអស់ បុគ្គលនោះឈ្មោះថាមុនីព្រោះហេតុនោះ អ្នកដែលដឹងខន្ធទាំងពីរក្នុងលោក ឈ្មោះថាមុនីព្រោះហេតុដឹងនោះ ។

Verses 268 & 269: Not by silence does one become a *muni*, if one is dull and ignorant. Like one holding a pair of scales, the wise one takes what is good and rejects what is evil. For this reason he is a *muni*. He who understands both internal and external aggregates is also, for that reason, called a ***muni***.

គាថាទី ២៧០: បុគ្គលមិនឈ្មោះថា អរិយៈព្រោះហេតុដែលបៀតបៀនសត្វទាំងឡាយ បុគ្គលដែលឈ្មោះថា អរិយៈព្រោះហេតុដែលមិនបានបៀតបៀនសត្វទាំងពួង ។

Verse 270: He who harms living beings is, for that reason, not an ariya (a Noble One); he who does not harm any living being is called an ariya.

គាថាទី ២៧១-២៧២: ភិក្ខុដែលមិនទាន់បានដល់នូវការអស់ទៅនៃអាសវៈ កុំទាន់សង្ឃឹមទុកថា អាត្មាអញពាល់ត្រូវនូវនេក្ខម្មសុខដែលបុថុជ្ជនសេពមិនបានហើយ ដោយគុណគឺសីលនិងវត្ត ឬដោយភាពជាអ្នកស្តាប់មកច្រើន ដោយការធ្វើសមាធិ ឬក៏ដោយភាពជាអ្នកនៅក្នុងសេនាសនៈដ៏ស្ងាត់ ។

Verses 271 & 272. Not only by mere moral practice, nor by much learning, nor by acquiring concentration, nor by dwelling in seclusion, nor by assuring oneself, "I enjoy the bliss of Anagami Fruition that is not enjoyed by common worldlings (puthujjanas )," should the bhikkhu, rest content without attaining the extinction of moral intoxicants (āsavas) [i.e., without attaining arahatship].



# ជំពូកទី ២០: មគ្គវគ្គ

## Chapter XX: Magga Vagga– The Path or The Way

គាថាទី ២៧៣: ផ្លូវដែលប្រកបដោយអង្គ ៨ ប្រសើរជាងផ្លូវទាំងឡាយ បទទាំងបួន (អរិយសច្ចៈ) ប្រសើរជាងសច្ចៈទាំងឡាយ វិរាគធម៌ប្រសើរជាងធម៌ទាំងឡាយ ព្រះតថាគត ព្រះអង្គមានព្រះចក្ខុប្រសើរជាងសត្វជើងពីរទាំង-ឡាយ ។

Verse 273. Of paths, the Path of Eight Constituents is the noblest; of truths, the Four Noble Truths are the noblest; of the dhammas, the absence of craving (i.e., Nibbāna) is the noblest; of the two-legged beings, the All-Seeing Buddha is the noblest.

គាថាទី ២៧៤: ផ្លូវនោះប៉ុណ្ណោះឯង ដើម្បីសេចក្តីបរិសុទ្ធនៃញាណទស្សនៈ ផ្លូវផ្សេងក្រៅពីនេះមិនមានឡើយ ព្រោះហេតុនោះ អ្នកទាំងឡាយចូរដើរទៅតាមផ្លូវនុ៎ះចុះ ដែលជាទីញុំាងមារនិងសេនាមារឱ្យវង្វេង ។

Verse 274. This is the only Path, and there is none other for the purity of vision. Follow this Path; it will bewilder Māra.

គាថាទី ២៧៥: អ្នកទាំងឡាយធ្វើដំណើរទៅតាមផ្លូវនុ៎ះហើយ នឹងធ្វើនូវទីបំផុតនៃទុក្ខបាន តថាគតបានស្គាល់ផ្លូវដែលជាទីកម្ចាត់ចេញនូវកូនសរហើយទើបប្រាប់ដល់អ្នកទាំងឡាយ ។

Verse 275. Following this Path, you will make an end of dukkha. Having myself known the Path which can lead to the removal of the thorns of moral defilements, I have shown you the Path.

គាថាទី ២៧៦: អ្នកទាំងឡាយគប្បីធ្វើនូវសេចក្តីព្យាយាមគ្រឿងដុតកំទ្បោចកិលេស (ព្រោះ) ព្រះតថាគតទាំងឡាយគ្រាន់តែជាអ្នកបង្ហាញផ្លូវឱ្យ ជនទាំងឡាយដែលធ្វើដំណើរទៅហើយ ពិចារណាជាប្រក្រតីរមែងរួចផុតពីចំណងរបស់មារបាន។

Verse 276. You yourselves should make the effort; the Tathāgatas (Buddhas) only can show the way. Those who practise the Tranquillity and Insight Meditation are freed from the bond of Māra.

គាថាទី ២៧៧: ពេលណាបណ្ឌិតពិចារណាឃើញច្បាស់ដោយបញ្ញាថា "សង្ខារទាំងឡាយទាំងពួងជារបស់មិនទៀតទាត់" ពេលនោះនឹងនឿយណាយក្នុងសេចក្តីទុក្ខ នុ៎ះហើយគឺជាផ្លូវនៃសេចក្តីបរិសុទ្ធ។

Verse 277. "All conditioned phenomena are impermanent"; when one sees this with Insight-wisdom, one becomes weary of dukkha, (i.e., the khandhas). This is the Path to Purity.

គាថាទី ២៧៨: ពេលណាបណ្ឌិតពិចារណាឃើញច្បាស់ដោយបញ្ញាថា "សង្ខារទាំងឡាយទាំងពួងជាទុក្ខ" ពេលនោះនឹងនឿយណាយក្នុងសេចក្តីទុក្ខ នុ៎ះហើយគឺជាផ្លូវនៃសេចក្តីបរិសុទ្ធ។





Verse 278. "All conditioned phenomena are dukkha"; when one sees this with Insight-wisdom, one becomes weary of dukkha (i. e., the khandhas). This is the Path to Purity.

គាថាទី ២៧៩: ពេលណាបណ្ឌិតពិចារណាឃើញច្បាស់ដោយបញ្ញាថា "ធមិទាំងឡាយទាំងពួងជារបស់អនត្តាមិនមែនខ្លួនប្រាណ" ពេលនោះនឹងនឿយណាយក្នុងសេចក្តីទុក្ខ នុ៎ះហើយគឺជាផ្លូវនៃសេចក្តីបរិសុទ្ធ។

Verse 279. "All phenomena (dhammas) are without Self"; when one sees this with Insight-wisdom, one becomes weary of dukkha (i. e., the khandhas). This is the Path to Purity.

គាថាទី ២៨0: បុគ្គលនៅកម្លោះមានកម្លាំង តែមិនព្យាយាមនៅក្នុងពេលដែលត្រូវព្យាយាម បានចូលដល់ភាពជាអ្នកខ្ជិលច្រអូស មានចិត្តត្រិះរិះធ្លាក់ចុះហើយ ខ្ជិលច្រអូសនឹងមិនបានជួបប្រទះនូវផ្លូវនៃបញ្ញាឡើយ។

Verse 280. The idler who does not strive when he should be striving, who though young and strong is given to idleness, whose thoughts are weak and wandering, will not attain Magga Insight which can only be perceived by wisdom.

គាថាទី ២៨១: បុគ្គលមានប្រក្រតីរក្សាវាចា សង្រួមហើយដោយចិត្ត និងមិនគួរធ្វើអកុសលដោយកាយ គប្បីញុំាងកម្មបថទាំង ៣ ប្រការនេះឱ្យបានបរិសុទ្ធល្អ គប្បីត្រេកអរនឹងផ្លូវដែលអ្នកស្វែងរកគុណបានប្រកាសហើយ។

Verse 281. One should be careful in speech, be well-restrained in mind, and physically, too, one should do no evil. One should purify these three courses of action and accomplish the practice of the Path of Eight Constituents made known by the Buddhas.

គាថាទី ២៨២: បញ្ញាកើតឡើងព្រោះការប្រកបពិត ការអស់នៃបញ្ញាព្រោះការមិនប្រកប បណ្ឌិតស្គាល់ផ្លូវទាំងពីរយ៉ាង (គឺផ្លូវ) នៃសេចក្ដីចម្រើន និងសេចក្ដីវិនាសនោះហើយ គប្បីតម្កល់ខ្លួនដោយហេតុដែលបញ្ញានឹងកើតឡើងបាន ។

Verse 282. Indeed, wisdom is born of meditation; without meditation wisdom is lost. Knowing this twofold path of gain and loss of wisdom, one should conduct oneself so that wisdom may increase.

គាថាទី ២៨៣: អ្នកទាំងឡាយចូរកាត់កិលេសដូចជាដើមឈើ តែកុំនាំគ្នាកាត់ដើមឈើ ព្រោះភ័យរមែងកើតមកពីកិលេសបីដូចជាដើមឈើ ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយចូរកាត់កិលេសដូចជាព្រៃឈើ និងកិលេសដូចជាពួកដើមឈើនៅក្នុងព្រៃចេញ ហើយជាអ្នកមិនមានកិលេស ។

Verse 283. O bhikkhus, cut down the forest of craving, not the real tree; the forest of craving breeds danger (of rebirth). Cut down the forest of craving as well as its undergrowth and be free from craving.

គាថាទី ២៨៤: កិលេសដូចជាដើមឈើដែលនៅក្នុងព្រៃ ទោះបីដូចជាមានតិចតួចក៏ដោយរបស់បុគ្គលមិនទាន់ដាច់ខាតអស់ស្រឡះ ក្នុងពួកនារីទាំងឡាយដរាបណា បុគ្គលនោះប្រៀបបីដូចជាកូនគោដែលនៅបៅដោះ មានចិត្តបដិពទ្ធជាប់ក្នុងមេរបស់វាដរាបនោះដែរ ។



គាថាធម្មបទ

Verse 284. So long as craving of man for woman is not cut down and the slightest trace of it remains, so long is his mind in bondage as the calf is bound to its mother.

គាថាទី ២៨៥: ចូរកាត់ចោលនូវសេចក្ដីស្នេហារបស់ខ្លួនចេញ ដូចជាបុគ្គលដកផ្កាឈូកដែលកើតក្នុងសារទសម័យដោយដៃយ៉ាងនោះឯង ចូរចម្រើនផ្លូវដែលសន្តិតែម្យ៉ាងប៉ុណ្ណោះ ព្រោះនិព្វាន ព្រះសុគតទ្រង់ត្រាស់សម្ដែងទុកហើយ ។

Verse 285. Cut off your craving as one plucks an autumn lily with the hand. Nibbāna has been expounded on by the Buddha; cultivate that Path which leads to it.

គាថាទី ២៨៦: បុគ្គលពាលតែងគិតថា "អាត្មាអញនឹងឈប់នៅអាស្រ័យក្នុងទីស្ថាននេះរហូតអស់រដូវភ្លៀង នឹងនៅសំណាក់ក្នុងទីស្ថាននេះក្នុងរដូវរងា និងរដូវក្ដៅនេះ" គេមិនដឹងសេចក្ដីអន្តរាយ (ដែលកើតមានដល់ខ្លួន) ឡើយ ។

Verse 286. "Here will I live in the rainy season; here will I live in the cold season and the hot season", so imagines the fool, not realizing the danger (of approaching death).

គាថាទី ២៨៧: មច្ចុរាជគឺសេចក្ដីស្លាប់អូសយកបុគ្គលដែលស្រវឹងក្នុងបុត្រ និងបសុសត្វ ជាអ្នកមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗនោះទៅ ដូចជាទឹកជំនន់ដ៏ធំកួចនាំយកអ្នកស្រុកដែលដេកលក់ទៅយ៉ាងនោះឯង ។

Verse 287. The man who dotes on his children and his herds of cattle, whose mind longs for and is attached to sensual pleasures, is carried away by Death even as a sleeping village is swept away by a great flood.

គាថាទី ២៨៨: បណ្ឌិតជ្រាបនូវអំណាចនៃសេចក្តីនេះថា បុត្រទាំងឡាយមានដើម្បីការពារមច្ចុរាជមិនបានឡើយ បិតាក៏ការពារមិនបាន សូម្បីតែពួកមិត្រសំឡាញ់ក៏ការពារមច្ចុរាជមិនបានដូចគ្នាដែរ ។

Verse 288. Not sons, nor parents, nor close relatives can protect one assailed by Death; indeed, neither kith nor kin can give protection.

គាថាទី ២៨៩: បើបុគ្គលត្រូវមច្ចុរាជគ្របសង្កត់ហើយ ការការពារក្នុងពួកញាតិទាំងឡាយមិនមានឡើយ ដូច្នេះហើយគប្បីជាអ្នកសង្រួមក្នុងសីល ហើយប្រញាប់ប្រញាល់ជម្រះផ្លូវទៅកាន់ព្រះនិព្វានឱ្យបានបរិសុទ្ធល្អ ។

Verse 289. Knowing this, the wise man restrained by morality should quickly clear (the obstacles to) the Path leading to Nibbāna.

## ជំពូកទី ២១ : បកិណ្ណកវគ្គ

## Chapter XXI: Pakiṇṇaka Vagga– Miscellaneous

គាថាទី ២៩០: បើបុគ្គលឃើញសេចក្តីសុខដ៏ធំទូលាយ ព្រោះលះបង់សេចក្តីសុខដ៏តូច អ្នកមានបញ្ញាកាលឃើញសេចក្តីសុខដ៏ធំទូលាយ គប្បីលះបង់ចោលនូវសេចក្តីសុខដ៏តូចចេញ( ទើបបានជួបប្រទះនូវសេចក្តីសុខដ៏ធំទូលាយបាន) ។





Verse 290. If by giving up small pleasures great happiness is to be found, the wise should give up small pleasures seeing (the prospect of) greet happiness.

គាថាទី ២៩១: បុគ្គលណាប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ដោយការធ្វើសេចក្តីទុក្ខឱ្យកើតមានដល់អ្នកដទៃ បុគ្គលនោះច្របូកច្របល់ហើយដោយគ្រឿងច្របូកច្របល់គឺពៀរវេរា និងមិនបានរួចផុតអំពីពៀរវេរាឡើយ ។

Verse 291. He who seeks his own happiness by inflicting pain on others, being entangled by bonds of enmity, cannot be free from enmity.

គាថាទី ២៩២: ភិក្ខុលះបង់ចោលនូវកិច្ចដែលខ្លួនត្រូវធ្វើ តែត្រឡប់ជាទៅធ្វើកិច្ចដែលខ្លួនមិនត្រូវធ្វើទៅវិញ អាសវៈទាំងឡាយរមែងចម្រើនដល់ភិក្ខុទាំងឡាយនោះ ដែលជាអ្នកមានមានះ ដូចជាដើមបបុសដែលគេលើកឡើងហើយជាអ្នកប្រមាទ ។

Verse 292 In those who leave undone what should indeed be done but do what should not be done, who are conceited and unmindful, moral intoxicants increase.

គាថាទី ២៩៣: សតិដែលប្រព្រឹត្តទៅក្នុងកាយ ភិក្ខុទាំងឡាយណាបានប្រារព្ធល្អហើយជានិច្ច ភិក្ខុទាំងឡាយនោះមានប្រក្រតីធ្វើជារឿយៗក្នុងកិច្ចដែលគប្បីធ្វើ មិនសេពនូវកិច្ចដែលមិនគប្បីធ្វើ អាសវៈទាំងឡាយរបស់ភិក្ខុទាំងនោះដែលជាអ្នកមានសតិ មានសម្បជញ្ញៈ នឹងតាំងនៅពុំបាន ។

Verse 293. In those who always make a good effort in meditating on the body, who do not do what should not be done but always do what should be done, who are also mindful and endowed with clear comprehension, moral intoxicants come to an end.

គាថាទី ២៩៤: បុគ្គលសម្លាប់តណ្ហាដូចជាមាតាផង សម្លាប់អស្មិមានះដូចជាបិតាផង សម្លាប់សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិដូចជាព្រះរាជាដែលជាក្សត្រទាំងពីរព្រះអង្គផង សម្លាប់អាយតនៈដូចជារដ្ឋ ព្រមទាំងនន្ទិរាគៈដូចជាអ្នករដ្ឋការផង បានអស់ហើយ នឹងកើតជាព្រាហ្មណ៍ មិនមានទុក្ខ ទៅដល់ព្រះនិព្វាន។

Verse 294. Having killed mother (i.e., Craving), father (i.e., Conceit), and the two kings (i.e., Eternity-belief and Annihilation-belief), and having destroyed the kingdom (i.e., the sense bases and sense objects) together with its revenue officer (i.e., attachment), the brāhmana (i.e., the arahat) goes free from dukkha.

គាថាទី ២៩៥: បុគ្គលសម្លាប់តណ្ហាដូចជាមាតាផង សម្លាប់អស្មិមានះដូចជាបិតាផង សម្លាប់សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ដូចជាព្រះរាជាដែលជាព្រាហ្មណ៍ទាំងពីរផង សម្លាប់នីវរណធម៌ទាំង ៥ យ៉ាង មានវិច្ឆិកិច្ឆា ដូចជាផ្លូវដែលសត្វខ្លាដើរទៅហើយ ជាគំរប់ ៥ គឺ សម្លាប់សេចក្ដីសង្ស័យបានអស់ហើយនឹងកើតជាព្រាហ្មណ៍ មិនមានទុក្ខ ទៅដល់ព្រះនិព្វាន។

Verse 295. Having killed mother, father, the two brāhmin kings and having destroyed the hindrances of which the fifth (i.e.,





doubt) is like a tiger-infested journey, the brāhmaṇa (i.e., the arahat) goes free from dukkha.

គាថាទី ២៩៦: សតិរបស់ជនទាំងឡាយណាទៅហើយក្នុងព្រះពុទ្ធជានិច្ច ទាំងយប់ទាំងថ្ងៃ ជនទាំងឡាយនោះឈ្មោះថា ជាសាវ័ករបស់ព្រះសមណគោតម ភ្ញាក់រឭកសព្វៗកាល។

Verse 296. Fully alert and ever vigilant are Gotama Buddha's disciples, who by day and by night are always mindful of the qualities of the Buddha.

គាថាទី ២៩៧: សតិរបស់ជនទាំងឡាយណាទៅហើយក្នុងព្រះធម៌ជានិច្ច ទាំងយប់ទាំងថ្ងៃ ជនទាំងឡាយនោះឈ្មោះថា ជាសាវ័ករបស់ព្រះគោតម ភ្ញាក់រឭកសព្វៗកាល។

Verse 297. Fully alert and ever vigilant are Gotama Buddha's disciples, who by day and by night are always mindful of the qualities of the Dhamma.

គាថាទី ២៩៨: សតិរបស់ជនទាំងឡាយណាទៅហើយក្នុងព្រះសង្ឃជានិច្ច ទាំងយប់ទាំងថ្ងៃ ជនទាំងឡាយនោះឈ្មោះថា ជាសាវ័ករបស់ព្រះគោតម ភ្ញាក់រឭកសព្វៗកាល។

Verse 298. Fully alert and ever vigilant are Gotama Buddha's disciples, who by day and by night are always mindful of the qualities of the Saṁgha.

គាថាទី ២៩៩: សតិរបស់ជនទាំងឡាយណាទៅហើយក្នុងកាយជានិច្ច ទាំងយប់ទាំងថ្ងៃ ជនទាំងឡាយនោះឈ្មោះថា ជាសាវ័ករបស់ព្រះគោតម ភ្ញាក់រឭកសព្វៗកាល ។

Verse 299. Fully alert and ever vigilant are Gotama Buddha's disciples, who by day and by night are always mindful of the component parts of the body.

គាថាទី ៣០០: ចិត្តរបស់ជនទាំងឡាយណាត្រេកអរហើយក្នុងការមិនបៀតបៀនជានិច្ច ទាំងយប់ទាំងថ្ងៃ ជនទាំងឡាយនោះឈ្មោះថា ជាសាវ័ករបស់ព្រះគោតម ភ្ញាក់រឭកសព្វៗកាល ។

Verse 300. Fully alert and ever vigilant are Gotama Buddha's disciples, whose mind by day and by night always takes delight in being compassionate (lit., harmless).

គាថាទី ៣០១: ចិត្តរបស់ជនទាំងឡាយណាត្រេកអរហើយក្នុងភាវនាជានិច្ច ទាំងយប់ទាំងថ្ងៃ ជនទាំងឡាយនោះឈ្មោះថា ជាសាវ័ករបស់ព្រះគោតម ភ្ញាក់រឭកសព្វៗកាល ។

Verse 301. Fully alert and ever vigilant are Gotama Buddha's disciples, whose mind by day and by night always takes delight in the cultivation (of good-will towards all).

គាថាទី ៣០២: ការបួសជាការក្រលំបាក ការត្រេកអរក្នុងធម៌ក៏ជាការក្រលំបាក ផ្ទះសម្បែងដែលថែរក្សាមិនបានល្អនាំឱ្យកើតទុក្ខ ការនៅរួមជាមួយបុគ្គលដែលស្មើគ្នានាំឱ្យកើតទុក្ខ បុគ្គលដែលដើរផ្លូវឆ្ងាយ គឺវដ្ដៈ ត្រូវសេចក្ដីទុក្ខ





តាមជាប់ទៅផង ព្រោះហេតុនោះ បុគ្គលមិនគួរជាអ្នកដើរផ្លូវឆ្ងាយ មិនគួរជាអ្នកត្រូវសេចក្ដីទុក្ខតាមជាប់ឡើយ ។

Verse 302. It is hard to become a bhikkhu; it is hard to be happy in the practice of a bhikkhu. The hard life of a householder is painful; to live with those of a different temperament is painful. A traveller in saṁsāra is continually subject to dukkha; therefore, do not be a traveller in saṁsāra; do not be the one to be subject to dukkha again and again.

គាថាទី ៣០៣: បុគ្គលអ្នកមានសទ្ធាដល់ព្រមដោយសីល បរិបូរដោយយស-ស័ក្តិ និងភោគៈ ទៅកាន់ប្រទេសណាៗ នឹងមានគេបូជា នៅក្នុងប្រទេសនោះៗ មិនខានឡើយ ។

Verse 303. He who is full of faith and virtue, who also possesses fame and fortune, is held in reverence wherever he goes.

គាថាទី ៣០៤: សប្បុរសទាំងឡាយឃើញច្បាស់នៅក្នុងទីឆ្ងាយបាន ដូចជាភ្នំហិមពាន្តយ៉ាងនោះឯង ឯពួកអសប្បុរសទាំងឡាយ (ទោះបីជានៅក្នុងទីជិតនេះ) ក៏មិនប្រាកដច្បាស់ ដូចជាព្រួញដែលគេបាញ់ចោលក្នុងពេលយប់យ៉ាង-នោះឯង ។

Verse 304. Like the Himalayas, the good are visible even from afar; like arrows shot in the night, the wicked are not seen even though they may be near.

គាថាទី ៣០៥: ភិក្ខុគប្បីសេពនូវទីអង្គុយ ទីសឹងតែម្នាក់ឯង ជាអ្នកត្រាច់ចរទៅតែម្នាក់ឯង កុំខ្ជិលច្រអូសឡើយ គប្បីអប់រំខ្លួនតែម្នាក់ឯង ជាអ្នកត្រេកអរតែក្នុងព្រៃ ។

Verse 305. He who sits alone, lies down alone, walks alone, in diligent practice, and alone tames himself should find delight in living in the forest.

## ជំពូកទី ២២: និរយវគ្គ

## Chapter XXII: Niraya Vagga– Woeful State

គាថាទី ៣០៦: អ្នកពោលពាក្យមិនពិតត្រង់រមែងចូលទៅកាន់នរក មួយទៀតអ្នកណាធ្វើអំពើអាក្រក់ តែបាននិយាយថា "អាត្មាអញមិនបានធ្វើអាក្រក់" ដូច្នេះ អ្នកនោះក៏ទៅកាន់នរកដូចគ្នាដែរ បុគ្គលទាំងពីរនាក់នោះជាអ្នកមានកម្មអាក្រក់លាមក លះលោកនេះទៅហើយនឹងជាអ្នកមានគតិស្មើគ្នានៅក្នុងបរលោកនាយ ។

Verse 306. One who tells lies (about others) goes to niraya; one who has done evil and says "I did not do it" also goes to niraya. Both of them being evil-doers, suffer alike (in niraya) in their next existence.





គាថាទី ៣០៧: មនុស្សទាំងឡាយជាច្រើននាក់ដែលមានសំពត់កាសាវៈជាប់នឹងក គឺស្លៀកដណ្ដប់សំពត់លឿង តែជាអ្នកមានធម៌ដ៏លាមក មិនសង្រួមតាមធម៌របស់សមណៈ អ្នកលាមកអម្បាលនោះតែងធ្លាក់ទៅក្នុងនរក ដោយអំពើដ៏លាមកទាំងឡាយដែលគេបានធ្វើហើយ ។

Verse 307. Many men wearing the yellow robe up to their necks who have an evil disposition and are unrestrained in thought, word and deed are reborn in niraya on account of their evil deeds.

គាថាទី ៣០៨: ដុំដែកដែលក្ដៅ ប្រៀបដូចជារងើកភ្លើងដែលបព្វជិតអ្នកទ្រុស្តសីលឆាន់ហើយប្រសើរជាង បព្វជិតដែលទ្រុស្តសីលមិនបានសង្រួម ហើយឆាន់ដុំបាយរបស់អ្នកដែនមិនប្រសើរសោះឡើយ ។

Verse 308. It is better for one to eat a red-hot lump of iron burning like a flame than to eat alms-food offered by the people, if one is without morality (sīla) and unrestrained in thought, word and deed.

គាថាទី ៣០៩: បុគ្គលដែលប្រមាទហើយ សេពនូវភរិយារបស់អ្នកដទៃ រមែងដល់នូវឋានៈ៤ យ៉ាងគឺ: ទីមួយ បានរបស់ដែលមិនមែនជាបុណ្យ ទីពីរ ដេកមិនលក់តាមសេចក្ដីប្រាថ្នា ទីបី ការនិន្ទា ទីបួន ធ្លាក់នរក ។

Verse 309. Four misfortunes befall a man who is unmindful of right conduct and commit sexual misconduct with another man's wife: acquisition of demerit, disturbed sleep, reproach, and suffering in niraya.

គាថាទី ៣១០: ឋានៈ ៤ យ៉ាងទៀត គឺៈ បានរបស់ដែលមិនមែនជាបុណ្យ១ គតិអាក្រក់១ សេចក្តីត្រេកអររបស់បុរសដែលភ័យខ្លាចជាមួយនឹងស្ត្រីដែលភ័យខ្លាចហើយមានប្រមាណតិច១ ព្រះរាជាតែងដាក់ព្រះរាជអាជ្ញាយ៉ាងធ្ងន់១ ព្រោះហេតុនោះ បុគ្គលមិនគួរសេពភរិយារបស់អ្នកដទៃឡើយ ។

Verse 310. Thus, there is the acquisition of demerit, and there is rebirth in the evil apāya realms. The enjoyment of a scared man with a scared woman is short-lived, and the king also metes out severe punishment. Therefore, a man should not commit misconduct with another man's wife.

គាថាទី ៣១១: ស្បូវភ្លាំងដែលគេចាប់ដកមិនល្អហើយ នឹងមុតដៃឯងយ៉ាង-ណាមិញ គុណគ្រឿងជាសមណៈដែលបព្វជិតប្រព្រឹត្តមិនល្អហើយ នឹងទាញទម្លាក់ទៅក្នុងនរកក៏យ៉ាងដូច្នោះដែរ ។

Verse 311. Just as kusa grass if badly held cuts that very hand, so also, the ill-led life of a bhikkhu drags that bhikkhu down to niraya.

គាថាទី ៣១២: ការងារណាដែលទន់ខ្សោយ១ វត្តប្រតិបត្តិណាដែលសៅហ្មងហើយ១ ព្រហ្មចរិយធម៌ឯណាដែលខ្លួនបានរំលឹកដោយការខ្ពើមរអើម១ កម្មទាំង៣ យ៉ាងនេះមិនមានផលច្រើនឡើយ ។

Verse 312. An act perfunctorily performed, or a practice that is depraved, or a questionable conduct of a bhikkhu is not of much benefit.





គាថាទី ៣១៣: បើបុគ្គលនឹងធ្វើ (កម្មណាមួយ) គួរធ្វើកម្មនោះឱ្យបានពិតប្រាកដ គួរធ្វើកម្មនោះឱ្យបានរឹងប៉ឹងល្អ ព្រោះថាសមណធម៌គ្រឿងវៀរចាកដែលធូរថយរមែងឱ្យទោសជាភិយ្យោភាព ដូចជាធូលី ។

Verse 313. If there is anything to be done, do it well; do it firmly and energetically; for the slack life of a bhikkhu scatters much dust (of moral defilements).

គាថាទី ៣១៤: អំពើអាក្រក់ដែលគេមិនបានធ្វើហើយប្រសើរជាង ព្រោះអំពើអាក្រក់តែងដុតកំដៅក្នុងកាលជាខាងក្រោយ ក៏បុគ្គលធ្វើអំពើណាមួយហើយមិនក្តៅក្រហាយក្នុងកាលជាខាងក្រោយ អំពើនោះដែលបុគ្គលធ្វើហើយធ្វើបានល្អហើយ ជាអំពើដ៏ប្រសើរ ។

Verse 314. It is better not to do an evil deed; an evil deed torments one later on. It is better to do a good deed as one does not have to repent for having done it.

គាថាទី ៣១៥: អ្នកទាំងឡាយគួរថែរក្សាការពារខ្លួន ដូចជាគេថែរក្សាការពារនូវភូមិប្រទេសដែលតាំងនៅជាយដែន ទាំងខាងក្នុងទាំងខាងក្រៅយ៉ាងនោះឯង ខណៈចូរកុំកន្លងនូវអ្នកទាំងឡាយឡើយ ព្រោះបុគ្គលទាំងឡាយដែលមានខណៈកន្លងហួសទៅហើយ ជាអ្នកបៀតត្រសៀតគ្នា សោកសៅនៅក្នុងនរក ។

Verse 315. As a border town is guarded both inside and outside, so guard yourself. Let not the right moment go by for those who miss this moment come to grief when they fall into niraya.

គាថាទី ៣១៦: សត្វទាំងឡាយរមែងខ្មាសក្នុងរឿងដែលមិនគួរខ្មាស តែមិនខ្មាសក្នុងរឿងដែលគួរខ្មាស សមាទានមិច្ឆាទិដ្ឋិ នឹងទៅកាន់ទុគ្គតិភព ។

Verse 316. Those beings who are ashamed of what should not be ashamed of, who are not ashamed of what should be ashamed of, and who hold wrong views go to a lower plane of existence (duggati).

គាថាទី ៣១៧: សត្វទាំងឡាយមានប្រក្រតីយល់ឃើញក្នុងរឿងដែលមិនគួរខ្លាចថា គួរខ្លាច យល់ឃើញក្នុងរឿងដែលគួរខ្លាចថា មិនគួរខ្លាច សមាទានមិច្ឆាទិដ្ឋិនឹងទៅកាន់ទុគ្គតិភព ។

Verse 317. Those beings who see danger in what is not dangerous, who do not see danger in what is dangerous, and who hold wrong views go to a lower plane of existence (duggati).

គាថាទី ៣១៨: សត្វទាំងឡាយជាអ្នកដឹងក្នុងរឿងដែលឥតទោសថា មានទោស មានសេចក្តីយល់ឃើញក្នុងរឿងដែលមានទោសថា ជារឿងមិនមានទោស ជាអ្នកកាន់មិច្ឆាទិដ្ឋិនឹងទៅកាន់ទុគ្គតិ ។

Verse 318. Beings who imagine wrong in what is not wrong, who do not see wrong in what is wrong, and who hold wrong views go to a lower plane of existence (duggati).

គាថាទី ៣១៩: សត្វទាំងឡាយជាអ្នកដឹងនូវរឿងដែលមានទោស ព្រោះជារឿងដែលមានទោស ដឹងរឿងដែលមិនមានទោស ព្រោះជារឿងដែលមិនមានទោស ជាអ្នកប្រកាន់ខ្ជាប់នូវសម្មាទិដ្ឋិនឹងទៅកាន់សុគតិភព ។



គាថាធម្មបទ

Verse 319. Beings who know what is wrong as wrong. who know what is right as right, and who hold right views go to a happy plane of existence (sugati).

## ជំពូកទី ២៣: នាគវគ្គ

## Chapter XXIII: Nāga Vagga– The Elephant

គាថាទី ៣២០: តថាគតនឹងអត់ធន់នូវពាក្យសម្តីដែលបុគ្គលនិយាយហួសប្រមាណ ដូចជាដំរីអត់ធន់ចំពោះកូនសរដែលគេបាញ់ពីដងធ្នូក្នុងសង្គ្រាមយ៉ាងនោះឯង ព្រោះថាបុគ្គលទ្រុស្តសីលមានចំនួនច្រើន ។

Verse 320. As an elephant in battlefield withstands the arrow shot from a bow, so shall I endure abuse. Indeed, many people are without morality.

គាថាទី៣២១:បុគ្គលទាំងឡាយតែងនាំសត្វពាហនៈដែលហ្វឹកហាត់ហើយ ចូលទៅកាន់ទីប្រជុំ ព្រះរាជាតែងទ្រង់គង់លើសត្វពាហនៈដែលគេបានហ្វឹកហាត់ហើយ បណ្តាមនុស្សទាំងឡាយ អ្នកណាអត់ធន់ចំពោះពាក្យដែលគេនិយាយហួសប្រមាណបាន អ្នកនោះឈ្មោះថាបានអប់រំខ្លួនហើយ ជាអ្នកប្រសើរបំផុត ។

Verse 321. Only the trained (horses and elephants) are led to gatherings of people; the King mounts only the trained (horses and elephants). Noblest among men are the tamed, who endure abuse.

គាថាទី ៣២២: ពួកសេះសិន្ធពអស្សតរ តួអាជានេយ្យ និងកុញ្ជរ មហានាគទាំងឡាយ ដែលគេបានហ្វឹកហាត់ហើយ ជាសត្វប្រសើរ បុគ្គលដែលបានអប់រំខ្លួនហើយប្រសើរជាងសត្វទាំងនោះ ។

Verse 322. Mules, thoroughbred horses, horses from Sindh, and great elephants are noble only when they are trained; but one who has tamed himself (through Magga Insight) is far nobler.

គាថាទី ៣២៣: បុគ្គលគប្បីទៅកាន់ទិសដែលខ្លួនមិនធ្លាប់បានទៅ (គឺព្រះនិព្វាន) ដោយយានជំនិះទាំងអស់នេះ ឱ្យដូចជាបុគ្គលដែលបានអប់រំខ្លួនហើយទៅដល់ទិសដែលខ្លួនមិនធ្លាប់បានទៅដល់បាន ដោយសារខ្លួនដែលបានអប់រំហើយ អប់រំល្អហើយយ៉ាងដូច្នោះ ពុំបានសោះឡើយ ។

Verse 323. Indeed, not by any means of transport (such as elephants and horses) can one go to the place one has never been before (i.e., Nibbāna); but by thoroughly taming oneself, the tamed one can get to that place (i.e., Nibbāna).

គាថាទី ៣២៤: កុញ្ជរឈ្មោះធនបាលកៈ ជាដំរីចុះប្រេង ហាមបានដោយកម្រណាស់ ត្រូវគេដាក់ខ្សែទន្ទឹងហើយ មិនព្រមស៊ីបាច់ស្មៅ កុញ្ជរនឹករលឹកដល់ព្រៃនាគវ័នតែម្យ៉ាង ។





Verse 324. The elephant called Dhanapāla, in severe must and uncontrollable, being in captivity, eats not a morsel, yearning for his native forest (i. e., longing to look after his parents).

គាថាទី ៣២៥: ពេលណាបុគ្គលជាអ្នកមានប្រក្រតីស៊ីច្រើន ងងុយងក់ ចូលចិត្តដេកច្រើន ក្រហល់ក្រហាយដូចជាសត្វជ្រូកដ៏ធំដែលគេបំប៉នដោយអាហារយ៉ាងនោះឯង ពេលនោះ បុគ្គលនោះជាអ្នកល្ងង់ខ្លៅនឹងចូលទៅកាន់បន្ទប់ជារឿយៗ ។

Verse 325. The stupid one who is lazy, gluttonous, and drowsy, who just wallows like a well-fed pig, is subject to repeated rebirths.

គាថាទី ៣២៦: កាលពីមុនចិត្តនេះបានត្រាច់រង្គត់ទៅតាមសេចក្តីប្រាថ្នា តាមអារម្មណ៍ដែលជាទីស្រឡាញ់ និងតាមសេចក្តីសប្បាយ ថ្ងៃនេះអាត្មាអញនឹងសង្កត់ចិត្តនោះដោយយោនិសោមនសិការៈ ដូចជាហ្មដំរីកាន់កង្វេរហ្វឹកហាត់ដំរីដែលចុះប្រេងយ៉ាងដូច្នោះឯង ។

Verse 326. In the past, this mind has wandered as it liked, wherever it liked, at its own pleasure. Now I will control my mind wisely, as a mahout with his goad controls an elephant in must.

គាថាទី ៣២៧: អ្នកទាំងឡាយចូរជាអ្នកត្រេកអរហើយក្នុងសេចក្តីមិនប្រមាទ ចូរតាមរក្សាចិត្តរបស់ខ្លួន ចូររើខ្លួនឱ្យរួចផុតចេញពីភក់យ៉ាងដូច្នោះឯង ។

Verse 327. Take delight in mindfulness, guard your mind well. As an elephant stuck in mire pulls itself out, so also, pull yourself out of the mire of moral defilements.

គាថាទី ៣២៨: បើបុគ្គលគប្បីបាននូវមិត្រសម្លាញ់ដែលជាអ្នកមានបញ្ញាគ្រឿងរក្សាខ្លួន មានធមិជាគ្រឿងនៅដោយល្អ ជាអ្នកប្រាជ្ញធ្វើដំណើរទៅជាមួយគ្នា គប្បីញ៉ាំញីអន្តរាយទាំងពួងហើយ គប្បីមានចិត្តត្រេកអរ មានសតិ ធ្វើដំណើរទៅជាមួយសម្លាញ់នោះ។

Verse 328. If one finds a sagacious friend, who is a virtuous and steadfast companion, one should live with him joyfully and mindfully, overcoming all dangers.

គាថាទី ៣២៩: បើមិនបានបុគ្គលដែលមានបញ្ញាជាគ្រឿងរក្សាខ្លួន មានធមិជាគ្រឿងនៅល្អ ធ្វើជាសម្លាញ់ ធ្វើដំណើរទៅជាមួយគ្នាទេ គប្បីធ្វើដំណើរទៅតែម្នាក់ឯង ដូចជាព្រះរាជាទ្រង់លះព្រះនគរដែលទ្រង់បានឈ្នះហើយ ឬដូចជាដំរីមាតង្គៈលះហ្វូងចោល ហើយដើរទៅក្នុងព្រៃតែឯងយ៉ាងនោះឯង។

Verse 329. If one cannot find a sagacious friend, who is a virtuous and steadfast companion, one should live alone like the king who gave up and left the country he had won, and like the elephant Mātaṅga roaming alone in the forest.

គាថាទី ៣៣០: ការធ្វើដំណើរទៅតែម្នាក់ឯងជាការប្រសើរជាង ព្រោះភាពជាសម្លាញ់ក្នុងបុគ្គលពាលមិនមានឡើយ បុគ្គលនោះគប្បីជាអ្នកធ្វើដំណើរទៅតែម្នាក់ឯង ដូចជាដំរីមាតង្គៈជាសត្វមានការខ្វល់ខ្វាយតិច ដើរទៅក្នុងព្រៃតែឯងដូច្នោះឯង និងមិនគួរធ្វើនូវអំពើបាបទាំងឡាយផង។





Verse 330. It is better to live alone; there is no fellowship with a fool. So one should live alone, do no evil, and be carefree like the elephant Mātaṅga roaming alone in the forest.

គាថាទី ៣៣១: កាលបើសេចក្តីត្រូវការកើតឡើងហើយ មិត្រសម្លាញ់ទាំង-ឡាយនាំសេចក្តីសុខមកឱ្យ សេចក្តីត្រេកអរដោយបច្ច័យតាមមានតាមបាននាំសេចក្តីសុខមកឱ្យ បុណ្យនាំសេចក្តីសុខមកឱ្យនៅវេលាជិតនឹងអស់អាយុជីវិត ការលះបង់សេចក្តីទុក្ខទាំងពួងបាន នាំសេចក្តីសុខមកឱ្យ។

Verse 331. It is good to have friends when the need arises; it is good to be content with anything that is available; it is good to have merit when life is about to end; it is good to be rid of all dukkha.

គាថាទី ៣៣២: ភាពជាអ្នកប្រតិបត្តិត្រឹមត្រូវដល់មាតា នាំសេចក្តីសុខមកឱ្យក្នុងលោក មួយទៀតភាពជាអ្នកប្រតិបត្តិត្រឹមត្រូវដល់បិតា នាំសេចក្តីសុខមកឱ្យក្នុងលោក។ ភាពជាអ្នកប្រតិបត្តិត្រឹមត្រូវដល់សមណៈ នាំសេចក្តីសុខមកឱ្យក្នុងលោក មួយទៀតភាពជាអ្នកមានប្រតិបត្តិត្រឹមត្រូវដល់ព្រាហ្ម នាំសេចក្តីសុខមកឱ្យ។

Verse 332. In this world it is good to be dutiful to one's mother; also it is good to be dutiful to one's father. In this world it is good to minister unto samanas; also it is good to minister unto brāhmaṇas.

គាថាទី ៣៣៣: សីលនាំសេចក្ដីសុខមកឱ្យរហូតដល់ជរា សទ្ធាដែលតម្កល់ទុកបានល្អហើយ នាំសេចក្ដីសុខមកឱ្យ កិរិយាបាននូវបញ្ញា នាំសេចក្ដីសុខមកឱ្យ ការមិនធ្វើនូវអំពើអាក្រក់ទាំងឡាយ នាំសេចក្ដីសុខមកឱ្យ ។

Verse 333. It is good to have virtue till old age, it is good to have unshakable faith, it is good to gain wisdom, it is good to do no evil.

## ជំពូកទី ២៤: តណ្ហាវគ្គ

## Chapter XXIV: Taṇhā Vagga– Craving

គាថាទី ៣៣៤: តណ្ហាដូចជាវល្លិ៍ជ្រែវរមែងចម្រើនដល់បុគ្គលដែលមានប្រក្រតីប្រព្រឹត្តប្រមាទហើយ បុគ្គលនោះរមែងវិលកើតវិលស្លាប់ទៅកាន់ភពតូចភពធំ ដូចពានរប្រាថ្នាផ្លែឈើលោតទៅលោតមកក្នុងព្រៃព្រឹក្សាយ៉ាងនោះឯង ។

Verse 334. In a man who is unmindful craving grows like a creeper. He runs from birth to birth, like a monkey seeking fruits in the forest.

គាថាទី ៣៣៥: តណ្ហានោះជាធម្មជាតិលាមកអាក្រក់ ជ្រួតជ្រាបទៅក្នុងអារម្មណ៏ផ្សេងៗនៅក្នុងលោក គ្របសង្កត់បុគ្គលណាបាន សេចក្ដីសោកសៅ





រមែងចម្រើនដល់បុគ្គលនោះ បីដូចជាស្មៅវភ្លាំងដែលត្រូវទឹកភ្លៀងហើយដុះឡើងយ៉ាងនោះឯង ។

Verse 335. In this world, sorrow grows in one who is overwhelmed by this vile craving that clings to the senses, just as well-watered birana grass grows luxuriantly.

គាថាទី ៣៣៦: បុគ្គលណាកម្ចាត់តណ្ហានោះ ដែលជាធម្មជាតិដ៏លាមក ដែលគេក្នុងលោកមិនងាយកន្លងផុតបាន សេចក្ដីសោកសៅទាំងឡាយនឹងឃ្លាតចេញផុតពីបុគ្គលនោះ ដូចជាតំណក់ទឹកស្រក់ធ្លាក់ចេញពីស្លឹកឈូកយ៉ាងដូច្នោះឯង ។

Verse 336. In this world, sorrow falls away from one who overcomes this vile craving that is difficult to get rid of, just as water drops fall away from a lotus leaf.

គាថាទី៣៣៧: ព្រោះហេតុនោះតថាគតនឹងប្រាប់ពួកអ្នកទាំងឡាយថា សេចក្ដីចម្រើន ចូរមានដល់ពួកអ្នកទាំងឡាយដែលមកប្រជុំគ្នានៅក្នុងទីនេះ អ្នកទាំងឡាយ ចូរគាស់រំលើងនូវឫសគល់នៃតណ្ហាចោល ដូចជាបុគ្គលដែលត្រូវការឫសស្មៅវភ្លាំងជីកគាស់ដើមស្មៅវភ្លាំងយ៉ាងដូច្នោះឯង មារចូរកុំបៀតបៀនដល់អ្នកទាំងឡាយឡើយ ដូចជាខ្សែទឹកកួចនូវដើមបបុសរឿយៗយ៉ាងនោះឯង ។

Verse 337. Therefore, I will deliver this worthy discourse to all of you who have assembled here. Dig up the root of craving just as one who wishes to have the fragrant root digs up the birana grass. Do not let Māra destroy you again and again, as the flood destroys the reed.

គាថាទី ៣៣៨: ដើមឈើ កាលបើឫសកែវមិនមានអន្តរាយរស់នៅឡើយ ទោះបីជាបុគ្គលកាត់ដាច់ហើយ ក៏នឹងលូតលាស់ដុះឡើងតទៅទៀតបានយ៉ាងណាមិញ សេចក្តីទុក្ខនេះ កាលបើតណ្ហានុស្ស័យដែលបុគ្គលកម្ចាត់មិនទាន់បានហើយ នឹងកើតឡើងរឿយៗក៏យ៉ាងដូច្នោះដែរ ។

Verse 338. Just as a tree with roots undamaged and firm grows again even though cut down, so also, if latent craving is not rooted out, this dukkha (of birth, ageing and death) arises again and again.

គាថាទី៣៣៩: ក្រសែនៃតណ្ហា ៣៦ យ៉ាង ដែលជ្រួតជ្រាបចូលទៅកាន់អារម្មណ៍ដ៏ជាទីពេញចិត្ត ជាធម្មជាតិកាចសាហាវ មានដល់បុគ្គលណាមួយ សេចក្តីត្រិះរិះទាំងឡាយដ៏ធំអាស្រ័យរាគៈ រមែងនាំបុគ្គលដែលមានទិដ្ឋិអាក្រក់នោះទៅ ។

Verse 339. That man of wrong views, in whom the thirty-six streams (of craving) that flow towards pleasurable objects are strong, is carried away by his many thoughts connected with passion.

គាថាទី ៣៤០: ក្រសែនៃតណ្ហាទាំងឡាយ រមែងជ្រួតជ្រាបចូលទៅក្នុងអារម្មណ៍ទាំងពួង តណ្ហាដូចជាវល្លិបែកខ្នែកឡើងហើយរមែងស្ថិតនៅ ក៏អ្នកទាំងឡាយបានឃើញតណ្ហាដូចជាវល្លិនោះកើតឡើងហើយ ចូរកាត់ផ្តាច់ឫសរបស់វាចោលដោយបញ្ញាចុះ ។





Verse 340. The stream of craving flows towards all sense objects; the creeper of craving arises (at the six sense-doors) and fixes itself (on the six sense objects). Seeing that creeper of craving growing, cut off its roots with Magga Insight.

គាថាទី ៣៤១: សោមនស្សទាំងឡាយដែលជ្រួតជ្រាបទៅហើយ និងសោមនស្សដែលប្រព្រឹត្តទៅជាមួយនឹងតណ្ហាដូចជ័រស្អិតរមែងមានដល់សត្វ សត្វទាំងនោះអាស្រ័យសេចក្តីសុខសប្បាយ ទើបស្វះស្វែងរកសេចក្តីសុខ នរជនទាំងនោះឯង គឺជាអ្នកដែលចូលទៅកាន់ជាតិ និងជរា ។

Verse 341. In beings, there flows happiness that is smeared with craving; those beings attached to pleasure and seeking pleasure are, indeed, subject to birth and ageing.

គាថាទី ៣៤២: ពួកសត្វ (ទាំងឡាយនេះ) ត្រូវតណ្ហាអ្នកធ្វើសេចក្តីច្របូកច្របល់ចោមព័ទ្ធអស់ហើយ រមែងរើបម្រះនឿលទៅមក បីដូចជាសត្វទន្សាយដែលជាប់អន្ទាក់នាយព្រានយ៉ាងដូច្នោះឯង ពួកសត្វទាំងនេះជាអ្នកជាប់ជំពាក់ហើយដោយសំយោជន៍ និងកិលេសដែលជាគ្រឿងជាប់ជំពាក់ ទើបជួបប្រទះសេចក្តីទុក្ខជារឿយៗ អស់កាលជាយូរអង្វែង ។

Verse 342. People beset with craving are terrified like a hare caught in a snare; held fast by fetters and bonds they undergo dukkha (round of rebirths) again and again, for a long time.

គាថាទី ៣៤៣: ពួកសត្វដែលត្រូវតណ្ហាអ្នកធ្វើសេចក្តីច្របូកច្របល់ចោមព័ទ្ធបានហើយ រមែងរើបម្រះនឿលទៅមក បីដូចជាសត្វទន្សាយដែលជាប់

អន្ទាក់នាយព្រានដូច្នោះឯង ។ ព្រោះហេតុនោះ កាលបើភិក្ខុប្រាថ្នាធម៌ដែលជាទីកម្ចាត់នូវរាគៈដើម្បីខ្លួន គប្បីកម្ចាត់បង់នូវតណ្ហាដែលធ្វើសេចក្ដីច្របូកច្រ-បល់ឱ្យបាន ។

Verse 343. People beset with craving are terrified like a hare caught in a snare. Therefore, One who wishes to free himself from craving should eradicate craving.

គាថាទី ៣៤៤: បុគ្គលណាមានអាល័យដូចជាដើមឈើដែលតាំងនៅក្នុងព្រៃចេញហើយ បង្អោនចូលទៅក្នុងព្រៃ (គឺតបៈ) បានរួចផុតពីព្រៃហើយ ក៏នៅតែត្បូលចូលទៅព្រៃ ដូចជាពីដើមវិញទៀត អ្នកទាំងឡាយចូរមើលបុគ្គលនោះចុះ គេបានរួចផុតហើយ (ពីចំណង) នៅតែបោលចូលទៅរកចំណងដូចជាពីដើមវិញទៀត ។

Verse 344. Having left the forest of desire (i.e., the life of a householder), he takes to the forest of the practice (i.e., the life of a bhikkhu); but when he is free from the forest of desire he rushes back to that very forest. Come, look at that man who having become free rushes back into that very bondage.

គាថាទី ៣៤៥-៣៤៦: ចំណងឯណាធ្វើអំពីដែកក្ដី កើតអំពីឈើក្ដី កើតអំពីស្មៅដំណេកទន្សាយក្ដី អ្នកប្រាជ្ញទាំងឡាយមិនបានពោលនូវចំណងនោះថាមាំទេ សេចក្ដីអាលោះអាល័យឯណាប្រកបដោយសេចក្ដីត្រេកអរក្រៃពេកក្នុងកែវមណីនិងកុណ្ឌលផង ក្នុងកូននិងប្រពន្ធផង អ្នកប្រាជ្ញទាំងឡាយពោលនូវ





ចំណងនោះថា ចំណងមាំ ជាគ្រឿងទាញសត្វឱ្យចុះក្នុងអបាយ ជាចំណងធូរប៉ុន្តែបុគ្គលស្រាយបានដោយក្រ អ្នកប្រាជ្ញទាំងឡាយកាត់ផ្ដាច់នូវចំណងនេះមិនមានអាលោះអាល័យ លះបង់នូវកាមសុខវៀរចេញស្រឡះ ។

Verses 345 & 346. The wise do not say that bonds made of iron, of wood, and of hemp are strong bonds; they say that only passionate attachment to and care for gems and jewelry, children and wives are strong bonds. These drag one down (to lower planes of existence) and although they seem yielding are difficult to unfasten. The wise, cutting off this bond (of craving) and resolutely giving up sensual pleasures, renounce the world.

គាថាទី ៣៤៧: សត្វទាំងឡាយណាជាអ្នកត្រេកអរហើយដោយរាគៈ សត្វទាំងឡាយនោះនឹងធ្លាក់ទៅដល់ក្រសែនៃតណ្ហា ដូចជាសត្វពីងពាងធ្លាក់ទៅកាន់សំបុកដែលខ្លួនបានធ្វើហើយយ៉ាងដូច្នោះឯង ។ អ្នកប្រាជ្ញទាំងឡាយកាត់នូវក្រសែនៃតណ្ហានោះបានហើយ ជាអ្នកមិនមានសេចក្ដីស្នេហា លះបង់នូវសេចក្ដីទុក្ខទាំងពួងទៅបាន ។

Verse 347. Beings who are infatuated with lust, fall back into the Stream of Craving they have generated, just as a spider does in the web it has spun. The Wise, cutting off the bond of craving, walk on resolutely, leaving, all ills (dukkha) behind.

គាថាទី ៣៤៨: អ្នកចូរលះអាល័យក្នុងពេលមុន ចូរលះអាល័យក្នុងពេលជាខាងក្រោយ ចូរលះអាល័យក្នុងពេលជាកណ្ដាលចោល ទើបជាអ្នកដល់ត្រើយ

នៃភព មានចិត្តរួចផុតពីសង្ខតធម៌ទាំងពួង នឹងមិនចូលទៅកាន់ជាតិជរាតទៅទៀតបានឡើយ ។

Verse 348. Give up the past, give up the future, give up the present. Having reached the end of existences, with a mind freed from all (conditioned things), you will not again undergo birth and decay.

គាថាទី ៣៤៩: តណ្ហារមែងចម្រើនឡើងជាភិយ្យោភាពដល់បុគ្គលដែលត្រូវវិតក្កៈគ្របសង្កត់ហើយ ច្រើនដោយរាគៈ ឃើញតាមអារម្មណ៍ថាល្អ បុគ្គលនោះឯងឈ្មោះថាធ្វើចំណងឱ្យជាប់ជាស្ថាពរ ។

Verse 349. In a man who is disturbed by (sensual) thoughts, whose passions are strong, and who keeps seeing objects as being pleasant, craving grows more and more. Indeed, he makes his bondage strong.

គាថាទី ៣៥0: ភិក្ខុណាត្រេកអរក្នុងធម៌ដែលចូលទៅស្ងប់រម្ងាប់វិតក្កៈ ចម្រើនអសុភៈ មានសតិសព្វៗកាល ភិក្ខុនោះឯងនឹងធ្វើតណ្ហាឱ្យសាបសូន្យទៅបាន ភិក្ខុនោះនឹងកាត់ផ្តាច់នូវចំណងរបស់មារបាន ។

Verse 350. A man who takes delight in calming (sensual) thoughts, who is ever mindful, and meditates on the impurity (of the body, etc.) will certainly get rid (of craving); this man will cut the bond of Māra.

គាថាទី ៣៥១: អ្នកណាបានដល់នូវសេចក្តីសម្រេច មានប្រក្រតីមិនចេះខ្លាច មិនមានតណ្ហា មិនមានកិលេសគ្រឿងពួន កាត់ផ្តាច់នូវកូនសរដែលឱ្យទៅកាន់





ភពទាំងឡាយបានហើយ កាយនេះ (របស់អ្នកនោះ) ឈ្មោះថា មាននៅក្នុងទីបំផុត ។

Verse 351. He who has attained arahatship is free from fear, free from craving, and free from moral defilements. He has cut off the thorns of existence (such as lust). This is the last existence (for him).

គាថាទី ៣៥២: អ្នកណាមានតណ្ហាទៅប្រាសហើយ មិនប្រកាន់ខ្លួន ឆ្លាតក្នុងនិរុត្តិបទ ស្គាល់ក្រុមនៃអក្សរទាំងឡាយ ស្គាល់ខាងដើមនិងខាងចុងនៃអក្សរទាំងឡាយ អ្នកនោះឯង តថាគតឱ្យឈ្មោះថា "មានសរីរៈនៅក្នុងទីបំផុត មានបញ្ញាច្រើន ជាមហាបុរស" ។

Verse 352. He who is free from craving and from attachment, who is skilled in the knowledge of the significance of terms, who knows the grouping of letters and their sequence is indeed called "one who has lived his last, a man of great wisdom, a great man."

គាថាទី ៣៥៣: តថាគតជាអ្នកគ្របសង្កត់នូវធម៌ទាំងពួង ដឹងច្បាស់នូវធម៌គ្រប់យ៉ាង មិនជាប់ជំពាក់ក្នុងធម៌ទាំងពួង លះបង់ធម៌បានទាំងអស់ រួចផុតហើយក្នុងការអស់ទៅនៃតណ្ហា ដឹងច្បាស់ខ្លួនឯង នឹងគប្បីអាងទៅដល់អ្នកណាថា (ជាគ្រូអាចារ្យ) ?

Verse 353. I have overcome all, I know all, I am detached from all, I have given up all; I am liberated from moral defilements having eradicated craving, (i. e., I have attained arahatship).

Having comprehended the Four Noble Truths by myself, whom should I point out as my teacher?

គាថាទី ៣៥៤: ធម្មទានរមែងឈ្នះនូវទានទាំងពួង រសធម៌រមែងឈ្នះនូវរស ទាំងពួង សេចក្តីត្រេកអរក្នុងធម៌រមែងឈ្នះនូវសេចក្តីត្រេកអរទាំងពួង ការអស់ទៅនៃតណ្ហារមែងឈ្នះនូវសេចក្តីទុក្ខទាំងពួង ។

Verse 354. The gift of tile Dhamma excels all gifts; the taste of the Dhamma excels all tastes; delight in the Dhamma excels all delights. The eradication of Craving (i.e., attainment of arahatship) overcomes all ills (saṁsāra dukkha).

គាថាទី ៣៥៥: ភោគៈទាំងឡាយតែងសម្លាប់នូវអ្នកដែលល្ងង់ខ្លៅ តែមិនសម្លាប់នូវអ្នកដែលស្វែងរកត្រើយគឺព្រះនិព្វាន អ្នកអាប់ឥតបញ្ញារមែងសម្លាប់ខ្លួនឯង ដូចជាសម្លាប់អ្នកដទៃ ព្រោះប្រាថ្នាចង់បានភោគៈ ។

Verse 355. Wealth destroys the foolish; but it cannot destroy those who seek the other shore (i.e., Nibbāna). By his craving for wealth the fool destroys himself, as he would destroy others.

គាថាទី ៣៥៦: ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វនេះក៏មានរាគៈជាទោស ព្រោះហេតុនោះហើយទានដែលគេបានឱ្យហើយក្នុងបុគ្គលដែលប្រាសចាករាគៈជាទានមានផលច្រើន ។

Verse 356. Weeds damage fields; lust spoils all beings. Therefore, giving to those free from lust yields great benefit.





គាថាទី ៣៥៧: ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វនេះក៏មានទោសៈជាទោស ព្រោះហេតុនោះហើយទានដែលគេបានឱ្យហើយក្នុងបុគ្គលដែលប្រាសចាកទោសៈ ជាទានមានផលច្រើន ។

Verse 357. Weeds damage fields; ill will spills all beings. Therefore, giving to those free from ill will yields great benefit.

គាថាទី ៣៥៨: ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វនេះក៏មានមោហៈជាទោស ព្រោះហេតុនោះហើយទានដែលគេបានឱ្យហើយក្នុងបុគ្គលដែលប្រាសចាកមោហៈ ជាទានមានផលច្រើន ។

Verse 358. Weeds damage fields; ignorance spoils all beings. Therefore, giving to those free from ignorance yields great benefit.

គាថាទី ៣៥៩: ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វនេះក៏មានការចង់បានជាទោស ព្រោះហេតុនោះហើយទានដែលគេបានឱ្យហើយក្នុងបុគ្គលដែលមិនមានការចង់បាន ជាទានមានផលច្រើន ។

Verse 359. Weeds damage fields; covetousness spoils all beings. Therefore, giving to those free from covetousness yields great benefit.

## ជំពូកទី ២៥: ភិក្ខុវគ្គ

## Chapter XXV: Bhikkhu Vagga– The Monk

គាថាទី ៣៦០: ការសង្រួមដោយភ្នែកជាការប្រពៃ ការសង្រួមដោយត្រចៀកជាការប្រពៃ ការសង្រួមដោយច្រមុះជាការប្រពៃ ការសង្រួមដោយអណ្ដាតជាការប្រពៃ។

Verse 360. Restraint in the eye is good, good is restraint in the ear; restraint in the nose is good, good is restraint in the tongue.

គាថាទី ៣៦១: ការសង្រួមដោយកាយជាការប្រពៃ ការសង្រួមដោយវាចាជាការប្រពៃ ការសង្រួមដោយចិត្តជាការប្រពៃ ការសង្រួមក្នុងទ្វារទាំងអស់ជាការប្រពៃ ភិក្ខុសង្រួមក្នុងទ្វារទាំងពួង រមែងរួចផុតអំពីសេចក្ដីទុក្ខទាំង-ពួង។

Verse 361. Restraint in body is good, good is restraint in speech; restraint in mind is good, good is restraint in all the senses. A bhikkhu restrained in all the senses is freed from all ills (Saṁsāra dukkha).

គាថាទី ៣៦២: អ្នកណាមានដៃសង្រួមហើយ មានជើងសង្រួមហើយ មានវាចាសង្រួមហើយ មានខ្លួនសង្រួមហើយ ជាអ្នកត្រេកអរហើយក្នុងភាវនា





ខាងក្នុង មានចិត្តតម្កល់ទុក តែម្នាក់ឯង សន្ដោស បណ្ឌិតទាំងឡាយហៅ អ្នកនោះថាភិក្ខុ។

Verse 362. He who controls his hand, controls his foot, controls his speech, and has complete control of himself; who finds delight in Insight Development Practice and is calm; who stays alone and is contented; & dash; him they call a bhikkhu.

គាថាទី ៣៦៣: ភិក្ខុណាមានមាត់សង្រួមហើយ និយាយដោយបញ្ញា មិនអណ្ដែតអណ្ដូង សម្ដែងហេតុនិងផល ភាសិតរបស់ភិក្ខុនោះទើបពីរោះ។

Verse 363. The bhikkhu who controls his mouth (speech) who speaks wisely with his mind composed, who explains the meaning and the text of the Dhamma, & dash; sweet are the words of that bhikkhu.

គាថាទី ៣៦៤: ភិក្ខុមានធម៌ជាទីមកត្រេកអរ ត្រេកអរហើយក្នុងធម៌ ពិចារ-ណានូវព្រះធម៌ រឭកព្រះធម៌រឿយៗ នឹងមិនសាបសូន្យអំពីព្រះសទ្ធម្ម។

Verse 364. The bhikkhu who abides in the Dhamma, who delights in the Dhamma, who meditates on the Dhamma, and is ever mindful of the Dhamma, does not fall away from the Dhamma of the virtuous.

គាថាទី ៣៦៥: ភិក្ខុមិនត្រូវមើលងាយលាភរបស់ខ្លួន មិនត្រូវដើរស្វែងរកលាភរបស់អ្នកដទៃ ភិក្ខុកាលបើចង់បានលាភរបស់អ្នកដទៃ នឹងមិនបានសម្រេចសមាធិ។

Verse 365. One should not despise what one has received (by proper means), nor should one envy others their gains. The

bhikkhu who envies others cannot attain Concentration (Samādhi).

គាថាទី ៣៦៦: បើភិក្ខុមានលាភតិចក៏ដោយ តែមិនបានមើលងាយលាភរបស់ខ្លួន ទេវតាទាំងឡាយតែងសរសើរភិក្ខុនោះថា ជាអ្នកមានអាជីវបរិសុទ្ធល្អ មិនខ្ជិលច្រអូស។

Verse 366. Though he receives only a little, if a bhikkhu does not despise what he has received (by proper means), the devas will surely praise him who leads a pure life and is not slothful.

គាថាទី ៣៦៧: ការប្រកាន់ខ្ជាប់ក្នុងនាមរូប ថា "ជារបស់អញ" ដោយប្រការទាំងពួងមិនមានដល់បុគ្គលណា មួយទៀត អ្នកណាមិនសោកសៅព្រោះនាមរូបដែលមិនមាន បុគ្គលនោះឯង តថាគតហៅថា ភិក្ខុ។

Verse 367. He who does not take the mind-and-body aggregate (nāma-rupa) as "I and mine", and who does not grieve over the dissolution (of mind and body) is, indeed, called a bhikkhu.

គាថាទី ៣៦៨: ភិក្ខុណាមានប្រក្រតីនៅដោយមេត្តា ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះគប្បីបានសម្រេចសន្តបទ (គឺព្រះនិព្វាន) ជាទីចូលទៅរម្ងាប់សង្ខារជាសុខ។

Verse 368. The bhikkhu who lives exercising loving-kindness and is devoted to the Teaching of the Buddha will realize Nibbāna & dash; the Tranquil, the Unconditioned, the Blissful.



គាថាធម្មបទ

គាថាទី ៣៦៩: ម្នាលភិក្ខុ អ្នកចូរស្តារទូកគឺអត្តភាពនេះចេញ ទូកដែលអ្នកស្តារហើយនឹងបានដល់ត្រើយលឿន អ្នកផ្តាច់រាគៈ និងទោសៈបានហើយ តពីនោះនឹងបានដល់នូវព្រះនិព្វាន។

Verse 369. O bhikkhu, bale out the water (of wrong thoughts) from this boat (your body); when empty it will sail swiftly; having cut off passion and ill-will you will realize Nibbāna.

គាថាទី ៣៧០: ភិក្ខុគប្បីកាត់ផ្តាច់នូវធម៌ ៥ យ៉ាង គប្បីលះបង់នូវធម៌ ៥ យ៉ាង ហើយនឹងគប្បីញ៉ាំងធម៌ ៥ យ៉ាង ឱ្យរីតតែចម្រើនឡើង ភិក្ខុដែលកន្លងនូវកិលេសគ្រឿងជាប់ជំពាក់ ៥ យ៉ាងនេះបានហើយ តថាគតហៅថា អ្នកកន្លងឱឃៈបានហើយ។

Verse 370. Cut off the five (the lower five fetters) give up the five (the upper five fetters); and develop the five (controlling faculties). The bhikkhu who has freed himself of the five bonds (passion, ill will, ignorance, pride and wrong view) is called "One who has crossed the flood (of *saṁsāra*)."

គាថាទី ៣៧១: ម្នាលភិក្ខុ អ្នកចូរពិចារណាឈាន និងកុំគប្បីប្រមាទឡើយ ចិត្តរបស់អ្នកចូរកុំវិលធ្លាក់ទៅក្នុងកាមគុណឡើយ អ្នកចូរកុំប្រមាទលេប (ឆាន់) នូវដុំលោហៈឡើយ អ្នកចូរកុំឱ្យកម្មដុតរោលរាលស្រែកទួញយំថា "នេះជាទុក្ខ" ដូច្នេះឡើយ។

Verse 371. O Bhikkhu, mediate, and do not be unmindful; do not let your mind rejoice in sensual pleasures. Do not be

unmindful and swallow the (hot) lump of iron; as you burn (in *niraya*) do not cry, "This, indeed, is suffering."

គាថាទី ៣៧២: ឈានមិនមានដល់អ្នកដែលមិនមានបញ្ញា បញ្ញានឹងមិនមានដល់អ្នកដែលមិនមានឈាន ឈាននិងបញ្ញាមាននៅក្នុងបុគ្គលណា បុគ្គលនោះឯងឈ្មោះថា តាំងនៅជិតព្រះនិព្វាន ។

Verse 372. There can be no concentration in one who lacks wisdom; there can be no wisdom in one who lacks concentration. He who has concentration as well as wisdom is, indeed, close to Nibbāna.

គាថាទី ៣៧៣: សេចក្តីត្រេកអរមិនមែនរបស់មាននៅនៃមនុស្ស រមែងមានដល់ភិក្ខុដែលចូលទៅកាន់ផ្ទះស្ងាត់ ជាអ្នកមានចិត្តស្ងប់រម្ងាប់ហើយ ជាអ្នកឃើញច្បាស់នូវព្រះធម៌ដោយប្រពៃ ។

Verse 373. The bhikkhu who goes into seclusion (to meditate), whose mind is tranquil, who clearly perceives the Dhamma, experiences the joy which transcends that of (ordinary) men.

គាថាទី ៣៧៤: ភិក្ខុពិចារណាឃើញនូវការកើតឡើង និងការរលត់ទៅនៃខន្ធទាំងឡាយដោយអាការៈណាៗ ភិក្ខុនោះរមែងបាននូវបីតិនិងប្រាមោទ្យដោយអាការៈនោះៗ ការបាននូវបីតិនិងប្រាមោទ្យនោះ ជាអមតធម៌របស់អ្នកប្រាជ្ញទាំងឡាយ ។

Verse 374. Every time he clearly comprehends the arising and the perishing of the *khandhas*, he finds joy and rapture. That, to the wise, is the way to Nibbāna (the Deathless).



គាថាធម្មបទ

គាថាទី ៣៧៥: ក្នុងអមតធម៌នោះ ធម៌នេះជាធម៌ខាងដើមរបស់ភិក្ខុក្នុងព្រះ-ពុទ្ធសាសនានេះ គឺៈ ការរក្សាឥន្ទ្រិយ៍១ សេចក្តីសន្តោស១ ការសង្រួមក្នុងព្រះបាតិមោក្ខ១ ។

Verse 375. For a wise bhikkhu in this Teaching, this is the beginning (of the practice leading to Nibbāna): control of the senses, contentment, and restraint according to the Fundamental Precepts.

គាថាទី ៣៧៦: អ្នកចូរសេពគប់នូវមិត្រទាំងឡាយដែលល្អ មានអាជីវបរិសុទ្ធមិនខ្ជិលច្រអូស ។ ភិក្ខុគប្បីជាអ្នកឈ្លាសវាងវៃ នៅក្នុងការប្រព្រឹត្តិបដិសណ្ឋារៈគប្បីជាអ្នកឈ្លាសវាងវៃនៅក្នុងអាចារៈ ព្រោះហេតុនោះ អ្នកនឹងជាបុគ្គលដែលមានប្រាមោទ្យច្រើន ធ្វើនូវទីបំផុតនៃសេចក្តីទុក្ខបាន ។

Verse 376. Associate with good friends, who are energetic and whose livelihood is pure; let him be amiable and be correct in his conduct. Then, (frequently) feeling much joy he will make an end of dukkha (of the round of rebirths).

គាថាទី ៣៧៧: ម្នាលភិក្ខុទាំងឡាយ! អ្នកចូរលះបង់នូវរាគៈនិងទោសៈចោលដូចដើមម្លិះជម្រុះផ្កាដែលស្រពោនយ៉ាងនោះឯង ។

Verse 377. O bhikkhus! As the jasmin (vassika) plant sheds its withered flowers, so also, should you shed passion and ill- will.

គាថាទី ៣៧៨: ភិក្ខុដែលមានកាយស្ងប់ មានវាចាស្ងប់ មានចិត្តស្ងប់ហើយ ជាអ្នកតម្កល់ខ្លួនទុកបានល្អហើយ មានអាមិសក្នុងលោកខ្ជាក់ចោលអស់ហើយ តថាគតហៅ អ្នកនោះថា "ជាអ្នកស្ងប់រម្ងាប់" ហើយ ។

Verse 378 The bhikkhu who is calm in body, calm in speech, and calm in mind, who is well-composed and has given up (lit., vomited) worldly pleasures, is called a "Tranquil One".

គាថាទី ៣៧៩: អ្នកចូរចោទខ្លួនដោយខ្លួនឯង ចូរពិចារណាខ្លួនដោយខ្លួនឯង ម្នាលភិក្ខុ អ្នកនោះជាអ្នកមានសតិ រក្សាខ្លួនប្រាណហើយ នឹងរស់នៅជាសុខសប្បាយ ។

Verse 379: O bhikkhu, by yourself exhort yourself, and examine yourself; thus guarding yourself and being mindful, you will live in peace.

គាថាទី ៣៨០: ខ្លួនជាទីពឹងរបស់ខ្លួនឯង ខ្លួនជាគតិរបស់ខ្លួនឯង ព្រោះហេតុនោះអ្នកចូររក្សាខ្លួន ដូចជានាយពាណិជថែរក្សានូវសេះដែលល្អយ៉ាងដូច្នោះឯង ។

Verse 380: One indeed is one's own refuge, (how could anyone else be one's refuge?) One indeed is one's own heaven; therefore, look after yourself as a horse dealer looks after a thoroughbred.





គាថាទី ៣៨១: ភិក្ខុអ្នកមានប្រាមោទ្យច្រើន ជ្រះថ្លាហើយក្នុងព្រះពុទ្ធសាស-នា គប្បីបានសម្រេចនូវសន្តបទ (គឺព្រះនិព្វាន) ដែលចូលទៅរម្ងាប់សង្ខារជាសុខ ។

Verse 381:.The bhikkhu who frequently feels joy and is devoted to the Teaching of the Buddha will realize Nibbāna & dash; the Tranquil, the Unconditioned, the Blissful.

គាថាទី ៣៨២: ភិក្ខុណានៅជាកម្លោះ ព្យាយាមខ្នះខ្នែងនៅក្នុងព្រះពុទ្ធសាស-នា ភិក្ខុនោះនឹងញ៉ាំងលោកនេះឱ្យភ្លឺស្វាងបាន ដូចជាព្រះច័ន្ទរះផុតពីពពកភ្លឺត្រចះត្រចង់យ៉ាងនោះឯង ។

Verse 382. A bhikkhu who, though young, devotes himself to the Teaching of the Buddha lights up the world, as does the moon freed from a cloud.

## ជំពូកទី ២៦: ព្រាហ្មណវគ្គ

## Chapter XXVI: Brāhmaṇa Vagga– The Brāhman

គាថាទី ៣៨៣: ម្នាលព្រាហ្មណ៍ អ្នកចូរព្យាយាមកាត់ផ្តាច់នូវក្រសែនៃតណ្ហាចោលចេញ ចូរកម្ចាត់បង់នូវកាមទាំងឡាយចោល ព្រាហ្មណ៍អ្នកដឹងនូវការ

រលត់អស់ទៅនៃសង្ខារទាំងឡាយហើយ ជាអ្នកបានដឹងនូវព្រះនិព្វានដែលបច្ច័យតាក់តែងឡើងមិនបាន ។

Verse 383. O brāhmaṇa, cut off the stream of craving with diligence, and abandon sense desires. O brāhmaṇa, perceiving the cessation of the conditioned, be an arahat who realizes Nibbāna, the Unconditioned.

គាថាទី ៣៨៤: ពេលណាព្រាហ្មណ៍ជាអ្នកដល់នូវត្រើយក្នុងធម៌ទាំងពីរយ៉ាង គឺសមថៈនិងវិបស្សនា ពេលនោះកិលេសគ្រឿងប្រកបសត្វទាំងពួងរបស់ព្រាហ្មណ៍ជាអ្នកដឹងនោះ នឹងដល់នូវការតាំងនៅមិនបាន ។

Verse 384. When the brāhmaṇa is well-established in the two dhammas (i.e., the practice of Tranquillity and Insight Meditation), then, in that knowing one, all fetters are destroyed.

គាថាទី ៣៨៥: ត្រើយក្តី ទីដែលមិនមែនជាត្រើយក្តី ត្រើយនិងទីដែលមិនមែនជាត្រើយក្តី មិនមានដល់បុគ្គលណា តថាគតហៅបុគ្គលនោះ ដែលជាអ្នកមានសេចក្តីក្រហល់ក្រហាយអស់ហើយ អស់កិលេសថា ជាព្រាហ្មណ៍ ។

Verse 385. Him I call a brāhmaṇa who has for him neither this shore (i.e., the sense-bases) nor the other shore (i.e., the sense objects ), and who is undistressed and free from moral defilements.

គាថាទី ៣៨៦: តថាគតហៅបុគ្គលដែលមានឈាន មានកាមដូចជាធូលីទៅប្រាសហើយ នៅតែម្នាក់ឯង មានកិច្ចបានធ្វើចប់ហើយ មិនមានអាសវៈ បានសម្រេចប្រយោជន៍ដ៏ខ្ពង់ខ្ពស់នោះថា ជាព្រាហ្មណ៍ ។





Verse 386. Him I call a brāhmaṇa, who dwells in seclusion practising Tranquillity and Insight Meditation and is free from taints (of moral defilements); who has performed his duties, and is free from moral intoxicants (āsavas) and has reached the highest goal (arahatship).

គាថាទី ៣៨៧: ព្រះអាទិត្យរុងរឿងបានតែក្នុងវេលាថ្ងៃ ព្រះច័ន្ទភ្លឺស្វាងរុងរឿងបានតែក្នុងវេលាយប់ ព្រះមហាក្សត្រលុះតែទ្រង់គ្រឿងប្រដាប់សម្រាប់រាជ្យ ទើបរុងរឿងបាន ព្រាហ្មណ៍លុះត្រាតែចម្រើនឈាន ទើបរុងរឿងបាន ឯព្រះពុទ្ធជាម្ចាស់ទ្រង់រុងរឿងបានដោយតេជៈទាំងវេលាថ្ងៃ ទាំងវេលាយប់ ។

Verse 387. By day shines the sun; by night shines the moon; in regalia shines the king; in meditation shines the arahat; but the Buddha in his glory shines at all times, by day and by night.

គាថាទី ៣៨៨: បុគ្គលដែលបានលះបាបហើយ តថាគតហៅថា "ព្រាហ្មណ៍" បុគ្គលដែលតថាគតហៅថា "សមណៈ" នោះ ព្រោះប្រព្រឹត្តល្អត្រឹមត្រូវ បុគ្គលដែលកម្ចាត់មន្ទិលរបស់ខ្លួនចេញ ហេតុនោះតថាគតហៅថា "បព្វជិត" ។

Verse 388. Because he has discarded evil he is called a 'brāhmaṇa'; because he lives calmly he is called a 'samaṇa'; and because he gets rid of his impurities he is called a 'pabbajita'.

គាថាទី ៣៨៩: ព្រាហ្មណ៍មិនគួរវាយប្រហារដល់ព្រាហ្មណ៍ឡើយ មិនគួរចងពៀរវេរាដល់ព្រាហ្មណ៍នោះឡើយ គួរតែត្មះតិះដៀលព្រាហ្មណ៍ដែលវាយប្រ-

ហារព្រាហ្មណ៍ គួរតែតិះដៀលព្រាហ្មណ៍ដែលចងពៀរ ជាងព្រាហ្មណ៍ដែលវាយប្រហារនោះទៅទៀត ។

Verse 389. One should not strike a brāhmaṇa; a brāhmaṇa should not get angry with his assailant; it is shameful to strike a brāhmaṇa; it is more shameful to get angry with one's assailant.

គាថាទី ៣៩០: ការហាមឃាត់ចិត្តចាកចេញពីអារម្មណ៍ដែលជាទីស្រឡាញ់ទាំងឡាយណា ការហាមឃាត់នោះ ជាការហាមឃាត់ដ៏ប្រសើរ មិនមែនតិចតួចដល់ព្រាហ្មណ៍ឡើយ ចិត្តដែលសម្បយុត្តដោយការបៀតបៀន រមែងប្រែត្រឡប់មកវិញបានពីវត្ថុណា១ សេចក្តីទុក្ខរមែងស្ងប់រម្ងាប់បានព្រោះវត្ថុនោះ១ឯង ។

Verse 390. For a brāhmaṇa there is no benefit at all if he does not restrain from anger to which his mind is prone. Inasmuch as one desists from the intention to harm, to that extent dukkha ceases.

គាថាទី ៣៩១: អ្នកណាមិនមានសេចក្តីអាក្រក់ដោយកាយ វាចា ចិត្ត តថាគតហៅអ្នកនោះដែលបានសង្រួមហើយដោយឋានៈទាំង ៣ យ៉ាង ថា ព្រាហ្មណ៍ ។

Verse 391. Him I call a brāhmaṇa who does no evil in deed or word or thought, who is restrained in these three respects.





គាថាទី ៣៩២: បុគ្គលដឹងច្បាស់នូវព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងហើយពីអ្នកណា គប្បីថ្វាយបង្គំអ្នកនោះដោយការគោរព ដូចជាព្រាហ្មណ៍គោរពបូជាភ្លើងដូច្នោះឯង ។

Verse 392. If from somebody one should learn the Teaching of the Buddha, he should respectfully pay homage to that teacher, as a brāhmin worships the sacrificial fire.

គាថាទី ៣៩៣: បុគ្គលឈ្មោះថា ព្រាហ្មណ៍ ព្រោះផ្នួងសក់ ព្រោះគោត្រ ព្រោះជាតិមិនបានឡើយ សច្ចៈនិងធម្មៈមាននៅក្នុងបុគ្គលណា បុគ្គលនោះឈ្មោះថាជាអ្នកបរិសុទ្ធឈ្មោះថា ព្រាហ្មណ៍ ។

Verse 393. Not by wearing matted hair, nor by lineage, nor by caste, does one become a brāhmaṇa; only he who realizes the Truth and the Dhamma is pure; he is a brāhmaṇa.

គាថាទី ៣៩៤: នែអ្នកល្ងង់ខ្លៅ! ប្រយោជន៍អ្វីដល់អ្នកដោយផ្នួងសក់ទាំង-ឡាយ ប្រយោជន៍អ្វីដល់អ្នកដោយសំពត់ស្បែកខ្លា ឈ្មោះអជិនៈ ចិត្តខាងក្នុងរបស់អ្នកអាក្រក់ អ្នកដុះជម្រះតែខាងក្រៅម្យ៉ាងប៉ុណ្ណោះឯង ។

Verse 394. O foolish one! What is the use of wearing matted hair? What is the use of Your wearing a garment made of antelope skin? In you, there is a forest (of moral defilements); you clean yourself only externally.

គាថាទី ៣៩៥: តថាគតហៅជនដែលស្លៀកសំពត់បង្សុកូល មានរូបរាងកាយស្គាំងស្គម មានសរសៃរឹមរវាម ចម្រើនឈានទៅក្នុងព្រៃតែម្នាក់ឯងនោះថា ជាព្រាហ្មណ៍ ។

Verse 395. Him I call a brāhamaṇa who wears robes made from rags (picked up from a dust heap), who is lean with veins standing out, who meditates alone in the forest.

គាថាទី ៣៩៦: តថាគតមិនហៅបុគ្គលដែលកើតពីកំណើត មានមាតាជាដែនកើតថាជាព្រាហ្មណ៍ បុគ្គលនោះឈ្មោះថា ភោវាទី ឈ្មោះថា ជាអ្នកមានកិលេសគ្រឿងកង្វល់ តែតថាគតហៅបុគ្គលដែលមិនមានកិលេសគ្រឿងកង្វល់ មិនប្រកាន់ខ្លួនថា ព្រាហ្មណ៍ ។

Verse 396. I do not call him a brāhmaṇa just because he is born from the womb of a brāhmaṇa mother. He is just a bhovadi brahmin if he is not free from moral defilements. Him I call a brāhmaṇa, who is free from moral defilements and from attachment.

គាថាទី ៣៩៧: អ្នកណាកាត់ផ្តាច់សំយោជន៍គ្រប់យ៉ាងចោលអស់ហើយ មិនភ័យញាប់ញ័រ តថាគតហៅអ្នកនោះដែលកន្លងកិលេសគ្រឿងជាប់ជំពាក់បានហើយ ជាអ្នករួចផុតហើយថា ជាព្រាហ្មណ៍ ។

Verse 397. Him I call a brāhmaṇa, who has cut off all fetters and is fearless, who is beyond attachment and is free from moral defilements.





គាថាទី ៣៩៨: តថាគតហៅបុគ្គលដែលកាត់ផ្តាច់នូវបន្ទញ គឺសេចក្តីក្រោធខឹង ខ្សែជ្រាមគឺតណ្ហា និងកាត់ផ្តាច់នូវទិដ្ឋិដែលប្រៀបដូចចន្ទោល ព្រមជាមួយអនុស្ស័យដូចខ្សែចង មានអវិជ្ជាដូចជាបន្ទញ ស្រាយចេញអស់ហើយ ជាអ្នកចេះដឹងថា ជាព្រាហ្មណ៍ ។

Verse 398. Him I call a brāhmaṇa, who has cut the strap (of ill will), the thong (of craving) and the cord (of wrong views together with latent defilements), who has lifted the bar that fastens the door (of ignorance), and who knows the Truth.

គាថាទី ៣៩៩: អ្នកណាមិនប្រទូសរ៉ាយ អត់ធន់ចំពោះពាក្យជេរប្រទេច ពាក្យតិះដៀល និងពាក្យចងចាំបាន តថាគតហៅអ្នកនោះដែលមានកំលាំង គឺ ខន្តីមានពួកពល គឺខន្តី ថា ជាព្រាហ្មណ៍ ។

Verse 399. Him I call a brāhmaṇa, who, without anger endures abuse, beating and being bound, and to whom the strength of patience is like the strength of an army.

គាថាទី ៤០០: តថាគតហៅអ្នកដែលមិនក្រោធ មានវត្តប្រតិបត្តិ មានសីលមិនមានតណ្ហាដែលជាគ្រឿងសម្រើបចិត្ត បានអប់រំខ្លួនស្រេចហើយ មានសរីរៈនៅក្នុងទីបំផុតនោះ ថា ជាព្រាហ្មណ៍ ។

Verse 400. Him I call a brāhmaṇa, who is free from anger, who practises austerity, who is virtuous and free from craving, who is controlled in his senses and for whom this body (i.e., existence) is the very last.

គាថាទី ៤០១: អ្នកណាមិនជាប់ជំពាក់ក្នុងកាមទាំងឡាយ ដូចទឹកមិនជាប់លើស្លឹកឈូក ដូចជាគ្រាប់ស្ពៃមិនជាប់លើចុងដែកដែលស្រួចយ៉ាងនោះឯង តថាគតហៅអ្នកនោះថា ជាព្រាហ្មណ៏ ។

Verse 401. Him I call a brāhmaṇa, who does not cling to sensual pleasures, just as water does not cling to a lotus leaf, or the mustard seed to the tip of an awl.

គាថាទី ៤០២: អ្នកណាក្នុងសាសនានេះ ដឹងច្បាស់នូវការអស់ទៅនៃសេចក្ដីទុក្ខរបស់ខ្លួន តថាគតហៅអ្នកនោះដែលមានភារៈទំលាក់ចោលហើយ រួចផុតអស់ហើយថា ជាព្រាហ្មណ៏ ។

Verse 402. Him I call a brāhmaṇa, who even in this existence realizes the end of dukkha (i.e., Nibbāna), who has laid down the burden (of the khandhas) and who is free from moral defilements.

គាថាទី ៤០៣: តថាគតហៅបុគ្គលដែលមានបញ្ញាជ្រៅជ្រះ ជាអ្នកប្រាជ្ញឈ្លាសវៃក្នុងផ្លូវ និងមិនមែនជាផ្លូវ បានសម្រេចនូវប្រយោជន៏ដ៏ខ្ពង់ខ្ពស់នោះថា ជាព្រាហ្មណ៏ ។

Verse 403. Him I call a brāhmaṇa, who is wise and is profound in his knowledge, who knows the right way from the wrong way, and who has attained the highest goal (i.e., arahatship).



គាថាធម្មបទ

គាថាទី ៤០៤: តថាគតហៅអ្នកដែលមិនជាប់ជំពាក់ដោយជនពីរពួក គឺ: គ្រ-ហស្ថ១ បព្វជិត១ ជាអ្នកធ្វើដំណើរទៅមិនមានអាល័យ ប្រាថ្នាតិច ថាជាព្រាហ្មណ៏ ។

Verse 404. Him I call a brāhmaṇa, who associates not with the householder or with the homeless one, or with both, who is free from sensual desire, and has few wants.

គាថាទី ៤០៥: អ្នកណាឈប់ប្រើអំណាចលើពួកសត្វដែលតក់ស្លុត និងមិនតក់ស្លុត មិនសម្លាប់ដោយខ្លួនផង មិនប្រើអ្នកដទៃឱ្យទៅសម្លាប់ផង តថាគតហៅអ្នកនោះថា ជាព្រាហ្មណ៏ ។

Verse 405. Him I call a brāhmaṇa, who has laid aside the use of force towards all beings, the perturbed as well as the unperturbed (i.e., arahats), and who does not kill or cause others to kill.

គាថាទី ៤០៦: តថាគតហៅអ្នកដែលមិនក្រោធខឹង ក្នុងបុគ្គលដែលក្រោធខឹងជាអ្នករលត់ហើយ ក្នុងបុគ្គលដែលមានអាជ្ញាលើខ្លួន ជាអ្នកមិនប្រកាន់ខ្លួន ក្នុងបុគ្គលដែលប្រកាន់ខ្លួននោះថា ជាព្រាហ្មណ៏ ។

Verse 406. Him I call a brāhmaṇa, who is not hostile to those who are hostile, who is peaceful (i.e., has laid aside the use of force) to those with weapons, and who is without attachment to objects of attachment.

គាថាទី ៤០៧: រាគៈ ទោសៈ មោហៈ និងការមិនរមិលគុណគេ អ្នកណាមួយ

ធ្វើឱ្យធ្លាក់ហើយ ដូចគ្រាប់ស្ពៃដែលជ្រុះធ្លាក់ចេញពីចុងដែកដែលស្រួចយ៉ាង

នោះឯង តថាគតហៅអ្នកនោះថា ជាព្រាហ្មណ៍ ។

Verse 407. Him I call a brāhmaṇa, from whom passion, ill will, pride and detraction have fallen off like a mustard seed from the tip of an awl.

គាថាទី ៤០៨: អ្នកណានិយាយពាក្យដែលជាហេតុមិនធ្វើឱ្យអ្នកដទៃខូចខក

ចិត្ត ជាពាក្យយល់គ្នាបាន ជាពាក្យទៀងត្រង់ មិនមែនពាក្យអាក្រក់ តថាគត

ហៅអ្នកនោះថា ជាព្រាហ្មណ៍ ។

Verse 408. Him I call a brāhmaṇa, who speaks gentle, instructive and true words, and who does not offend anyone by speech.

គាថាទី ៤០៩: អ្នកណាមិនកាន់យកនូវរបស់ដែលវែងឬខ្លី តូចឬធំ ល្អឬមិនល្អ

ដែលម្ចាស់គេមិនបានឱ្យហើយក្នុងលោក តថាគតហៅអ្នកនោះថា ព្រាហ្មណ៍ ។

Verse 409. Him I call a Brāhmaṇa, who, in this world takes nothing that is not given him, be it long or short, big or small, good or bad.

គាថាទី ៤១០: សេចក្តីប្រាថ្នារបស់បុគ្គលណាមិនមាននៅក្នុងលោកនេះផង ក្នុង

លោកខាងមុខផង តថាគតហៅ បុគ្គលដែលមិនមានសេចក្តីប្រាថ្នាចង់បាន

ប្រាសចាកពីកិលេសហើយនោះថា ជាព្រាហ្មណ៍ ។





Verse 410. Him I call a brāhmaṇa, who has no desire either for this world or for the next, who is free from craving and from moral defilements.

គាថាទី ៤១១: អ្នកណាមិនមានសេចក្តីអាល័យ អ្នកណាដឹងជាក់ច្បាស់ហើយ

ជាអ្នកមិនមានសេចក្តីសង្ស័យ ជាហេតុនិយាយថាយ៉ាងណា តថាគតហៅ អ្នក

ដែលបានដល់អមតធម៌ដោយលំដាប់នោះថា ជាព្រាហ្មណ៍ ។

Verse 411. Him I called a brāhmaṇa, who has no craving, who through knowledge of the Four Noble Truths is free from doubt, and has realized Nibbāna the Deathless.

គាថាទី ៤១២: អ្នកណាលះបុណ្យបាបទាំងពីរ និងកិលេសគ្រឿងជាប់ជំពាក់

ក្នុងលោកបានហើយ តថាគតហៅអ្នកដែលមិនសោកសៅ អស់កិលេស បរិ-

សុទ្ធនោះថា ព្រាហ្មណ៍ ។

Verse 412. Him I call a brāhmaṇa, who, in this world, has transcended both ties good and evil; who is sorrowless and, being free from the taints of moral defilements, is pure.

គាថាទី ៤១៣: តថាគតហៅ បុគ្គលដែលមានសេចក្តីត្រេកអរក្នុងភពអស់

ហើយ ជាអ្នកបរិសុទ្ធល្អ មិនសៅហ្មង ដូចជាព្រះច័ន្ទដែលប្រាសចាកមន្ទិលនោះ

ថា ជាព្រាហ្មណ៍ ។

Verse 413. Him I call a brāhmaṇa, who, like the moon (in a cloudless sky), is pure, clear and serene, and in whom craving for existence is extinct.

គាថាទី ៤១៤: អ្នកណាឆ្លងផុតផ្លូវរអិល ភក់ជ្រៅ វដ្តសង្សារ និងមោហៈនេះបានហើយ ជាអ្នកឆ្លងផុតហើយ ដល់ត្រើយហើយ ជាអ្នកមានឈាន មិនមានកិលេសជាគ្រឿងញាប់ញ័រ មិនមានសេចក្តីសង្ស័យជាហេតុនិយាយថាយ៉ាងណា មិនប្រកាន់មាំ រលត់ហើយ តថាគតហៅអ្នកនោះថា ជាព្រាហ្មណ៍ ។

Verse 414. Him I call a brāhmaṇa, who, having traversed this dangerous swamp (of passion), this difficult road (of moral defilements), the ocean of life (saṁsāra) and the darkness of ignorance (moha), and having crossed the fourfold Flood, has reached the other shore (Nibbāna); who practises Tranquillity and Insight Meditation, who is free from craving and from doubt, who clings to nothing and remains in perfect peace.

គាថាទី ៤១៥: អ្នកណាលះកាមទាំងឡាយក្នុងលោកនេះហើយ ជាអ្នកមិនមានផ្ទះសម្បែង វៀរចាកបានហើយ តថាគតហៅអ្នកដែលមានកាមនិងភពអស់ហើយនោះថា ជាព្រាហ្មណ៍ ។

Verse 415. Him I call a brāhmaṇa, who, in this world, has given up sensual pleasures, and leaving the home-life has become a bhikkhu; who has eradicated sensual desires and has come to the end of existence.

គាថាទី ៤១៦: អ្នកណាលះតណ្ហាទាំងឡាយក្នុងលោកនេះបានអស់ហើយ ជាអ្នកគ្មានផ្ទះ លះបង់បានហើយ តថាគតហៅអ្នកដែលមានតណ្ហានិងភពអស់ហើយនោះថា ជាព្រាហ្មណ៍ ។

Verse 416. Him I call a brāhmaṇa, who, in this world, has given up craving, and leaving the home-life has become a



គាថាធម្មបទ

bhikkhu; who has eradicated craving and has come to the end of existence.

គាថាទី ៤១៧: អ្នកណាលះកិលេសគ្រឿងប្រកបដែលជារបស់មនុស្ស កន្លងហួសនូវកិលេសគ្រឿងប្រកបសត្វ ដែលជារបស់ទិព្វបានហើយ តថាគតហៅអ្នកនោះដែលជាអ្នករួចផុតអស់ពីកិលេសគ្រឿងប្រកបទាំងពួងថា ព្រាហ្មណ៍ ។

Verse 417. Him I call a brāhmaṇa, who has given up attachment to (sensual pleasures of) human life, has transcended attachment to (sensual pleasures of) deva life and is completely free from all attachment.

គាថាទី ៤១៨: តថាគតហៅអ្នកដែលលះបង់សេចក្តីត្រេកអរ និងសេចក្តីមិនត្រេកអរបានហើយ ជាអ្នកត្រជាក់ មិនមានឧបធិកិលេសគ្រប់គ្រងលោកទាំងពួងបានហើយ ជាអ្នកអង់អាចក្លាហាននោះថា ជាព្រាហ្មណ៍ ។

Verse 418. Him I call a brāhmaṇa, who has given up taking delight (in sensual pleasures) and not taking delight (in solitude); who has attained perfect peace and is free from moral defilements; who has overcome all the five khandhas (lit., the world) and is diligent.

គាថាទី ៤១៩: អ្នកដឹងការចុតិ និងការកើតឡើងរបស់សត្វទាំងឡាយ ដោយប្រការទាំងពួង តថាគតហៅអ្នកដែលមិនជាប់ជំពាក់ មានដំណើរទៅល្អហើយដឹងហើយនោះថា ជាព្រាហ្មណ៍ ។

Verse 419. Him I call a brāhmaṇa, who knows the death and rebirth of beings in every detail, who is detached, who follows the good practice and knows the Four Noble Truths.

គាថាទី ៤២០: ទេវតា គន្ធព្វ និងមនុស្សទាំងឡាយមិនដឹងនូវគតិរបស់បុគ្គលណា តថាគតហៅអ្នកនោះ ជាអ្នកអស់អាសវក្កិលេសហើយ ជាព្រះអរហន្តថា ជាព្រាហ្មណ៍ ។

Verse 420. Him I call a brāhmaṇa, whose destination the devas or gandhabbas or men do not know who has eradicated moral intoxicants and is an arahat.

គាថាទី ៤២១: សេចក្តីខ្វល់ខ្វាយក្នុងពេលមុន ពេលជាខាងក្រោយ និងក្នុងពេលជាកណ្តាលរបស់អ្នកណាមិនមាន តថាគតហៅអ្នកនោះដែលជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ មិនប្រកាន់មាំ ថា ជាព្រាហ្មណ៍ ។

Verse 421. Him I call a brāhmaṇa, who does not cling to the past, future and present khandha aggregates and who is free from moral defilements and attachment.

គាថាទី ៤២២: តថាគតហៅបុគ្គលដែលអង់អាច ប្រសើរ ជាអ្នកមានប្រាជ្ញាស្វែងរកគុណដ៏ខ្ពង់ខ្ពស់ ឈ្នះវិសេស ហើយមិនកម្រើកញាប់ញ័រ លាងកិលេសជ្រះអស់ហើយ ជាអ្នកភ្ញាក់រឭកនោះថា ជាព្រាហ្មណ៍ ។

Verse 422. Him I call a brāhmaṇa, who is fearless like a bull, who is noble and diligent, who is a seeker of high moral virtues and a conqueror (of three Māras), who is free from craving, who has been cleansed of moral defilements and knows the Four Noble Truths.





គាថាទី ៤២៣: បុគ្គលណាដឹងនូវខន្ធដែលអាស្រ័យនៅក្នុងកាលមុន ទាំងឃើញឋានសួគ៌ និងអបាយ ម្យ៉ាងទៀត បានដល់ហើយនូវការអស់ទៅនៃជាតិ ចប់កិច្ចអស់ហើយព្រោះដឹងច្បាស់ ជាមុនី តថាគតហៅបុគ្គលនោះដែលជាអ្នកនៅជាប់ព្រហ្មចរិយធម៌ហើយ ថា ជាព្រាហ្មណ៍ ។

Verse 423. Him I call a brāhmaṇa, who knows past existences, who sees the celestial as well as the lower worlds, who has reached the end of rebirths, who, with *Magga* Insight, has become an arahat and has accomplished all that is to be accomplished for the eradication of moral defilements.

## **ឯកសារពិគ្រោះ - Reference:**

- ព្រះត្រៃបិដកខ្មែរ, សុត្តន្តបិដក, ខុទ្ទកនិកាយ ខុទ្ទកបាឋ, ធម្មបទគាថា ឧទាន, បឋមភាគ, លេខ ៥២, ទំព័រ ២១-១១២
- ភិក្ខុ មហាឃិន នឿន, **វិនយធរោ,** គាថាធម្មបទប្រែ
- លោក K.R. Norman, (1997), ធម្មបទប្រែ (ភាសាអង់គ្លេស)
- ព្រះតេជគុណ **នារទះ** (Narada Thera), 1993, ធម្មបទប្រែ (ភាសាអង់គ្លេស)
- ព្រះតេជគុណ **ពុទ្ធរក្ខិតះ** (Buddharakkhita), ធម្មបទប្រែ (ភាសាអង់គ្លេស)
- លោកស្រី (Daw Mya Tin), ធម្មបទប្រែ (ភាសាអង់គ្លេស)
- បទានុក្រមធម្មបទខ្មែរ ភាគ ១, ២, ៣
- សម្តេចព្រះសង្ឃរាជ ជួន ណាត, វចនានុក្រមខ្មែរ
- ព្រះត្រៃបិដក ភាសាអង់គ្លេស, សុត្តន្តបិដក, ទីឃនិកាយ
-វចនានុក្រមអង់គ្លេស ខ្មែរ-អង់គ្លេស, អង់គ្លេស-ខ្មែរ
- វចនានុក្រមអង់គ្លេស (Pāli Proper Names)
- Encyclopaedia Britannica 2008 ultimate Reference Suite.



## **ពិនិត្យកែសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធដោយ**

-ព្រះមហា **សឿង វុឌ្ឍី** សមណនិស្សិតថ្នាក់អនុបណ្ឌិត
- ភិក្ខុ **អ៊ុំ សត្ថា** សមណនិស្សិតថ្នាក់អនុបណ្ឌិត
- ភិក្ខុ **មួន វិចិត្រ** សមណនិស្សិតថ្នាក់អនុបណ្ឌិត
- ភិក្ខុ **ខ៊ាន ភាគ** សមណនិស្សិតថ្នាក់បរិញ្ញាបត្រ
-ភិក្ខុ **វ៉ា ចន្ទប៊ុន** សមណនិស្សិតថ្នាក់បរិញ្ញាបត្រ
- សាមណេរ **ឆ្លឹច មាស** សមណនិស្សិតថ្នាក់បរិញ្ញាបត្រ
- សាមណេរ **ខឹន ម៉ៅ** សមណនិស្សិតថ្នាក់បរិញ្ញាបត្រ
- សាមណេរ **សុខ ធាវី** សមណនិស្សិតថ្នាក់អនុបណ្ឌិត
- ឧបាសក **ម៉ៅ វ៉ាន** ឧបាសិកា **ធន់ សំបូរ** អតីតទីប្រឹក្សាឯកអគ្គរាជទូតកម្ពុជា ប្រចាំសហភាពមីយ៉ាន់ម៉ា
- លោក **ព្រំ ស៊ីណា** និស្សិតថ្នាក់បរិញ្ញាបត្រ

## **វាយកុំព្យូទ័រ និងរចនាក្របដោយ**

- ភិក្ខុបញ្ញាវរោ **ស៊ុយ សុវណ្ណ** សមណនិស្សិតថ្នាក់អនុបណ្ឌិត